## សេចក្ដីសង្ខេប

# របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣

## ការឈានឡើងនៃភូមិភាគខាងត្បូង :

វឌ្ឍនភាពមនុស្សក្នុងពិភពលោកចម្រុះ

UNDP



Copyright © 2013
by the United Nations Development Programme
1 UN Plaza, New York, NY 10017, USA

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃឯកសារនេះអាចនឹងត្រូវផលិតឡើងវិញ រក្សាទុកនៅក្នុងប្រព័ន្ធ ដែលអាចទាញមកប្រើប្រាស់ឡើងវិញ ឬបញ្ជូនបន្តដោយគ្មានការអនុញ្ញាតជាមុនឡើយ ទោះក្នុងទម្រង់ ឬតាមមធ្យោបាយណាមួយក៏ដោយ ដែលរួមទាំងជាទម្រង់អេឡិចត្រូនិក មេកានិក ការថតចម្លង អាត់សម្លេង។

បោះពុម្ពនៅកម្ពុជា ដោយ ### [printers]
ពិនិត្យកែសម្រួល និងផលិត ៖ Communications Unit/UNDP Cambodia
ប្រែសម្រួល ៖ ម៉ម កុសល
រចនាបថ ៖ Melanie Doherty Design

# ក្រុមអ្នករៀបរៀងរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៣

**នាយក និងប្រធានក្រុមអ្នកនិពន្ធ**
Khalid Malik

**ការស្រាវជ្រាវ និងស្ថិតិ**
Maurice Kugler (នាយកផ្នែកស្រាវជ្រាវ), Milorad Kovacevic (នាយកផ្នែកស្ថិតិ), Subhra Bhattacharjee, Astra Bonini, Cecilia Calderón, Alan Fuchs, Amie Gaye, Iana Konova, Arthur Minsat, Shivani Nayyar, José Pineda និង Swarnim Waglé

**សារគមនាគមន៍ និងការបោះពុម្ព**
William Orme (នាយកផ្នែកសារគមនាគមន៍), Botagoz Abdreyeva, Carlotta Aiello, Eleonore Fournier-Tombs, Jean-Yves Hamel, Scott Lewis និង Samantha Wauchope.

**របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិ**
Eva Jespersen (នាយករង), Christina Hackmann, Jonathan Hall, Mary Ann Mwangi និង Paola Pagliani.

**ប្រតិបត្តិការ និងរដ្ឋបាល**
Sarantuya Mend (នាយកផ្នែកប្រតិបត្តិការ), Ekaterina Berman, Diane Bouopda, Mamaye Gebretsadik និង Fe Juarez-Shanahan.

**ការិយាល័យរបាយការណ៍អភិវឌ្ឍន៍មនុស្ស**
របាយការណ៍អភិវឌ្ឍន៍មនុស្ស គឺជាផលិតផលដែលបានពីកិច្ចប្រឹងប្រែងរួមគ្នាមួយនៅក្រោមការដឹកនាំរបស់នាយក រួមជាមួយអ្នកស្រាវជ្រាវ និងស្ថិតិ និងបុគ្គលិកខាងសារគមនាគមន៍ និងបោះពុម្ព រួមទាំងក្រុមអ្នកគាំទ្រដល់ការរៀបរៀងរបាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិទាំងមូល។ សហសេវិកក្នុងផ្នែកប្រតិបត្តិការ និងរដ្ឋបាល បានសម្របសម្រួលកិច្ចការរបស់ការិយាល័យនេះ។

## សេចក្ដីសង្ខេប

# របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៣

## ការឈានឡើងនៃភូមិភាគខាងត្បូង ៖

### វឌ្ឍនភាពមនុស្សក្នុងពិភពលោកចម្រុះ

Empowered lives.
Resilient nations.

Published for the
United Nations
Development
Programme
(UNDP)

# អារម្ភកថា

របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣ "ការឈានឡើងនៃភូមិភាគខាងត្បូង ៖ វឌ្ឍនភាពមនុស្សនៅក្នុងពិភពលោកចម្រុះ" ពិនិត្យមើលការវិវត្តភូមិសាស្ត្រនយោបាយ នៅក្នុងសម័យកាលយើងនេះ ក្នុងនោះ មានបញ្ហា និងនិន្នាការនានាដែលលេចឡើង និងតួអង្គថ្មីៗ ដែលកំពុងមានឥទ្ធិពលមកលើទិដ្ឋភាពនៃការអភិវឌ្ឍ។

របាយការណ៍នេះធ្វើទឡ្ហីករណ៍ថា វិបល្លាសលេចធ្លោ នៃប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំក្នុងការក្លាយខ្លួនទៅជាសេដ្ឋកិច្ច ពោរពេញដោយឌីណាមិក អមដោយឥទ្ធិពលនយោបាយកាន់តែខ្លាំងឡើងនោះ កំពុងតែនាំមកនូវផលបច្ច័យយ៉ាងច្រើនមកលើវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស។

របាយការណ៍នេះកត់សំគាល់ថា នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ប្រទេសទាំងអស់បានបង្កើនសំទុះនៃសមិទ្ធផលរបស់ខ្លួន លើវិស័យអប់រំ សុខភាព និងប្រាក់ចំណូល ដូចដែលបានវាស់ឃើញតាមរយៈសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) រហូតដល់ថា គ្មានប្រទេសណាមួយមានតួលេខ HDI នៅក្នុងឆ្នាំ ២០១២ ទាបជាងនៅក្នុងឆ្នាំ ២000ឡើយ។នៅពេលប្រទេសដែលមានតួលេខ HDI ទាប មានកំណើនកាន់តែឆាប់រហ័សនៅក្នុងអំឡុងពេលនេះ គេសង្កេតឃើញមានភាពចុះសម្រុងគ្នាគួរឲ្យកត់សំគាល់នៃតួលេខ HDI នៅកម្រិតពិភពលោក បើទោះជាវឌ្ឍនភាពនេះរវាងតំបន់នានាមិនមានកម្រិតស្មើគ្នាក៏ដោយ។

ដោយសង្កេតមើលជាពិសេសបណ្តាប្រទេសដែលបានបង្កើនតួលេខ HDI របស់ខ្លួនយ៉ាងច្រើនរវាងឆ្នាំ១៩៩0និង២០១២ទាំងខាងប្រាក់ចំណូល និងកត្តាដទៃទៀត ក្រៅពីប្រាក់ចំណូលនៅក្នុងក្របខ័ណ្ឌការអភិវឌ្ឍមនុស្ស របាយការណ៍នេះពិនិត្យមើលយុទ្ធសាស្ត្រនានា ដែលជួយប្រទេសទាំងនោះ ឲ្យមានដំណើរឈានទៅមុខបានល្អ។ ក្នុងន័យនេះ របាយការណ៍ឆ្នាំ ២០១៣ បានរួមចំណែកដុំកំភួនទៅក្នុងផ្នត់គំនិតការអភិវឌ្ឍ ដោយអធិប្បាយអំពីកត្តាជំរុញជាក់លាក់ ដែលនាំឲ្យមានវិបល្លាសការអភិវឌ្ឍ និងលើកស្ទើអាទិភាពគោល-នយោបាយ ដែលអាចជួយបន្តកម្លាំងចលករនេះទៅអនាគត។

យោងតាមនិទស្សន៍ ដែលបានធ្វើឡើងសម្រាប់របាយការណ៍នេះ រហូតដល់ឆ្នាំ ២០២០ ផលិតផលសេដ្ឋកិច្ចសរុប នៃប្រទេសនាំមុខចំនួនបី ពោលគឺ ប្រេស៊ីល ចិន និងឥណ្ឌា នឹងមានច្រើនជាងផលិតសរុបនៃប្រទេសកាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក រួមបញ្ចូលគ្នាទៅទៀត។ ដូចមានបង្ហាញក្នុងរបាយការណ៍នេះ មួយភាគធំនៃកំណើននេះកើតចេញពីភាពជាដៃគូថ្មីៗខាងពាណិជ្ជកម្ម និងបច្ចេកវិទ្យា នៅក្នុងភូមិភាគខាងត្បូងផ្ទាល់តែម្តង។

ទោះជាយ៉ាងណាក៏ដោយ សារគន្លឹះមួយដែលមាននៅក្នុង របាយការណ៍អភិវឌ្ឍន៍មនុស្សមួយនេះ និងរបាយការណ៍មុនៗ គឺថាកំណើនសេដ្ឋកិច្ច មិនសុទ្ធតែបម្លែងដោយស្វ័យប្រវត្តិទៅជាវឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សឡើយ។ គោល-នយោបាយជួយជនក្រីក្រ និងការវិនិយោគយ៉ាងច្រើនលើសមត្ថភាពរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើការអប់រំ អាហារូបត្ថម្ភ និងសុខភាព និងជំនាញក្នុងការងារ អាចពង្រីកលទ្ធភាពទទួលបានការងារសមរម្យ និងផ្តល់លក្ខខណ្ឌសម្រាប់និរន្តរភាពនៃវឌ្ឍនភាព។

របាយការណ៍ឆ្នាំ ២០១៣ នេះ កំណត់អត្ត-សញ្ញាណវិស័យជាក់លាក់ចំនួនបួន នៃការយកចិត្តទុកដាក់សម្រាប់ទ្រទ្រង់និរន្តរភាព នៃចលករអភិវឌ្ឍន៍ ពោលគឺ បង្កើនសមធម៌ រួមមានខាងយេនឌ័រ, ជំរុញឲ្យមានការបញ្ចេញទស្សនៈ និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងនោះ មានយុវជនផងដែរ, ការដោះស្រាយបញ្ហាបរិស្ថាន និងការគ្រប់គ្រងស្ថានភាពប្រែប្រួលនៃប្រជាសាស្ត្រ។

របាយការណ៍នេះក៏ស្នើផងដែរថា ដោយសារតែការប្រឈមជាសកលខាងការអភិវឌ្ឍ កាន់តែមានសភាពស្មុគស្មាញ និងមានលក្ខណៈឆ្លងដែន វាជាប្រការមួយចាំបាច់ ត្រូវមានចំណាត់ការតាមបែបសម្របសម្រួលមួយ លើការប្រឈមសំខាន់ៗបំផុតចំពោះមុខនៅក្នុងសម័យកាលយើងនេះ បើទោះជាការប្រឈមក្នុងការលុបបំបាត់ ភាពក្រីក្រ ការប្រែប្រួលអាកាសធាតុ ឬសន្តិភាព និងសន្តិសុខក្តី។ ក្នុងខណៈដែលប្រទេសនានាមានទំនាក់ទំនង

គ្នាកាន់តែច្រើនឡើង តាមរយៈពាណិជ្ជកម្មចំណាកស្រុក និងបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង គ្មានអ្វីគួរឲ្យសង្ស័យទេ ដែលថាសេចក្ដីសម្រេចខាងនយោបាយនៅក្នុងកន្លែងមួយ នឹងមានឥទ្ធិពលខ្លាំងមកលើកន្លែងផ្សេងទៀត។ វិបត្តិនានានៅក្នុងបណ្ដាឆ្នាំកន្លងទៅនេះ ខាងស្បៀងអាហារ ហិរញ្ញវត្ថុ និងអាកាសធាតុ ដែលបានបំផ្លាញអាយុជីវិតមនុស្សអស់ជាច្រើន បានចង្អុលបង្ហាញអំពីស្ថានភាពនេះ និងអំពីសារៈសំខាន់នៃការងារកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋពីសំណាក់ហេតុការណ៍អាក្រក់ និងគ្រោះមហន្តរាយនានា។

ដើម្បីក្រេបយកចំណេះដឹង ជំនាញ និងគំនិតអភិវឌ្ឍន៍នៅក្នុងភូមិភាគខាងត្បូង របាយការណ៍នេះ អំពាវនាវឲ្យបង្កើតស្ថាប័នថ្មីៗ ដែលអាចសម្រួលដល់សមាហរណកម្មនៅថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ អំណាចដែលលេចឡើង នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ គឺជាប្រភពនៃគោលនយោបាយបែបច្នៃប្រឌិតថ្មីៗ ខាងសង្គម និងសេដ្ឋកិច្ចរួចទៅហើយ និងក៏ដូចជាដៃគូពាណិជ្ជកម្ម វិនិយោគ និងសហប្រតិបត្តិការអភិវឌ្ឍន៍កាន់តែច្រើនសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។

ប្រទេសដទៃទៀតជាច្រើន នៅទូទាំងភូមិភាគខាងត្បូង ទទួលបានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ហើយបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូងរបស់ប្រទេសទាំងនោះក៏ជាកម្លាំងចលករផងដែរ សម្រាប់គោលនយោបាយអភិវឌ្ឍន៍។ យូអិនឌីភី អាចដើរតួដ៏មានប្រយោជន៍ក្នុងនាមជាអន្តរការីពាំនាំមកនូវចំណេះដឹង និងជាអ្នកកៀងគរដៃគូនានា ពោលគឺ រដ្ឋាភិបាល សង្គមស៊ីវិល និងក្រុមហ៊ុនពហុជាតិ ដើម្បីចែករម្លែកបទពិសោធន៍នានា។ យើងមានតួនាទីសំខាន់មួយផងដែរក្នុងការសម្រួលឲ្យមានការសិក្សា រៀនសូត្រ និងការកសាងសមត្ថភាព។របាយការណ៍នេះផ្ដល់ទស្សនវិស័យស៊ីជម្រៅមានប្រយោជន៍ជាខ្លាំងសម្រាប់ការចូលរួមរបស់យើងទៅអនាគត នៅក្នុងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។

នៅទីបំផុត របាយការណ៍នេះអំពាវនាវឲ្យសម្លឹងមើលដោយមធ្យ័តផងដែរ ទៅស្ថាប័នអភិបាលកិច្ចពិភពលោក ដើម្បីជំរុញឲ្យមានពិភពលោកមួយដែលកាន់តែមានយុត្តិធម៌ និងកាន់តែស្មើភាពគ្នាជាងមុន។ របាយការណ៍នេះចង្អុលបង្ហាញអំពីរចនាសម្ព័ន្ធ ដែលចាស់ហួសសម័យ ដែលមិនឆ្លុះបញ្ចាំងអំពីតថភាពសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយថ្មីៗ ដែលបានអធិប្បាយ និងពិចារណាជម្រើសនានា សម្រាប់ភាពជាដៃគូនៅក្នុងសម័យកាលថ្មីនេះ។ របាយការណ៍នេះក៏អំពាវនាវផងដែរ ឲ្យមានតម្លាភាព និងគណនេយ្យភាពច្រើនជាងមុន និងគូសបញ្ជាក់អំពីតួនាទីនៃសង្គមស៊ីវិលលើពិភពលោក ដែលបានធ្វើការតស៊ូមតិឲ្យមានការរីកចម្រើនបែបនេះ និងដើម្បីផ្ដល់អំណាចធ្វើសេចក្ដីសម្រេចកាន់តែច្រើនឡើង ដល់អ្នកដែលរងគ្រោះ ដោយសារការប្រឈមទាំងនេះនៅកម្រិតពិភពលោក ដែលជាញឹកញាប់ អ្នកទាំងនោះ គឺជាប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះជាងគេនៅលើពិភពលោកយើង។

ក្នុងពេលដែលការពិភាក្សា អំពីរបៀបវារៈអភិវឌ្ឍន៍ពិភពលោកសម្រាប់ក្រោយឆ្នាំ ២០១៥ នៅតែបន្ត ខ្ញុំសង្ឃឹមថា មនុស្សជាច្រើននឹងឆ្លៀតពេល ដើម្បីអានរបាយការណ៍នេះ និងឆ្លុះបញ្ចាំងអំពីមេរៀននានា ដែលមានក្នុងរបាយការណ៍នេះ ជាប្រយោជន៍ដល់ពិភពលោករបស់យើង ដែលកំពុងមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស។ របាយការណ៍ជួយយើង ឲ្យកាន់តែមានភាពភ្លឺស្វាងជាងមុនក្នុងការយល់ដឹង អំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍសកលលោក និងបង្ហាញថា តើយើងអាចរៀនសូត្របានប៉ុណ្ណាពីបទពិសោធន៍នានា នៃវឌ្ឍនភាពយ៉ាងឆាប់រហ័សលើការអភិវឌ្ឍ នៅក្នុងប្រទេសជាច្រើនក្នុងភូមិភាគខាងត្បូង។



Helen Clark
**ហេឡិន ក្លាក**
*អភិបាល*
*កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ*

# មាតិកានៃរបាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣


អារម្ភកថា

សេចក្ដីថ្លែងអំណរគុណ

ទិដ្ឋភាពរួម

សេចក្ដីផ្ដើម

## ជំពូក ១
### ស្ថានភាពការអភិវឌ្ឍមនុស្ស

វឌ្ឍនភាពរបស់ប្រជាជាតិ

សមាហរណកម្មសង្គម

សន្តិសុខមនុស្សជាតិ

## ជំពូក ២
### ភូមិភាគខាងត្បូងដែលមានលក្ខណៈសកលជាងមុន

ការស្ដារតុល្យភាពឡើងវិញ ៖ ពិភពលោកមានលក្ខណៈកាន់តែសកល

ភូមិភាគខាងត្បូង ក៏កាន់តែសកលជាងមុន

សន្ទុះពីការអភិវឌ្ឍមនុស្ស

គំនិតច្នៃប្រឌិត និងសហគ្រិនភាពនៅភូមិភាគខាងត្បូង

ទម្រង់ថ្មីនៃកិច្ចសហប្រតិបត្តិការ

ធ្វើឲ្យមានវឌ្ឍនភាពយូរអង្វែង

## ជំពូក ៣
### កត្តានាំឲ្យមានវិបល្លាសក្នុងការអភិវឌ្ឍ

កត្តាជំរុញទី ១ ៖ ការអភិវឌ្ឍបែបសកម្មនិយម

កត្តាជំរុញទី ២ ៖ ទាញយកប្រយោជន៍ពីទីផ្សារពិភពលោក

កត្តាជំរុញទី ៣ ៖ ភាពច្នៃប្រឌិតមុះមុតខាងគោលនយោបាយសង្គម

## ជំពូក ៤
### រក្សាកម្លាំងចលករ

អាទិភាពគោលនយោបាយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍

ការធ្វើម៉្យដែលប្រជាសាស្ត្រ និងការអប់រំ

ឥទ្ធិពលនៃអត្រាមនុស្សចាស់

តម្រូវការឲ្យមានគោលនយោបាយប្រកបដោយមហិច្ឆិតា

ការឆក់ឱកាស

## ជំពូក ៥
### អភិបាលកិច្ច និងភាពជាដៃគូសម្រាប់សម័យកាលថ្មី

ទស្សនៈសកលថ្មីមួយ អំពីផលិតផលសាធារណៈ

ភាពជាតំណាងប្រសើរជាងមុនសម្រាប់ភូមិភាគខាងត្បូង

សង្គមស៊ីវិលសកលលោក

ឆ្ពោះទៅពហុភាពនិយមដែលស៊ីសង្វាក់គ្នា

អធិបតេយ្យភាពប្រកបដោយការទទួលខុសត្រូវ

ស្ថាប័នថ្មី យន្តការថ្មី

សេចក្ដីសន្និដ្ឋាន ៖ ភាពជាដៃគូនៅក្នុងសម័យកាលថ្មី

កំណត់សំគាល់

ឯកសារយោង

## ឧបសម្ព័ន្ធស្ថិតិ

សេចក្ដីណែនាំសម្រាប់អ្នកអាន

សេចក្ដីពន្យល់អំពីប្រទេស និងលំដាប់ថ្នាក់គិតតាម HDI សម្រាប់ឆ្នាំ ២០១២

តារាងស្ថិតិ

១ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស និងសមាសភាគនានា

២ និន្នាការនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ១៩៨០-២០១២

៣ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ដែលបានគិតបញ្ចូលវិសមភាព

៤ សន្ទស្សន៍វិសមភាពយេនឌ័រ

៥ សន្ទស្សន៍ភាពក្រីក្រក្នុងក្របខ័ណ្ឌរួម

៦ បន្ទុកលើធនធាន

៧ សុខភាព

៨ ការអប់រំ

៩ សមាហរណកម្មសង្គម

១០ លំហូរទំនិញ និងសេវាកម្មនៅក្នុងពាណិជ្ជកម្មអន្តរជាតិ

១១ លំហូរ និងចរាចរជាអន្តរជាតិនៃមូលធន

១២ ការបង្កើតថ្មី និងបច្ចេកវិទ្យា

១៣ បរិស្ថាន

១៤ និន្នាការនៃចំនួនប្រជាជន

តំបន់នានា

ទិន្នន័យស្ថិតិយោង

ឧបសម្ព័ន្ធបច្ចេកទេស ៖ កំណត់សំគាល់លើសេចក្ដីពន្យល់ពីការធ្វើនិទស្សន៍

# សេចក្តីសង្ខេប

ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨-២០០៩ បណ្តាសេដ្ឋកិច្ចជឿនលឿនលែងរីកចម្រើនតទៅទៀត តែផ្ទុយទៅវិញ សេដ្ឋកិច្ចបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅតែបន្តលូតលាស់ ដែលនេះជាដំណើរវិវត្តន៍មួយពិភពលោកបានធ្វើការកត់សំគាល់ទុក។ ចាប់តាំងពីពេលនោះមក មានការធ្វើអត្ថាធិប្បាយជាច្រើនអំពីការឈានឡើងនៃភូមិភាគខាងត្បូង ដែលក្នុងពិភពប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានគេចាត់ទុកថាជាកិច្ចស្តារតុល្យភាពពិភពលោកឡើងវិញ (global rebalancing) ដែលគួរតែមានតាំងពីពេលយូរមកហើយ។ កិច្ចពិភាក្សាត្រង់នេះ កន្លងមក បានផ្តោតជាពិសេសតែទៅលើផលទុនក្នុងស្រុកសរុប (GDP) និងកំណើនពាណិជ្ជកម្មនៅក្នុងប្រទេសធំៗមួយចំនួនតូចប៉ុណ្ណោះ។ ប៉ុន្តែ បច្ចុប្បន្នមានតួអង្គពោរពេញដោយឌីណាមិករស់រវើកជាងនេះ កំពុងមានសកម្មភាពដែលពាក់ព័ន្ធប្រទេសច្រើន និងនិន្នាការជ្រាលជ្រៅជាងមុន ជាមួយសក្តានុពលភាពឥទ្ធិពលទូលំទូលាយមកលើអាយុជីវិតប្រជាពលរដ្ឋសមធម៌សង្គម និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន និងនៅកម្រិតពិភពលោកផងដែរ។ ដូចដែលរបាយការណ៍នេះបង្ហាញស្រាប់ ការឈានឡើងនៃភូមិភាគខាងត្បូង គឺជាលទ្ធផលនៃការវិនិយោគជាបន្តបន្ទាប់លើការអភិវឌ្ឍមនុស្ស និងសមិទ្ធផលនានា និងជាឱកាសមួយ ដើម្បីធ្វើឲ្យមានវឌ្ឍនភាពកាន់តែច្រើនថែមទៀត លើការអភិវឌ្ឍមនុស្សសម្រាប់ពិភពលោកទាំងមូល។ ការធ្វើឲ្យវឌ្ឍនភាពនេះក្លាយជាតថភាព ទាមទារឲ្យមានការធ្វើសេចក្តីសម្រេចនយោបាយប្រកបដោយការយល់ដឹងជាមុន និងភាពឈ្លាសវៃនៅកម្រិតពិភពលោក និងនៅថ្នាក់ជាតិដោយផ្អែកលើមេរៀននានាខាងគោលនយោបាយ ដូចដែលវិភាគនៅក្នុងរបាយការណ៍នេះ។

## ការឈានឡើងនៃភូមិភាគខាងត្បូង

ការឈានឡើងនៃភូមិភាគខាងត្បូង គឺជាព្រឹត្តិការណ៍ពុំធ្លាប់មានពីមុនមក បើគិតពីល្បឿន និងវិសាលភាព។ គេត្រូវតែយល់អំពីវាក្នុងន័យការអភិវឌ្ឍមនុស្សទូលំទូលាយ ថាវាជារឿងរ៉ាវអំពីការពង្រីកយ៉ាងសម្បើមនូវលទ្ធភាពបុគ្គល និងជាដំណើរនិរន្តនៃវឌ្ឍនភាពអភិវឌ្ឍន៍មនុស្ស នៅក្នុងបណ្តាប្រទេស ដែលជាកន្លែងមានប្រជាជនភាគច្រើនបំផុតនៃពិភពលោកកំពុងរស់នៅ។ នៅពេលប្រទេសរាប់សិប និងប្រជាជនជាច្រើនពាន់លាននាក់ឈានឡើងកាន់តែខ្ពស់ ក្នុងលំដាប់នៃការអភិវឌ្ឍ ដូចដែលកើតមាននាបច្ចុប្បន្ននេះ ពួកគេធ្វើឲ្យមានឥទ្ធិពលដោយផ្ទាល់ មកលើការបង្កើតសម្បត្តិ និងវឌ្ឍនភាពធំទូលាយនៃការអភិវឌ្ឍមនុស្សនៅក្នុងប្រទេស និងតំបន់ទាំងអស់ក្នុងពិភពលោក។ ក្នុងន័យនេះ ឱកាសថ្មីៗកំពុងកើតមានសម្រាប់ប្រទេសមិនសូវអភិវឌ្ឍន៍ប្រឹងប្រែង ដើរឲ្យទាន់គេ និងសម្រាប់ធ្វើកិច្ចផ្តួចផ្តើមខាងគោល-នយោបាយច្នៃប្រឌិត ដែលអាចជាប្រយោជន៍ដល់ប្រទេសដែលជឿនលឿនបំផុតផងដែរ។

ទោះបីប្រទេស កំពុងអភិវឌ្ឍន៍ភាគច្រើនសម្រេចបានផលអភិវឌ្ឍន៍ល្អក៏ដោយ ក្នុងចំណោមនោះមួយចំនួនធំមានការលូតលាស់ ប្រសើរមែន-ទែន ដែលអាចហៅបានថា "ការឈានឡើងនៃ

រូបទី ១

**នៅរវាងឆ្នាំ ១៩៩០ និង ២០១២ ប្រទេសច្រើនជាង ៤០ នៅភូមិភាគខាងត្បូង មានកំណើនតួលេខ HDI ធំជាងយ៉ាងច្រើនធៀបនឹងតួលេខ HDI ដែលបានព្យាករណ៍សម្រាប់ប្រទេសទាំងនោះ នៅឆ្នាំ ១៩៩០**




**សំគាល់ ៖** បណ្តាប្រទេសនៅភាគខាងលើនៃខ្សែបន្ទាត់ ៤៥ អង្សានេះ មានតួលេខ HDI ខ្ពស់ជាងតួលេខនៅឆ្នាំ១៩៩០។ ពណ៌ប្រផេះ និងពណ៌ខ្មៅ តំណាងឲ្យប្រទេសដែលមានតួលេខ HDI ខ្ពស់ជាងជាខ្លាំងនៅរវាងឆ្នាំ ១៩៩០ និង ២០១២ ធៀបនឹងតួលេខ HDI នៃប្រទេសទាំងនោះ នៅក្នុងឆ្នាំ ១៩៩០។ ប្រទេសទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណបែបនេះ ដោយផ្អែកលើតួលេខដែលទទួលបានពីការវិភាគតាមរូបមន្ត regression អំពីការប្រែប្រួលនៃតួលេខ HDI រវាងឆ្នាំ ២០១២ និង១៩៩០ ធៀបនឹងតួលេខ HDI នៅក្នុងឆ្នាំ១៩៩០។ ប្រទេសដែលមានសរសេរឈ្មោះ គឺជាក្រុមប្រទេសដែលមានកំណើន HDI យ៉ាងឆាប់រហ័ស ដូចដែលមានពិភាក្សាពិស្តារបន្ថែមទៀតនៅក្នុងជំពូកទី ៣។

**ប្រភព ៖** ការគណនារបស់ HDRO

ភូមិភាគខាងត្បូង"។ ប្រទេសធំៗជាងគេខ្លះបានធ្វើឲ្យមានការលូតលាស់យ៉ាងឆាប់រហ័ស ជាពិសេស ប្រេស៊ីល ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ិចស៊ិក អាហ្វ្រិកខាងត្បូង និងទួរគី។ ប៉ុន្តែក៏មានវឌ្ឍនភាពក្រាស់ក្រែលផងដែរ ក្នុងបណ្តាសេដ្ឋកិច្ចតូចជាងនោះ ដូចជា បង់ក្លាដែស ស៊ីលី ហ្គាណា ម៉ូរីទ្យូស រ្វ៉ាន់ដា ថៃ និងទុយនេស៊ី (រូបទី ១)។

នៅពេលដែលវាផ្តោតជាសំខាន់ លើការឈានឡើងនៃភូមិភាគខាងត្បូង និងផលបច្ច័យទៅលើការអភិវឌ្ឍមនុស្ស របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣ ក៏និយាយផងដែរ អំពីពិភព-លោកកំពុងមានការប្រែប្រួល ដោយសារមួយផ្នែកធំ ឥទ្ធិពលនៃការឈានឡើងនៃភូមិភាគខាងត្បូង។ របាយការណ៍នេះ ពិនិត្យមើលវឌ្ឍនភាពកន្លងមក ការប្រឈមដែលកំពុងលេចឡើង (ការប្រឈមខ្លះជាលទ្ធផលនៃជោគជ័យទាំងនេះ) និងឱកាសដែលស្តែងចេញសម្រាប់អភិបាលកិច្ចនៅកម្រិតពិភពលោក និងតំបន់។

ភូមិភាគខាងត្បូង កំពុងឈានឡើងទៅនៅទន្ទឹមនឹងភូមិភាគខាងជើង ក្នុងនាមជាប្រភពនៃភាពច្នៃប្រឌិតខាងបច្ចេកទេស និងសហគ្រិនភាព

នេះ គឺជាលើកដំបូងក្នុងរយៈពេល ១៥០ ឆ្នាំចុងក្រោយនេះ ដែលទិន្នផលសរុបនៃសេដ្ឋកិច្ចនាំមុខគេចំនួនបី នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ពោលគឺ ប្រេស៊ីល ចិន និងឥណ្ឌា មានប្រហែលគ្នានឹង GDP រួមគ្នានៃបណ្តាប្រទេសនៅភូមិភាគខាងជើងដែលជាប្រពៃណី ជាមហាអំណាចឧស្សាហកម្ម ពោលគឺ កាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ តួលេខនេះ តំណាងឲ្យកិច្ចស្តារតុល្យភាពឡើងវិញក្នុងអំណាចសេដ្ឋកិច្ចពិភពលោក។ នៅឆ្នាំ១៩៥០ ប្រទេសប្រេស៊ីល ចិន និងឥណ្ឌា រួមគ្នា តំណាងឲ្យត្រឹមតែ ១០% នៃសេដ្ឋកិច្ចពិភពលោកតែប៉ុណ្ណោះ ចំណែកប្រទេសចំនួន ៦ នៅភូមិភាគខាងជើងដែលជាប្រពៃណី ជាសេដ្ឋកិច្ចនាំមុខគេ មានច្រើនជាងពាក់កណ្តាល នៃសេដ្ឋកិច្ចពិភពលោក។ យោងតាមការធ្វើនិទស្សន៍ សម្រាប់របាយការណ៍នេះ រហូតដល់ឆ្នាំ ២០៥០ ប្រទេសប្រេស៊ីល ចិន និងឥណ្ឌា រួមគ្នានឹងមានរហូតដល់ ៤០% នៃទិន្នផលសរុបលើពិភពលោក (រូបទី ២) ដែលជាតួលេខខ្ពស់ជាងខ្លាំងណាស់ ធៀបនឹងតួលេខនិទស្សន៍អំពីទិន្នផលសរុបរួមគ្នានៃក្រុមប្លុក ៧ (មានសហរដ្ឋអាមេរិក ជប៉ុន អាល្លឺម៉ង់ បារាំង ចក្រភពអង់គ្លេស អ៊ីតាលី និងកាណាដា) ក្នុងពេលបច្ចុប្បន្ននេះ។

គ្រួសារវណ្ណៈកណ្តាលនៅបណ្តាប្រទេស ក្នុងភូមិភាគខាងត្បូង មានកំណើនយ៉ាងឆាប់រហ័ស ទាំងចំនួនប្រាក់ចំណូលនិងការរំពឹងទុក (រូបទី៣)។ គ្រាន់តែចំនួនច្រើនសន្ធឹកសន្ធាប់ នៃប្រជាជននៅភូមិភាគខាងត្បូង ពោលគឺ អ្នកប្រើប្រាស់ និងពលរដ្ឋរាប់ពាន់លាននាក់ អាចនាំឲ្យមានបច្ច័យកិច្ចអភិវឌ្ឍន៍មនុស្សជាសកល ច្រើនបែបយ៉ាងសម្រាប់បណ្តារដ្ឋាភិបាល ក្រុមហ៊ុន និងស្ថាប័នអន្តរជាតិនៅភូមិភាគខាងត្បូង យកទៅធ្វើចំណាត់ការ។ បច្ចុប្បន្ននេះ ភូមិភាគខាងត្បូងកំពុងឈានឡើង ទន្ទឹមនឹងភូមិភាគខាងជើង ក្នុងនាមជាប្រភពនៃភាពច្នៃប្រឌិតខាងបច្ចេកទេស និងសហគ្រិន-ភាព។ នៅក្នុងពាណិជ្ជកម្មជើង-ត្បូង សេដ្ឋកិច្ចឧស្សាហកម្មដែលកើតឡើងថ្មី បានកសាងសមត្ថភាព ក្នុងការបង្កើតផលិតផលទំនើបៗយ៉ាងមានប្រសិទ្ធភាព សម្រាប់ទីផ្សារក្នុងប្រទេសជឿនលឿន។ ប៉ុន្តែ អន្តរកម្មត្បូង-ត្បូង បានជួយឲ្យក្រុមហ៊ុននានានៅក្នុងភូមិភាគខាងត្បូង កែសម្រួល និងច្នៃប្រឌិតផលិតផល និងដំណើរការនានា ដែលឆ្លើយតបបានយ៉ាងសមស្របទៅនឹងតម្រូវការនៅក្នុងមូលដ្ឋាន។

## ស្ថានភាពការអភិវឌ្ឍមនុស្ស

សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) នៅឆ្នាំ ២០១២ បានលាតត្រដាងឲ្យឃើញនូវវឌ្ឍនភាពយ៉ាងច្រើន។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ប្រទេសនានាទូទាំងពិភពលោកបានបោះជំហានឡើងឆ្ពោះទៅរកកម្រិតខ្ពស់ នៃការអភិវឌ្ឍមនុស្ស។ ជំហាននៃវឌ្ឍនភាព HDI មានល្បឿនខ្ពស់បំផុតនៅក្នុងក្រុមប្រទេស ដែលតួលេខនៃការអភិវឌ្ឍមនុស្សមានកម្រិតទាប និងកណ្តាល។ នេះជាដំណឹងល្អ។ ប៉ុន្តែ វឌ្ឍនភាពបែបនេះទាមទារឲ្យមានកំណែលម្អមិនត្រឹមតែតួលេខមធ្យមនៃ HDI នោះទេ។ វាមិនមែនជាអ្វី ដែលគួរប្រាថ្នាចង់បាន ឬដែលមាននិរន្តរភាពឡើយ ប្រសិនបើកំណើនតួលេខ HDI កើតមានស្របគ្នានឹងកំណើននៃវិសមភាពប្រាក់ចំណូល ការប្រើប្រាស់គ្មាននិរន្តរភាព ការចំណាយខ្ពស់សម្រាប់វិស័យយោធា និងកម្រិតទាបនៃភាពចុះសម្រុងគ្នាក្នុងសង្គម (សូមអានប្រអប់ ១)។

រូបទី ២

**ដល់ឆ្នាំ ២០៥០ ប្រេស៊ីល ចិន និងឥណ្ឌារួមគ្នាត្រូវបាននិទស្សន៍ថា មានដល់ ៤០% នៃទិន្នផលសរុបពិភពលោក ជាកំណើនពី ១០% នៅឆ្នាំ ១៩៥០**




**សំគាល់ ៖** ផលិតផលសរុបត្រូវបានវាស់ជាអំណាចទិញនៃប្រាក់ដុល្លារនៅឆ្នាំ ១៩៩០។

**ប្រភព ៖** ការធ្វើអាំងទែរប៉ូឡាស្យុង ( interpolation ) របស់ HDRO នូវតួលេខដែលមានកន្លងមកដែលបានពី Maddison (2010) និងតួលេខនិទស្សន៍ដែលបានពី Pardee Center for International Futures (2013).

ផ្នែកសំខាន់មួយនៃការអភិវឌ្ឍមនុស្ស គឺសមធម៌។ បុគ្គលគ្រប់រូបមានសិទ្ធិរស់ក្នុងជីវភាពមួយគ្រប់គ្រាន់ទៅតាមគុណតម្លៃ និងការប៉ងប្រាថ្នារបស់ពួកគេរៀងៗខ្លួន។ គ្មានអ្នកណាម្នាក់ គួរមានអាយុខ្លី ឬរស់ក្នុងភាពទុគ៌តឡើយ ដោយសារតែកើតក្នុងត្រកូល "មិនខ្ពង់ខ្ពស់" ឬប្រទេស "ក្រីក្រ" ឬក្រុមជនជាតិ ឬពូជសាសន៍ "ភាគតិច" ឬភេទ "ទន់ខ្សោយ"។ វិសមភាពពន្លឺតជំហានការអភិវឌ្ឍមនុស្ស ហើយក្នុងករណីខ្លះ អាចរារាំងការអភិវឌ្ឍមនុស្សទាំងស្រុងតែម្តង។ នៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ពិភពលោកបានឃើញការកាត់បន្ថយយ៉ាងច្រើន នូវវិសមភាពខាងសុខភាព និងការអប់រំ ជាងវិសមភាពខាងប្រាក់ចំណូល (រូបទី ៤)។ ជារួម ការសិក្សាទាំងអស់ឯកភាពថា វិសមភាពខាងប្រាក់ចំណូលមានកម្រិតខ្ពស់ណាស់ បើទោះជាគ្មានការឯកភាពគ្នា អំពីនិន្នាការនៅក្នុងពេលថ្មីៗនេះក៏ដោយ។

## ភូមិភាគខាងត្បូងដែលមានលក្ខណៈសកលជាងមុន

ផលិតកម្មក្នុងពិភពលោក កំពុងតែកែប្រែតុល្យភាពតាមទម្រង់ ដែលពុំធ្លាប់មានក្នុងរយៈពេល ១៥០ ឆ្នាំចុងក្រោយនេះ។ លំហូរឆ្លងដែននៃទំនិញ សេវាកម្ម ប្រជាជន និងគំនិត មានកំណើនគួរឲ្យកត់សំគាល់។ រហូតដល់ឆ្នាំ ២០១១ ពាណិជ្ជកម្មមានរហូតដល់ជិត៦០%នៃផលិតផលសរុបលើពិភពលោក។ ប្រទេសកំពុងអភិវឌ្ឍន៍បានដើរតួយ៉ាងធំនៅក្នុងតួលេខនេះ (ប្រអប់ ២)៖ រវាងឆ្នាំ១៩៨០និង២០១០ប្រទេសកំពុងអភិវឌ្ឍន៍បានបង្កើនភាគចំណែកនៃទំនិញរបស់ខ្លួន នៅក្នុងពាណិជ្ជកម្មពិភពលោកពី ២៥% ដល់ ៤៧% ហើយភាគចំណែកនៃផលចំណូល របស់ប្រទេសទាំងនេះលើពិភពលោកបានកើនពី ៣៣% ដល់ ៤៥%។ តំបន់កំពុងអភិវឌ្ឍន៍ ក៏បាន និងកំពុង

រូបទី ៣

**ចំនួនប្រជាជនវណ្ណៈកណ្តាលនៅភូមិភាគខាងត្បូង ត្រូវបាននិទស្សន៍ថានឹងបន្តកើន**




**សំគាល់ ៖** ប្រជាជនវណ្ណៈកណ្តាលរួមមាន អ្នកដែលមានប្រាក់ចំណូល ឬចំណាយ ១០-១០០ ដុល្លារ/ថ្ងៃ (សមមូលអំណាចទិញ ឆ្នាំ ២០០៥)។

**ប្រភព ៖** Brookings Institution 2012.

ពង្រឹងចំណងទាក់ទងរវាងគ្នាផងដែរ ៖ រវាងឆ្នាំ ១៩៨០ និង ២០១០ ពាណិជ្ជកម្មត្បូង-ត្បូង គិតជាភាគចំណែក នៃទំនិញនៅក្នុងពាណិជ្ជកម្មលើពិភពលោកបានកើនឡើងពី៨,១%ដល់២៦,៧% (រូបទី ៥)។

ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ នៅពុំទាន់ចូលរួមក្នុងដំណើរឈានឡើងនៃភូមិភាគខាងត្បូង បានពេញលេញនៅឡើយទេ

ដំណើរឈានឡើងនៃភូមិភាគខាងត្បូង មិនទាន់មានលក្ខណៈឯកសណ្ឋាននៅឡើយទេ នៅទូទាំងប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែង នៅក្នុងចំណោមប្រទេសអភិវឌ្ឍន៍តិចតួចចំនួន ៤៨ ជាពិសេសបណ្តាប្រទេសដែលពុំជាប់នឹងសមុទ្រ ឬដែលស្ថិតនៅឆ្ងាយពីទីផ្សារពិភពលោក ដំហាននៃការប្រែប្រួលមានសភាពយឺតជាង។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងនេះជាច្រើនបានចាប់ផ្តើមទទួលផលពីពាណិជ្ជកម្ម ការវិនិយោគហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យាត្បូង-ត្បូង។ ឧទាហរណ៍ គេឃើញមានបន្សាយឥទ្ធិពលជាវិជ្ជមានពីប្រទេសចិន មកលើប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ជាពិសេស ដៃគូពាណិជ្ជកម្មជិតស្និទ្ធ។ ផលប្រយោជន៍ទាំងនេះ អាចជួយទូទាត់បានមួយកម្រិតជាមួយការធ្លាក់ចុះ នៃតម្រូវការក្នុងប្រទេសជឿនលឿន។ កំណើននៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ត្រូវបានប៉ាន់ស្មានថា អាចមានត្រឹមរវាង០,៣-១,១ភាគរយដែលទាបជាងនៅក្នុងឆ្នាំ ២០០៧-២០១០ ប្រសិនបើកំណើននៅក្នុងប្រទេសចិន និងឥណ្ឌា មានការថយចុះតាមអត្រាដូចគ្នានឹងការថយចុះនៅក្នុងប្រទេសជឿនលឿន។

ប្រទេសជាច្រើន បានទទួលផលពីបន្សាយឥទ្ធិពលនៅក្នុងវិស័យនានា ដែលរួមចំណែកក្នុងការអភិវឌ្ឍមនុស្ស ជាពិសេស វិស័យសុខភាព។ ឧទាហរណ៍ ក្រុមហ៊ុនឥណ្ឌាផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យ និងផលិតផល និងសេវាព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍ តាមថ្លៃដែលអាចជាវបានដល់ប្រទេសនានានៅអាហ្វ្រិក។ ក្រុមហ៊ុនប្រេស៊ីល និងអាហ្វ្រិកខាងត្បូង ក៏កំពុងធ្វើដូចគ្នានេះដែរ នៅក្នុងទីផ្សារនៅក្នុងតំបន់របស់ខ្លួន។

ទោះជាយ៉ាងណាក៏ដោយ ការនាំចេញពីប្រទេសធំៗ ក៏អាចនាំមកនូវផលអវិជ្ជមានផងដែរ។ ប្រទេសធំៗបង្កើតឲ្យមានសម្ពាធ នៃការប្រកួត-ប្រជែងនៅក្នុងប្រទេសតូចៗជាង ដែលអាចរារាំងពិពិធកម្ម និងឧស្សាហូបនីយកម្មសេដ្ឋកិច្ច។ ប៉ុន្តែមានករណីដែលកម្លាំងនៃការប្រកួតប្រជែង បាននាំឲ្យឧស្សាហកម្មមួយចំនួន បន្តដំណើរការយ៉ាងរឹងមាំផងដែរ។ តួនាទីនៃភាពប្រកួតប្រជែងបច្ចុប្បន្ននេះ អាចងាយនឹងបម្លែងទៅជាតួនាទីបំពេញបន្ថែមទៅអនាគត។ ការឈានចេញពីភាពប្រកួតប្រជែងទៅរកកិច្ចសហការ ទំនងជាអាស្រ័យលើគោល-នយោបាយនានា ដើម្បីទប់ទល់នឹងការប្រឈមថ្មីៗផងដែរ។

## កត្តាជំរុញឲ្យមានវិបល្លាសការអភិវឌ្ឍ

ប្រទេសជាច្រើន មានវឌ្ឍនភាពក្រាស់ក្រែលដែរ នៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ហើយទន្ទឹមនឹងនោះ ការឈានឡើងនៃភូមិភាគខាងត្បូងមានភាពទូលំទូលាយបង្គួរដែរ។ ប្រទេសមួយចំនួនដែលសម្រេចសមិទ្ធផលទាំងនេះ មិនគ្រាន់តែកើនបានប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រេចបានប្រសើរ ខ្ពស់ជាងកម្រិតមធ្យមលើសូចនាករសង្គម ដូចជា សុខភាព និងការអប់រំ (រូបទី ៦) ទៀតផង។

## តើជីវិតជាមនុស្សមានន័យដូចម្ដេចខ្លះ ?

ជិតកន្លះសតវត្សរ៍កន្លងទៅ ទស្សនវិទូ Thomas Nagel បានចេញផ្សាយឯកសារល្បីល្បាញមួយ ដែលមានចំណងជើងថា "តើជីវិតជាសត្វប្រចៀវមានន័យដូចម្ដេចខ្លះ ?" សំណួរដែលខ្ញុំចង់លើកឡើង គឺតើជីវិតជាមនុស្សមានន័យដូចម្ដេចខ្លះ ? ដូចយើងបានឃើញស្រាប់អត្ថបទទស្សនទានស៊ីជម្រៅរបស់ Tom Nagel នៅក្នុងទស្សនាវដ្ដី The Philosophical Review ក៏អធិប្បាយផងដែរអំពីមនុស្ស និងត្រឹមតិចតួចប៉ុណ្ណោះអំពីប្រចៀវ។ ក្នុងចំណោមចំណុចដទៃទៀត លោក Nagel សំដែងការមិនឯកភាពទាំងស្រុងចំពោះការប៉ុនប៉ងរបស់អ្នកវិទ្យាសាស្ត្រសង្កេត ក្នុងការកំណត់អត្តសញ្ញាណបទពិសោធន៍នៃស្ថានភាពជាសត្វប្រចៀវ ឬស្រដៀងគ្នានេះដែរ គឺស្ថានភាពជាមនុស្ស ដែលពាក់ព័ន្ធជាមួយបាតុភូតរូបនៅក្នុងខួរក្បាល និងនៅក្នុងរាងកាយ ដែលអ្នកក្រៅងាយស្រួលសង្កេត។ វិញ្ញាណប្រចៀវ ឬមនុស្សស្ទើរតែមិនអាចមើលឃើញ ដោយសារមានត្រឹមតែការកន្ត្រាក់សាច់ដុំក្នុងខួរក្បាល និងនៃដងខ្លួន។ ភាពស្មុគស្មាញនៃការកន្ត្រាក់ក្នុងខួរក្បាល មិនអាចកើតឡើងបាន ដោយសារតែការកន្ត្រាក់ងាយៗនៃរាងកាយនោះទេ (ទោះជាយ៉ាងណាក៏ដោយ អាចមានការប៉ុនប៉ងបង្កើតឲ្យមានបែបនេះ)។

កម្រិតខ្ពស់បំផុតនៃវិធានអភិវឌ្ឍន៍មនុស្សក៏ផ្ដែកលើភាពខុសគ្នាមួយផងដែរ ប៉ុន្តែជាភាពខុសគ្នាបែបផ្សេងមួយ ធៀបនឹងមូលដ្ឋានការបង្ហាញឲ្យឃើញនៅក្នុងទស្សនវិជ្ជាអំពីចំណេះដឹងរបស់ Nagel។ តាមរយៈរបាយការណ៍អភិវឌ្ឍន៍មនុស្សជាបន្តបន្ទាប់ ដែលបានចាប់ផ្ដើមនៅក្នុងឆ្នាំ ១៩៩០ Mahbub-ul-Haq បានបង្ហាញអំពីការលំបាកក្នុងការប៉ាន់ប្រមាណ រវាងភាពសំបូរបែបនៃរបៀបរស់នៅរបស់មនុស្ស ដែលរួមទាំងហេតុផលដែលមនុស្សឲ្យតម្លៃលើសេរីភាពជាមួយកិច្ចការងាយៗជាងនេះ នៃការកត់ត្រាប្រាក់ចំណូល និងធនធានផ្សេងទៀតពីខាងក្រៅរបស់បុគ្គល ឬប្រទេសនានា។ គេងាយសង្កេតឃើញ និងងាយវាស់ផលទុនក្នុងស្រុកសរុប (GDP) ជាងការវាស់គុណភាពនៃការរស់នៅរបស់ប្រជាជន។ ប៉ុន្តែ សុខុមាលភាព និងសេរីភាពរបស់មនុស្ស និងការជាប់ទាក់ទងជាមួយភាពត្រឹមត្រូវ និងយុត្តិធម៌នៅក្នុងពិភពលោក មិនអាចបកស្រាយបាន ត្រឹមតែតាមរយៈរង្វាស់ GDP និងអត្រាកំណើន GDP ឡើយ ទោះបីមនុស្សជាច្រើនប៉ុនប៉ងធ្វើបែបនេះក៏ដោយ។

ភាពស្មុគស្មាញនៃការអភិវឌ្ឍមនុស្ស មានសារៈសំខាន់ចាំបាច់ត្រូវមានការទទួលស្គាល់មួយផ្នែក គឺដោយសារយើងមិនគួរគិតអំពីការប្ដូរសំណួរ ៖ ការផ្ដួចផ្ដើមដ៏ក្លាហានរបស់ Mahbub-ul-Haq ដើម្បីបំពេញបន្ថែម និងក្នុងករណីខ្លះ ផ្ដល់នូវវត្ថុជំនួសរង្វាស់ GDP គឺជាចំណុចស្នូលដ៏មានសារៈសំខាន់នេះឡើយ។ ប៉ុន្តែ ស្របជាមួយអំណះអំណាងនេះ មានចំណុចកាន់តែលំបាកមួយ ដែលក៏ជាផ្នែកមិនអាចជៀសវាងបានផងដែរ នៃអ្វីដែលត្រូវបានហៅថា "វិធានអភិវឌ្ឍន៍មនុស្ស។" ដើម្បីឲ្យមានភាពងាយស្រួល យើងអាចប្រើប្រាស់សូចនាករងាយៗជាច្រើនអំពីការអភិវឌ្ឍមនុស្ស ដូចជា HDI ដោយផ្អែកលើអថេរតែបី ដោយមានមេគុណងាយៗសម្រាប់អថេរនីមួយៗ។ ប៉ុន្តែការចង់បាននេះមិនចប់ត្រឹមនេះទេ។ យើងមិនគួរច្រានចោលផ្លូវកាត់ដែលអាចប្រើការបាន និងដែលមានប្រយោជន៍នោះឡើយ ពោលគឺ HDI អាចប្រាប់យើងបានច្រើនអំពីគុណភាពនៃការរស់នៅ ជាងអ្វីដែល GDPអាចផ្ដល់ឲ្យ-ប៉ុន្តែយើងក៏មិនគួរពេញចិត្តទាំងស្រុងតែជាមួយកំណើនដែលស្រង់យកបានភ្លាមៗនៅក្នុងផ្លូវកាត់ទាំងនេះ នៅក្នុងដំណើរការនៃការងារដែលមានជាបន្តនោះឡើយ។ ការប៉ាន់ប្រមាណអំពីគុណភាពនៃការរស់នៅ គឺជាលំហាត់ស្មុគស្មាញមួយជាងអ្វី ដែលអាចស្រង់យកបានតាមរយៈតួលេខតែមួយទៅទៀត បើទោះជាការជ្រើសរើសយកអថេរនានាសម្រាប់បញ្ចូលបន្ថែម និងការជ្រើសយកនីតិវិធីមេគុណ បានធ្វើឡើងហ្មត់ចត់កម្រិតណាក៏ដោយ។

ការទទួលស្គាល់អំពីភាពស្មុគស្មាញ ក៏មានការពាក់ព័ន្ធដទៃទៀតផងដែរ។ តួនាទីយ៉ាងសំខាន់នៃការយល់ឃើញរបស់សាធារណជន ដែលជាការយកចិត្តទុកដាក់នៃរបាយការណ៍អភិវឌ្ឍន៍មនុស្សមួយផ្នែក បានកើតចេញពីការទទួលស្គាល់នូវភាពស្មុគស្មាញនេះ។ មានតែអ្នកពាក់ប៉ុណ្ណោះទើបដឹងថាស្បែកជើងចង្អៀត ប៉ុន្តែការចាត់ចែងដើម្បីជៀសវាងភាពចង្អៀតនេះ មិនអាចធ្វើបានប្រកបដោយប្រសិទ្ធភាពឡើយ បើគ្មានការផ្ដល់ឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការសំដែងមតិ និងមិនផ្ដល់ឲ្យពួកគេនូវឱកាសយ៉ាងច្រើនសម្រាប់ការពិភាក្សាជាសាធារណៈ។ សារៈសំខាន់នៃធាតុផ្សំខុសៗគ្នានៅក្នុងការវាយតម្លៃសុខុមាលភាព និងសេរីភាពរបស់ប្រជាជន អាចទទួលស្គាល់ និងប៉ាន់ប្រមាណបានគ្រប់គ្រាន់ តែតាមរយៈការពិភាក្សាគ្មានឈប់ឈរក្នុងចំណោមប្រជាពលរដ្ឋ ដោយមានឥទ្ធិពលមកលើការកសាងគោលនយោបាយសាធារណៈប៉ុណ្ណោះ។ សារៈសំខាន់ខាងនយោបាយនៃកិច្ចផ្ដួចផ្ដើមបែបនេះ ដែលត្រូវបានឲ្យឈ្មោះថា "និទាឃរដូវនៅអារ៉ាប់ និងចលនាមហាជននៅកន្លែងដទៃទៀតលើពិភពលោក មានភាពស្របគ្នាជាមួយសារៈសំខាន់នៃចំណេះដឹងរបស់ប្រជាជន ដែលសំដែងទស្សនៈរបស់ខ្លួននៅក្នុងការពិភាក្សាជាមួយអ្នកដទៃ អំពីការលំបាកដែលពួកគាត់ជួបប្រឈម និងថាតើពួកគាត់ចង់កំចាត់ចោលអ្វីខ្លះ ដែលជាភាពអយុត្តិធម៌។ មានបញ្ហាជាច្រើនដែលត្រូវពិភាក្សាជាមួយគ្នាទៅវិញទៅមក និងជាមួយមន្ត្រីសាធារណៈ ដែលជាអ្នកកសាងគោលនយោបាយ។

ការសន្ទនាប្រកបដោយការទទួលខុសត្រូវ នៅពេលមានការទទួលស្គាល់បានសមស្របនៅគ្រប់លំដាប់ថ្នាក់នៃអភិបាលកិច្ច ក៏ត្រូវតែរាប់បញ្ចូលតំណាងផលប្រយោជន៍របស់ពលរដ្ឋ ដែលពុំមានវត្តមាននៅទីនោះ ដើម្បីសំដែងកង្វល់របស់ពួកគេទៅតាមភាសារបស់ពួកគេផងដែរ។ ការអភិវឌ្ឍមនុស្ស មិនអាចមិនយកចិត្តទុកដាក់អំពីមនុស្សជំនាន់ក្រោយៗទៅអនាគតដោយសារតែពួកគេគ្មានវត្តមាននៅទីនោះឡើយ។ ប៉ុន្តែមនុស្សពិតជាមានសមត្ថភាពក្នុងការគិតគូរអំពីអ្នកដទៃ អាយុជីវិតរបស់អ្នកទាំងនោះ ហើយសិល្បៈនៃនយោបាយប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព គឺត្រូវពង្រីកការសន្ទនាពីការយកចិត្តទុកដាក់តែអំពីរឿងផ្ទាល់ខ្លួន ទៅរកការស្វែងយល់អំពីសង្គមធំទូលាយ អំពីសារៈសំខាន់នៃតម្រូវការចាំបាច់ និងសេរីភាពរបស់ប្រជាពលរដ្ឋទៅអនាគត ក៏ដូចជាក្នុងបច្ចុប្បន្នផងដែរ។ កិច្ចការនេះមិនមែនគ្រាន់តែជាការរួមបញ្ចូលកង្វល់ទាំងនោះ នៅក្នុងសូចនាករតែមួយនោះឡើយ ដូចជា តាមរយៈការបន្ថែមទៅក្នុង HDI ដែលមានបន្ទុកធ្ងន់ធ្ងររួចមកហើយ (ដែលនៅក្នុងករណីខ្លះតំណាងឲ្យត្រឹមតែសុខុមាលភាព និងសេរីភាពសម្រាប់បច្ចុប្បន្នតែប៉ុណ្ណោះ) - ប៉ុន្តែ តាមពិតវាជាកិច្ចការដែល

ត្រូវធ្វើឲ្យប្រាកដថា ការពិភាក្សានានាអំពីការអភិវឌ្ឍមនុស្ស រួមបញ្ចូលកង្វល់ដទៃផងដែរ។ របាយការណ៍អភិវឌ្ឍន៍មនុស្ស អាចបន្ថែមចំណែកទៅក្នុងការពង្រីកបែបនេះតាមរយៈការបំភ្លឺ ក៏ដូចជាការបង្ហាញជូនព័ត៌មានពាក់ព័ន្ធផងដែរ។

វិធានអភិវឌ្ឍន៍មនុស្ស គឺជាជំហានចម្បងមួយទៅមុខនៅក្នុងលំហាត់លំបាកៗនៃការស្វែងយល់អំពីជោគជ័យ និងការបាត់បង់នៅក្នុងការរស់នៅរបស់មនុស្ស និងក្នុងការទទួលស្គាល់អំពីសារៈសំខាន់នៃការឆ្លុះបញ្ចាំង និងការសន្ទនា និងតាមរយៈប្រការទាំងនោះ ត្រូវឈានទៅបង្កើតពិភពលោកមួយដែលមានភាពត្រឹមត្រូវ និងយុត្តិធម៌ជាងមុន។ យើងអាចដូចជាសត្វប្រចៀវ ដោយហេតុថាមិនបានត្រៀមខ្លួនជាស្រេច ក្នុងការទទួលបានការយកចិត្តទុកដាក់នៅក្នុងរង្វាស់របស់អ្នកវិទ្យាសាស្ត្រសង្កេត ដែលគ្មានការអត់ធ្មត់ ប៉ុន្តែយើងក៏មានសមត្ថភាពគិតគូរ និងជជែកអំពីជ្រុងជាច្រើននៃការរស់នៅរបស់យើង និងរបស់អ្នកដទៃផងដែរ ទាំងសម្រាប់បច្ចុប្បន្ន និងអនាគតតាមវិធីនានា ដែលអាចនៅមិនទាន់សមស្របសម្រាប់សត្វប្រចៀវនៅឡើយទេ។ មនុស្សស្ថិតក្នុងសភាពដូចសត្វប្រចៀវផង និងមិនដូចសត្វប្រចៀវផងដែរ។

រូបទី ៤

**តំបន់ភាគច្រើនបង្ហាញអំពីកំណើនវិសមភាពខាងប្រាក់ចំណូល និងការថយចុះនៃវិសមភាពខាងសុខភាព និងការអប់រំ**




**សំគាល់ ៖** ផ្អែកតាមការគណនាអំពីតុល្យភាពនៃប្រជាពលរដ្ឋក្នុងប្រទេសចំនួន ១៨២ អំពីការបាត់បង់ ដោយសារតែវិសមភាពខាងសុខភាព, ១៤៤ ប្រទេស អំពីការបាត់បង់ដោយសារតែវិសមភាពខាងការអប់រំ និង ៦៦ ប្រទេស អំពីការបាត់បង់ដោយសារតែវិសមភាពខាងប្រាក់ចំណូល។ ទិន្នន័យ ស្តីពីវិសមភាពនៃប្រាក់ចំណូលបានមកពី Milanovié (2010) មានរហូតដល់ឆ្នាំ ២០០៥។

**ប្រភព ៖** ការគណនារបស់ HDRO ដោយប្រើប្រាស់ទិន្នន័យសុខភាពមកពីនាយកដ្ឋានសេដ្ឋកិច្ច និងកិច្ចការសង្គមនៃ អ.ស.ប ទិន្នន័យអំពីការអប់រំបានពី Barro and Lee (2010) និងទិន្នន័យអំពីវិសមភាពប្រាក់ចំណូលបានមកពី Milanovié (2010) ។

តើប្រទេសនានា នៅភូមិភាគខាងត្បូងបានបម្លែងទស្សនទាន នៃការអភិវឌ្ឍមនុស្សរបស់ខ្លួនដោយរបៀបណា? នៅក្នុងប្រទេសទាំងនេះភាគច្រើន មានកត្តាបីដែលជំរុញដល់ការអភិវឌ្ឍ៖ ស្ថានភាពការអភិវឌ្ឍបែបសកម្មនិយម ការទាញយកប្រយោជន៍ពីទីផ្សារពិភពលោក និងភាពច្នៃប្រឌិតមុះមុតខាងគោលនយោបាយសង្គម។ កត្តាជំរុញទាំងនេះ មិនមែនបានមកពីគំនិតអរូបីយថាតើការអភិវឌ្ឍ គួរមានដំណើរការបែបណានោះឡើយ ប៉ុន្តែវាបានមកតាមរយៈបទពិសោធន៍នៃវិបល្លាសអភិវឌ្ឍន៍របស់ប្រទេសជាច្រើននៅភូមិភាគខាងត្បូង។ ជាក់ស្តែង ប្រទេសទាំងនោះបានធ្វើការដេញដោលចំពោះវិធាននានា ដែលត្រូវបានគូសវាសគិតទុកជាមុន និងទ្រឹស្តីមួយចំនួន។ ម៉្យាងប្រទេសទាំងនេះ ទុកដោយឡែកនូវឱវាទទ្រឹស្តីមួយចំនួន ដែលមានលក្ខណៈគ្រប់គ្រងប្រមូលផ្តុំ សមូហភាពនិយម តែម៉្យាងវិញទៀតប្រទេសទាំងនោះ មានការយល់ឃើញខុសៗគ្នាអំពីសេរីភាវូបនីយកម្ម ដែលគ្មានការត្រួតត្រាដែលអនុម័តដោយ Washington Consensus ។

## កត្តាជំរុញទី ១ ៖ ស្ថានភាពការអភិវឌ្ឍបែបសកម្មនិយម

រដ្ឋដែលមានជំហររឹងមាំ មានការទទួលខុសត្រូវ និងគិតគូរជាមុន កសាងគោលនយោបាយទាំងសម្រាប់វិស័យសាធារណៈ និងវិស័យឯកជនដោយផ្តោតលើចក្ខុវិស័យរយៈពេលវែង និងការដឹកនាំនិយាម និងគុណតម្លៃរួម និងគោលការណ៍និងស្ថាប័នដែលកសាងទំនុកចិត្ត និងភាពចុះសម្រុងគ្នា។ ដើម្បីសម្រេចឲ្យបានវិបល្លាសយូរអង្វែង ទាមទារឲ្យប្រទេសនានាកំណត់យកវិធានដែលមានសង្គតិភាព និងតុល្យភាពសម្រាប់ការអភិវឌ្ឍ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសនានាដែលបានទទួលជោគជ័យ ក្នុងការផ្តួចផ្តើមឲ្យមាននិរន្តរភាពនៃកំណើនប្រាក់ចំណូល និងការអភិវឌ្ឍមិនមែនអនុវត្តរូបមន្តងាយតែមួយនោះទេ។ ចំពោះមុខនឹងការប្រឈមជាច្រើន ប្រទេសទាំងនោះបានប្រកាន់យកគោលការណ៍ខុសៗគ្នា ខាងទីផ្សារ, ជំរុញការនាំចេញ, ការអភិវឌ្ឍឧស្សាហកម្ម និងការបន្សាំ និងជំរុញបច្ចេកវិទ្យា។ ប្រជាជនត្រូវតែជាស្នូលនៃអាទិភាពនានា សំដៅលើកកម្ពស់កាលានុវត្តភាព និងការពារប្រជាជនពីហានិភ័យផ្សេងៗ។ រដ្ឋាភិបាលអាចគាំទ្រដល់ឧស្សាហកម្មដែលមិនអាចកើតមាន ដោយសារកម្លាំងទីផ្សារនៅទន់ខ្សោយ។ទោះបីយុទ្ធសាស្រ្តបែបនេះនាំមកនូវហានិភ័យខាងនយោបាយ សម្រាប់ការស្វែងរកផលចំណូលច្រើនហួសហេតុ និងបក្សពួកនិយមក៏ដោយ ក៏វាបានជួយប្រទេសមួយចំនួននៅភូមិ-ភាគខាងត្បូង ក្នុងការប្រែក្លាយឧស្សាហកម្មដែលកាលពីមុនត្រូវបានចាត់ទុកថា គ្មានប្រសិទ្ធភាពឲ្យឈានទៅជាឧស្សាហម្មនាំមុខគេ ក្នុងការជំរុញការនាំចេញ នៅពេលដែលសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះកាន់តែបើកចំហ។

នៅក្នុងសង្គមដ៏ធំ និងដែលស្មុគស្មាញលទ្ធផល ពីគោលនយោបាយជាក់លាក់ណាមួយមិនអាចជៀសវាង ពីភាពមិនប្រាកដប្រជាបានឡើយ។ ស្ថានភាពអភិវឌ្ឍន៍ត្រូវឈរលើភាពប្រាកដនិយមសំអាងហេតុការណ៍ និងធ្វើការសាកល្បងវិធានខុសៗគ្នា។ ចំណុចមួយចំនួនបានលេចធ្លោឡើងដូចជាស្ថានភាពអភិវឌ្ឍន៍ដែលមានប្រជាជនជាស្នូល បានពង្រីកសេវាសង្គមសំខាន់ៗ។ ការវិនិយោគលើសមត្ថភាពរបស់ប្រជាជន - តាមរយៈសេវាសុខភាព ការអប់រំ និងសេវាកម្មសាធារណៈដទៃទៀត-មិនមែនជាសាខានៃដំណើរការកំណើនឡើយ ប៉ុន្តែ គឺជាផ្នែកទាំងស្រុងនៃការអភិវឌ្ឍ (រូបទី ៧ និង៨) តែម្តង។ ការពង្រីកយ៉ាងឆាប់រហ័សនូវការងារមានគុណភាព គឺជាទិដ្ឋភាពសំខាន់មួយ នៃការអភិវឌ្ឍដែលជំរុញការអភិវឌ្ឍមនុស្ស។

## រូបទី ២

### សមាហរណកម្មនៃភូមិភាគខាងត្បូងជាមួយសេដ្ឋកិច្ចពិភពលោក និងការអភិវឌ្ឍមនុស្ស

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ១០៧ ដែលជាសំណាកនៃការសិក្សាក្នុងឆ្នាំ ១៩៩០-២០១០ ប្រទេសប្រមាណ ៨៧% អាចត្រូវចាត់ទុកថាបានធ្វើសមាហរណកម្មទៅក្នុងពិភពលោក ៖ ប្រទេសទាំងនោះបានបង្កើនអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួន មានដៃគូពាណិជ្ជកម្មធំៗជាច្រើន[១] និងរក្សាបាននូវអត្រាខ្ពស់នៃពាណិជ្ជកម្មធៀបនឹងលទ្ធផលក្នុងអត្រាខ្ពស់ជាងប្រទេស ដែលមានកម្រិតប្រាក់ចំណូលប្រហែលគ្នា។[២] ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់នេះ ក៏មានការផ្សារភ្ជាប់ជិតស្និទ្ធយ៉ាងខ្លាំងជាមួយពិភពលោក និងជាមួយគ្នាទៅវិញទៅមកផងដែរ ៖ ការប្រើប្រាស់អ៊ិនធឺណិតបានពង្រីកជាខ្លាំង ដោយមេដ្យានអំពីកំណើនប្រចាំឆ្នាំនៃចំនួនអ្នកប្រើប្រាស់កើនហួស ៣០% រវាងឆ្នាំ ២០០០ និង ២០១០។

ទោះបីមិនមែនគ្រប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានធ្វើសមាហរណកម្មទៅក្នុងពិភពលោក សុទ្ធតែមានការលូតលាស់យ៉ាងឆាប់រហ័សនូវសន្ទស្សន៍ អភិវឌ្ឍន៍មនុស្ស (HDI) ក៏ដោយ អំណះអំណាងប្រាសមកវិញគឺជាការណ៍ពិត។ ប្រទេសកំពុងអភិវឌ្ឍន៍ស្ទើរទាំងអស់ ដែលបានកែលម្អ HDI ភាគច្រើន ធៀបនឹងប្រទេសដទៃប្រហាក់ប្រហែលខ្លួននៅរវាងឆ្នាំ ១៩៩០ និង ២០១២ (យ៉ាងហោចណាស់ប្រទេសចំនួន ៤៥ នៅក្នុងសំណាកនេះ) បានធ្វើសមាហរណកម្មកាន់តែច្រើនឡើងជាមួយសេដ្ឋកិច្ចពិភពលោកនៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ។ កំណើនជាមធ្យមនៃអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផល មានប្រមាណ ១៣% ធំជាងកំណើននៅក្នុងក្រុមប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានការកែលម្អត្រឹមតិចតួចលើ HDI។ ស្ថានភាពនេះ មានភាពស្របគ្នាជាមួយបេកគំហើញពីមុនមកដែលថាប្រទេសនានាទំនងជាមានការបើកចំហជាងមុន នៅពេលប្រទេសទាំងនោះអភិវឌ្ឍន៍កាន់តែខ្លាំង។[៣]

ប្រទេសដែលមានការធ្វើសមាហរណកម្មកាន់តែច្រើន ដែលមានការកែលម្អ HDI រួមមាន មិនត្រឹមតែប្រទេសធំៗដែលគួរឲ្យកត់សំគាល់នោះទេ ប៉ុន្តែប្រទេសតូចៗជាង និងប្រទេសអភិវឌ្ឍន៍តិចតួចច្រើនជាងដប់ផងដែរ។ ដូច្នេះ ប្រទេសទាំងនេះស្ថិតនៅក្នុងក្រុមធំ និងមានលក្ខណៈចម្រុះជាងសេដ្ឋកិច្ចទីផ្សារដែលលេចធ្លោ ដែលជាញឹកញាប់ត្រូវបានឲ្យឈ្មោះ ដូចជា BRICS (Brazil, Russia, India, China and South Africa / ប្រេស៊ីល សហព័ន្ធរុស្ស៊ី ឥណ្ឌា ចិន និងអាហ្វ្រិកខាងត្បូង), IBSA (Inda, Brazil and South Africa / ឥណ្ឌា ប្រេស៊ីល និងអាហ្វ្រិកខាងត្បូង), CIVETS (Colombia, Vietnam, Egypt, Turkey and South Africa / កូឡុំប៊ី វៀតណាម អេហ្ស៊ីប ទួរគី និងអាហ្វ្រិកខាងត្បូង) និង MIST (Mexico, Indonesia, South Korea and Turkey / ម៉ិកស៊ិក ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង [សាធារណរដ្ឋកូរ៉េ] និងទួរគី) ។

តួលេខខាងក្រោមបង្ហាញពីការកែលម្អនៃ HDI[៤] ធៀបនឹងការប្រែប្រួលនៃអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផល ពោលគឺ សូចនាករអំពីកម្រិតនៃការចូលរួមនៅក្នុងទីផ្សារពិភពលោក។ ច្រើនជាងបួនភាគប្រាំនៃប្រទេសកំពុងអភិវឌ្ឍន៍ បានបង្កើនអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួននៅរវាងឆ្នាំ ១៩៩០ និង២០១២។ ក្នុងចំណោមករណីលើកលែងនៅក្នុងអនុក្រុមនេះ ដែលបានកែលម្អ HDI យ៉ាងច្រើនផងដែរនោះ គឺឥណ្ឌូនេស៊ី ប៉ាគីស្ថាន និងវេនេហ្ស៊ុយអេឡា ដែលជាប្រទេសចំនួនបីដែលត្រូវបានចាត់ទុកថាជាអ្នកដើរតួជាសកលនៅក្នុងទីផ្សារពិភពលោក ដោយនាំចេញ ឬនាំចូលយ៉ាងហោចណាស់ពីសេដ្ឋកិច្ចចំនួន ៨០។ ប្រទេសតូចជាងនេះចំនួនពីរ ដែលផលធៀបរវាងពាណិជ្ជកម្ម និងលទ្ធផលបានធ្លាក់ចុះ (ម៉ូរីទុស និងប៉ាណាម៉ា) បន្តធ្វើពាណិជ្ជកម្មតាមកម្រិតខ្ពស់ជាងយ៉ាងច្រើន ធៀបនឹងការរំពឹងទុកសម្រាប់ប្រទេសនានា ដែលមានកម្រិតប្រាក់ចំណូលប្រហែលគ្នា។ ប្រទេសទាំងអស់ ដែលបានកែលម្អ HDI យ៉ាងច្រើន និងបានបង្កើនអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួននៅរវាងឆ្នាំ ១៩៩០ និង ២០១២ មានគូសបញ្ជាក់នៅក្នុងជ្រុងខាងលើភាគខាងស្តាំ នៃរូបខាងក្រោម។ ប្រទេសនានានៅជ្រុងខាងស្តាំភាគខាងក្រោម (ដែលរួមទាំង កេនយ៉ា ហ្វីលីពីន និងអាហ្វ្រិកខាងត្បូង) បានបង្កើនអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួន ប៉ុន្តែមានការកែលម្អ HDI ត្រឹមតិចតួច)។

### វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស និងការពង្រីកពាណិជ្ជកម្មនៅភូមិភាគខាងត្បូង




១. ពាណិជ្ជកម្មទ្វេភាគីកើនលើស ២ លានដុល្លារ នៅក្នុងឆ្នាំ ២០១០-២០១១

២. ផ្អែកលើលទ្ធផលមកពីការគណនា regression នៃផលធៀបរវាងពាណិជ្ជកម្ម និង GDP នៃប្រទេសនានា លើប្រាក់ចំណូលក្នុងម្នាក់ៗ ដែលទាក់ទងនឹងចំនួនប្រជាជន និងស្ថានភាពភូមិសាស្ត្រមិនជាប់នឹងសមុទ្រ

៣. សូមអាន Rodrik (2001).

៤. កំណែលម្អ HDI វាស់ដោយលទ្ធផលពីការគណនាតាមរូបមន្ត regression នៃការប្រែប្រួល HDI រវាងឆ្នាំ ១៩៩០ និង ២០១២ ធៀបនឹង HDI ដំបូងនៅក្នុងឆ្នាំ ១៩៩០។ ប្រទេសចំនួន ៥ ត្រូវបានកត់សំគាល់ដោយពណ៌ប្រផេះនៅជ្រុងខាងលើភាគខាងឆ្វេង មានការកែលម្អយ៉ាងច្រើនខាង HDI ប៉ុន្តែ មានតួលេខថយចុះនៃអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួន នៅក្នុងរវាងឆ្នាំ១៩៩០ និង ២០១០ ទោះបីប្រទេសទាំងនេះ រក្សាបាននូវចំណងទាក់ទងខាងពាណិជ្ជកម្មយ៉ាងច្រើននៅលើពិភពលោក ឬបានធ្វើពាណិជ្ជកម្មច្រើនជាងការរំពឹងទុក ធៀបនឹងប្រទេសដែលមានប្រាក់ចំណូលក្នុងម្នាក់ៗប្រហាក់ប្រហែលគ្នាក៏ដោយ។ ប្រទេសដែលកត់សំគាល់ដោយពណ៌ប្រផេះនៅជ្រុងខាងលើភាគខាងស្តាំ និងជ្រុងខាងក្រោមភាគខាងស្តាំ មានកំណែលម្អ HDI តិចតួចនៅរវាងឆ្នាំ ១៩៩០ និង ២០១២ ប៉ុន្តែមានកំណើនអត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលរបស់ខ្លួន ឬរក្សាបាននូវចំណងទាក់ទងខាងពាណិជ្ជកម្មយ៉ាងច្រើន។

## កត្តាជំរុញទី ២ ៖ ទាញយកប្រយោជន៍ពីទីផ្សារពិភពលោក

ទីផ្សារពិភពលោកបានដើរតួយ៉ាងសំខាន់នៅក្នុងការជំរុញវឌ្ឍនភាព។ ប្រទេសឧស្សាហកម្មថ្មីៗទាំងអស់ បានប្រកាន់យកយុទ្ធសាស្ត្រមួយនៃ "ការនាំចូលអ្វី ដែលពិភពលោកទាំងមូលដឹង និងនាំចេញនូវអ្វីដែលពិភពលោកចង់បាន"។ ប៉ុន្តែប្រការសំខាន់ជាងនេះទៀត គឺលក្ខខណ្ឌនៃការចូលរួមនៅក្នុងទីផ្សារទាំងនោះ។ បើគ្មានការវិនិយោគលើមនុស្សទេ ផលចំណូលពីទីផ្សារពិភពលោកទំនងជាមានត្រឹមកម្រិតកំណត់តែប៉ុណ្ណោះ។ជោគជ័យមិនទំនងជាលទ្ធផល នៃការបើចំហភ្លាមៗនោះទេ ប៉ុន្តែ គឺជាលទ្ធផលនៃការធ្វើសមាហរណកម្មបណ្តើរៗ ជាបន្តបន្ទាប់ជាមួយសេដ្ឋកិច្ចពិភពលោក ស្របតាមកាលៈទេសៈ និងជាមួយការវិនិយោគលើមនុស្ស ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធ។ សេដ្ឋកិច្ចតូចៗបានទទួលជោគជ័យក្នុងការផ្តោតលើផលិតផល ដោយឡែករបស់ខ្លួន ពោលគឺជម្រើស ដែលជាញឹកញាប់ គឺជាលទ្ធផលនៃការគាំទ្រជាច្រើនឆ្នាំរបស់រដ្ឋ ដោយផ្អែកលើសមត្ថភាពដែលមានស្រាប់ ឬសមត្ថភាពដែលបង្កើតឡើងថ្មីៗ។

## កត្តាជំរុញ ៣ ៖ ភាពច្នៃប្រឌិតមុះមុតខាងគោលនយោបាយសង្គម

មានប្រទេសមិនច្រើនទេ ដែលបានរក្សានិរន្តរភាពកំណើនយ៉ាងឆាប់រហ័ស ដោយគ្មានការវិនិយោគសាធារណៈជាដុំកំភួន មិនត្រឹមតែលើហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើវិស័យអប់រំ និងសុខាភិបាលផងដែរ។ គោលដៅគួរតែជាការបង្កើតឲ្យមានវដ្តដ៏ល្អនៃកំណើន និងគោលនយោបាយសង្គម ដែលពង្រឹងគ្នាទៅវិញទៅមក។ ជាញឹកញាប់ កំណើនកាន់តែមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ នៅក្នុងបណ្តាប្រទេស ដែលមានកម្រិតទាបនៃវិសមភាពប្រាក់ចំណូល ជាងនៅក្នុងប្រទេសដែលមានកម្រិតខ្ពស់នៃវិសមភាពប្រាក់ចំណូល។ ការលើកកម្ពស់សមភាព ជាពិសេស ក្នុងចំណោមក្រុមជនជាតិ ឬពូជសាសន៍ដែលមានជំនឿសាសនាខុសៗគ្នា ក៏ជួយកាត់បន្ថយទំនាស់ក្នុងសង្គមផងដែរ។

### រូបទី ៥

**គិតជាភាគចំណែកនៃទំនិញក្នុងពាណិជ្ជកម្មពិភពលោក រវាងឆ្នាំ ១៩៨០-២០១១ ពាណិជ្ជកម្មត្បូង-ត្បូង បានកើនឡើងច្រើនជាងបីដង ចំណែកពាណិជ្ជកម្មជើង-ជើង បានធ្លាក់ចុះ**




**សំគាល់ ៖** ភូមិភាគខាងជើងនៅក្នុងឆ្នាំ ១៩៨០ សំដៅលើ អូស្ត្រាលី កាណាដា ជប៉ុន នូវែលហ្សេឡង់ ស.រ.អា និងអឺរ៉ុបខាងលិច។
**ប្រភព ៖** ការគណនារបស់ HDRO ផ្អែកតាម UNSD (2012).

### រូបទី ៦

**វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស និងការពង្រីកពាណិជ្ជកម្មនៅភូមិភាគខាងត្បូង**




**ប្រភព ៖** ការគណនារបស់ HDRO; អត្រាពាណិជ្ជកម្មធៀបនឹងលទ្ធផលបានពី World Bank (2012a).

## រូបទី ៧

**ប្រទេសខ្លះសម្រេចបានល្អលើ HDI ដែលឆ្លុះបញ្ចាំងទាំងអំពីប្រាក់ចំណូល និងមិនមែនប្រាក់ចំណូល**




**សំគាល់ ៖** ផ្អែកលើតួលេខពីប្រទេសចំនួន ៩៦ ៖ ប្រទេសដែលមានដាក់ឈ្មោះ មានលក្ខណៈតំណាងឲ្យសំណាកនៃប្រទេសដែលមានដំណើរការល្អខាងការអភិវឌ្ឍមនុស្សនៅកម្រិតតំបន់ និងមានពិភាក្សាពិស្តារបន្ថែមទៀតនៅទូទាំងជំពូកនេះ។
**ប្រភព ៖** ការគណនារបស់ HDRO

## រូបទី ៨

**តួលេខ HDI បច្ចុប្បន្ន និងការចំណាយសាធារណៈកន្លងមក មានទំនាក់ទំនងគ្នាជាវិជ្ជមាន ...**




**ប្រភព ៖** ការគណនារបស់ HDRO និង World Bank (2012a).

ការអប់រំ ការថែទាំសុខភាព និងកិច្ចគាំពារសង្គម ការផ្តល់សិទ្ធិអំណាចខាងផ្លូវច្បាប់ និងអង្គការសង្គម សុទ្ធតែជួយអ្នកក្រឲ្យចូលរួមនៅក្នុងកំណើន។ តុល្យភាពរវាងវិស័យនានា ជាពិសេសការយកចិត្តទុកដាក់លើវិស័យជនបទ និងការពង្រីកការងារ ទាំងលើប្រភេទការងារ និងទំហំការងារ មានសារៈសំខាន់ណាស់ក្នុងការកំណត់ថាតើកំណើននឹងនាំមក នូវការសាយភាពប្រាក់ចំណូលកម្រិតណា។ ប៉ុន្តែ សូម្បីតែបរិធានគោល-នយោបាយងាយៗ ក៏មិនអាចផ្តល់អំណាចដល់ក្រុមអ្នកទន់ខ្សោយឡើយ។ ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គមត្រូវតស៊ូពុះពារ ដើម្បីអាចបង្ហាញពីកង្វល់របស់ខ្លួន ហើយរដ្ឋាភិបាលមិនសុទ្ធតែធ្វើការវាយតម្លៃ ថាតើសេវានានាដែលមានគោលដៅសម្រាប់មនុស្សគ្រប់រូប ពិតជាបានផ្តល់ផលដូចការរំពឹងទុកនោះឡើយ។ គោលនយោបាយសង្គមត្រូវតែលើកកម្ពស់ការច្របាច់បញ្ចូលគ្នា ពោលគឺការធានាគ្មានភាពរើសអើង ហើយការយកចិត្តទុកដាក់ឲ្យបានស្មើភាព មានសារៈសំខាន់ណាស់ក្នុងការធានាស្ថិរភាពនយោបាយ និងសង្គម និងការផ្តល់សេវាសង្គមសំខាន់ៗ ដែលអាចទ្រទ្រង់កំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង ដោយគាំទ្រដល់កម្លាំងពលកម្មដែលកើតឡើងថ្មី ឲ្យមានសុខភាពល្អ និងមានការអប់រំខ្ពង់ខ្ពស់។ មិនមែនគ្រប់សេវាទាំងនេះ ត្រូវតែផ្តល់ជាសាធារណៈនោះទេ។ ប៉ុន្តែរដ្ឋត្រូវធានាថា ពលរដ្ឋគ្រប់រូបអាចទទួលបានតបតាមតម្រូវការសំខាន់ៗ នៃការអភិវឌ្ឍមនុស្ស ( សូមអានប្រអប់ ៣ )។

របៀបវារៈសម្រាប់វិបល្លាសការអភិវឌ្ឍដែលជំរុញការអភិវឌ្ឍមនុស្ស មានទម្រង់ខុសៗគ្នាជាច្រើន។ វាពង្រីកទ្រព្យរបស់ប្រជាជនដោយបង្កើនលទ្ធភាពទទួលបានជាសកលនូវសេវាសំខាន់ៗ។ វាកែលម្អមុខនាទីរបស់រដ្ឋ និងស្ថាប័នសង្គម ដើម្បីលើកកម្ពស់កំណើនដែលមានសមធម៌ ដែលជំរុញឲ្យមានការផ្តល់ប្រយោជន៍ទូលំទូលាយ។ វាកាត់បន្ថយឧបសគ្គខាងការិយាធិបតេយ្យ និងឧបសគ្គខាងសង្គម សម្រាប់ចំណាត់ការខាងសេដ្ឋកិច្ច និងការកៀងគរសង្គម។ វាតម្រូវឲ្យថ្នាក់ដឹកនាំមានគណនេយ្យភាព។

## ហេតុអ្វីទីក្រុងញូវយ៉កសម្លឹងទៅភូមិភាគខាងត្បូង ដើម្បីស្វែងរកប្រឹក្សាខាងគោលនយោបាយប្រឆាំងភាពក្រីក្រ

នៅក្រុងញូវយ៉ក យើងធ្វើការដើម្បីកែលម្អការរស់នៅរបស់ប្រជាពលរដ្ឋតាមវិធីជាច្រើន។ យើងបន្តកែលម្អគុណភាពនៃការអប់រំនៅក្នុងសាលារៀនរបស់យើង។ យើងបានកែលម្អសុខភាពរបស់អ្នករស់នៅក្នុងក្រុងញូវយ៉ក ដោយកាត់បន្ថយការជក់បារី និងរោគធាត់។ យើងបានកែលម្អទេសភាពទីក្រុងនេះ ដោយបន្ថែមផ្លូវសម្រាប់ការជិះកង់ និងដាំដើមឈើជាច្រើនពាន់ដើម។

យើងបានប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ដោយស្វែងរកវិធីថ្មីៗ និងល្អជាងមុន ដើម្បីបង្កើតស្មារតីខ្លួនទីពឹងខ្លួន និងត្រៀមលក្ខណៈ ដើម្បីឲ្យពលរដ្ឋវ័យក្មេងរបស់យើង មានអនាគតភ្លឺស្វាង។ ដើម្បីដឹកនាំកិច្ចប្រឹងប្រែងនេះ យើងបានបង្កើតមជ្ឈមណ្ឌលសម្រាប់កាលានុវត្តភាពសេដ្ឋកិច្ច។ មជ្ឈមណ្ឌលនេះមានបេសកកម្មកំណត់យុទ្ធសាស្ត្រនានា ដើម្បីជួយកាត់ផ្តាច់ចំណងនៃភាពក្រីក្រតាមរយៈកិច្ចផ្តួចផ្តើមអប់រំ សុខភាព និងការងារបែបច្នៃប្រឌិត។

នៅក្នុងរយៈពេល ៦ ឆ្នាំកន្លងមកនេះ មជ្ឈមណ្ឌលនេះបានប្រកាសកម្មវិធីសាកល្បងច្រើនជាង ៥០ ក្រោមភាពជាដៃគូជាមួយទីភ្នាក់ងារនានាក្នុងក្រុងនេះ និងអង្គការសហគមន៍ជាច្រើនរយ។ មជ្ឈមណ្ឌលនេះបានបង្កើតយុទ្ធសាស្ត្រវាយតម្លៃសម្រាប់គម្រោងសាកល្បងទាំងនេះ ពិនិត្យតាមដានដំណើរការនៃគម្រោង, ប្រៀបធៀបលទ្ធផលនានា និងកំណត់យុទ្ធសាស្ត្រនានាដែលមានជោគជ័យបំផុត ក្នុងការកាត់បន្ថយភាពក្រីក្រ និងពង្រីកកាលានុវត្តភាព។ កម្មវិធីដែលមានជោគជ័យ នឹងត្រូវបន្តអត្ថិភាពរបស់វា តាមរយៈមូលនិធិសាធារណៈ និងឯកជនថ្មីៗ។ កម្មវិធីដែលមិនទទួលជោគជ័យនឹងត្រូវបញ្ឈប់ និងបង្វែរធនធានទៅវិនិយោគលើយុទ្ធសាស្ត្រថ្មីៗ។ បន្ទាប់មករបកគំហើញពីមជ្ឈមណ្ឌលនេះ ត្រូវបានចែករំលែកនៅក្នុងស្ថាប័ននានានៃរដ្ឋាភិបាល ជាមួយអ្នកកសាងគោលនយោបាយ ជាមួយដៃគូជាអង្គការមិនស្វែងរកផលចំណេញ និងម្ចាស់ជំនួយឯកជន និងជាមួយសហសេវិកនានានៅទូទាំងប្រទេស និងនៅជុំវិញពិភពលោកដែលកំពុងស្វែងរកវិធីថ្មីៗក្នុងការកាត់ផ្តាច់ចំណងនៃភាពក្រីក្រ។

ក្រុងញូវយ៉កមានសំណាង ដោយសារមានមនុស្សឈ្លាសវៃបំផុតលើពិភពលោកនៅក្នុងធុរៈកិច្ច និងសកលវិទ្យាល័យរបស់យើង ប៉ុន្តែយើងទទួលស្គាល់ថា មានចំណុចជាច្រើនដែលយើងត្រូវរៀនសូត្រពីកម្មវិធីនានាដែលបានបង្កើតនៅកន្លែងផ្សេង។ នេះជាមូលហេតុដែលមជ្ឈមណ្ឌលនេះបានចាប់ផ្តើមការងាររបស់ខ្លួនដោយធ្វើការអង្កេតជាអន្តរជាតិអំពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលមានប្រសិទ្ធភាព។

នៅឆ្នាំ ២០០៧ មជ្ឈមណ្ឌលនេះបានប្រកាសកម្មវិធីឱកាសសម្រាប់គ្រួសារនៅទីក្រុងញូវយ៉ក (Opportunity NYC: Family Rewards) ដែលជាកម្មវិធីផ្តល់សាច់ប្រាក់ ដោយមានលក្ខខណ្ឌនៅក្នុងសហរដ្ឋអាមេរិក។ ផ្អែកតាមកម្មវិធីប្រហែលគ្នានេះ ដែលអនុវត្តនៅក្នុងប្រទេសច្រើនជាង ២០ កម្មវិធី Opportunity NYC: Family Rewards បានជួយកាត់បន្ថយភាពក្រីក្រ ដោយផ្តល់ឲ្យគ្រួសារនានា នូវការលើកទឹកចិត្តក្នុងការទទួលបានសេវាការពារសុខភាព ការអប់រំ និងការបណ្តុះបណ្តាលអំពីការងារ។ នៅក្នុងការបង្កើតកម្មវិធីនេះ យើងរៀនសូត្រពីមេរៀនមកពីប្រទេស ប្រេស៊ីល ម៉ិចស៊ិក និងប្រទេសដទៃទៀតជាច្រើន។ នៅចុងបញ្ចប់នៃកម្មវិធីសាកល្បងរយៈពេលបីឆ្នាំរបស់យើង យើងបានរកឃើញថាកម្មវិធីណាខ្លះ ដែលអាចអនុវត្តដោយជោគជ័យនៅក្រុងញូវយ៉កនិងកម្មវិធីណាខ្លះមិនមានប្រសិទ្ធភាព។ព័ត៌មានដែលទទួលបានមានប្រយោជន៍សម្រាប់កម្មវិធីដទៃទៀត ដែលអាចយកទៅអនុវត្តនៅទូទាំងពិភពលោក។

មុននឹងប្រកាសកម្មវិធី Opportunity NYC: Family Rewards ខ្ញុំបានទៅទស្សនា ក្រុងទូលូកានៅម៉ិចស៊ិកូ ដើម្បីស្វែងយល់ដោយផ្ទាល់អំពីកម្មវិធីផ្តល់សាច់ប្រាក់ ដោយមានលក្ខខណ្ឌរបស់សហព័ន្ធ ដែលអនុវត្តដោយជោគជ័យនៅម៉ិចស៊ិកកូ ដែលមានឈ្មោះថា Oportunidades។ យើងក៏បានចូលរួមនៅក្នុងកម្មវិធីផ្លោះប្តូរការរៀនសូត្រជើង-ត្បូងផងដែរ ដែលរៀបចំដោយអង្គការសហប្រជាជាតិ។ យើងធ្វើការជាមួយមូលនិធិ Rockefeller Foundation, ធនាគារពិភពលោក អង្គការនៃរដ្ឋអាមេរិក និងគ្រឹះស្ថានដទៃទៀត និងអ្នកកសាងគោលនយោបាយអន្តរជាតិ ដើម្បីផ្លោះប្តូរបទពិសោធន៍អំពីកម្មវិធីផ្តល់សាច់ប្រាក់ដោយមានលក្ខខណ្ឌនៅអាមេរិកឡាទីន ដូចជានៅតំបន់ទេស៊ី អាហ្វ្រិកខាងត្បូង និងទួរគីផងដែរ។

ការផ្លោះប្តូរការរៀនសូត្រជាអន្តរជាតិរបស់យើង មានមិនត្រឹមតែលើកិច្ចផ្តួចផ្តើមផ្តល់សាច់ប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែ ក៏មានរាប់បញ្ចូលវិធានបែបច្នៃប្រឌិតនានាសម្រាប់ការដឹកជញ្ជូនក្នុងទីក្រុង កិច្ចផ្តួចផ្តើមអប់រំថ្មីៗ និងកម្មវិធីនានាផ្សេងទៀតផងដែរ។

គ្មានអ្នកណាម្នាក់មានភាពផ្តាច់មុខលើគំនិតល្អៗនោះទេ ដែលនេះជាមូលហេតុដែលក្រុងញូវយ៉ក ត្រូវបន្តសិក្សារៀនសូត្រពីទម្លាប់ល្អៗនៃទីក្រុង និងប្រទេសដទៃទៀត។ ក្នុងពេលដែលយើងកែលម្អ និងវាយតម្លៃកម្មវិធីថ្មីៗរបស់យើងក្នុងទីក្រុងរបស់យើងផ្ទាល់ យើងនៅតែមានការប្តេជ្ញាក្នុងការផ្តល់សងទៅវិញនូវអំពើល្អដែលគេបានធ្វើមកលើយើង ក៏ដូចជាជួយធ្វើឲ្យមានភាពប្រសើរយូរអង្វែងនៅក្នុងសហគមន៍នានា ជុំវិញពិភពលោកផងដែរ។

## វក្សាកម្លាំងចលករ

ប្រទេសភាគច្រើនក្នុងភូមិភាគខាងត្បូង បានបង្ហាញនូវជោគជ័យជាច្រើន។ ប៉ុន្តែ សូម្បីតែក្នុងប្រទេសដែលសម្រេចផលកម្រិតខ្ពស់ក៏ដោយ ក៏នៅតែមិនអាចធានាជោគជ័យទៅអនាគត នៅឡើយទេ។ តើប្រទេសនៅភូមិភាគខាងត្បូងអាចបន្តជំហាននៃវឌ្ឍនភាពរបស់ខ្លួន លើការអភិវឌ្ឍមនុស្សដោយរបៀបណា និងតើវឌ្ឍនភាពនេះអាចពង្រីកទៅក្នុងប្រទេសដទៃ ដោយរបៀបណា? របាយការណ៍នេះ លើកស្នើវិស័យសំខាន់ៗចំនួនបួនសម្រាប់សម្រួលដំណើរការនេះ៖ ពង្រឹងសមធម៌, ជំរុញការបញ្ចេញទស្សនៈ និងការចូលរួម, ដោះស្រាយបញ្ហាបរិស្ថាន និងគ្រប់គ្រងការប្រែប្រួលប្រជាសាស្ត្រ។ របាយការណ៍នេះចង្អុលបង្ហាញពីការបង់ខាតកម្រិតខ្ពស់ បណ្តាលពីកង្វះចំណាត់ការខាងគោលនយោបាយ និងធ្វើទទ្បីករណ៍ ឲ្យមានមហិច្ឆតាកាន់តែច្រើនខាងគោលនយោបាយ។

### ពង្រឹងសមធម៌

សមធម៌កាន់តែច្រើន ដែលរួមទាំងរវាងបុរស និងស្ត្រី និងរវាងក្រុមនានា មានតម្លៃមិនត្រឹមតែនៅក្នុងគោលការណ៍នេះផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានសារៈសំខាន់ សម្រាប់លើកកម្ពស់ការអភិវឌ្ឍមនុស្សផងដែរ។ បរិធានដ៏មានឥទ្ធិពលបំផុតមួយសម្រាប់គោលបំណងនេះ គឺការអប់រំ ដែលធ្វើឲ្យប្រជាជនបង្កើនទំនុកចិត្តលើខ្លួនឯង និងធ្វើឲ្យពួកគេ កាន់តែងាយស្រួលក្នុងការស្វែងរកការងារ ធ្វើងាយចូលរួមនៅក្នុងការ ជជែកវែកញែកជាសាធារណៈ និងតម្រូវឲ្យរដ្ឋាភិបាលផ្តល់សេវាថែទាំសុខភាព សន្តិសុខសង្គម និងសិទ្ធិដទៃទៀត។

ការអប់រំ ក៏ផ្តល់ប្រយោជន៍ច្រើនសម្រាប់សុខភាព និងអត្រានៃការមានជីវិតផងដែរ (ប្រអប់ទី ២)។ ការស្រាវជ្រាវសម្រាប់របាយការណ៍នេះ បានរកឃើញថា ការអប់រំមាតាកាន់តែមានសារៈ-សំខាន់ចំពោះការមានជីវិតរបស់កុមារ ជាងប្រាក់ចំណូលក្នុងគ្រួសារ ឬទ្រព្យសម្បត្តិទៅទៀត ហើយអន្តរាគមន៍គោលនយោបាយ មានឥទ្ធិពលយ៉ាងខ្លាំង នៅក្នុងកន្លែងដែលកាលពីដំបូងការអប់រំផ្តល់ផលតិចតួច។ នេះជាឥទ្ធិពលស៊ីជម្រៅនៃគោល-នយោបាយ ដែលអាចប្តូរការយកចិត្តទុកដាក់ពីកិច្ចប្រឹងប្រែង ដើម្បីបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ ទៅជាវិធានការ ដើម្បីកែលម្អការអប់រំកុមារ។

របាយការណ៍នេះ គាំទ្រឲ្យមានមហិច្ឆតាខាងគោលនយោបាយ។ តាមរយៈសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័ស ប្រទេសដែលមាន HDI កម្រិតទាប អាចឈានទៅសម្រេចបានការអភិវឌ្ឍមនុស្សដូចប្រទេសដែលមាន HDI កម្រិតខ្ពស់ និងខ្ពស់បំផុតផងដែរ។ រហូតដល់ឆ្នាំ ២០៥០ HDI សរុបអាចកើន ៥២% នៅតំបន់ក្បែរសាហារ៉ានៃទ្វីបអាហ្វ្រិក (ពី ០,៤០២ ដល់ ០,៦១២) និង ៣៦% នៅអាស៊ីខាងត្បូង (ពី ០,៥២៧ ដល់ ០,៧១៤)។ អន្តរាគមន៍គោលនយោបាយនៅក្រោមសេណារីយ៉ូនេះ ក៏មានឥទ្ធិពលវិជ្ជមានមកលើការប្រយុទ្ធប្រឆាំងភាពក្រីក្រផងដែរ។ ផ្ទុយទៅវិញ ការបង់ខាតដោយសារតែគ្មានចំណាត់ការនឹងមានទំហំកាន់តែធំ ជាពិសេស នៅក្នុងប្រទេសដែលមាន HDI កម្រិតទាប ដែលកាន់តែងាយរងគ្រោះ។ ជាក់ស្តែង ការខកខានមិនអនុវត្តគោលនយោបាយប្រកបដោយមហិច្ឆតា នៃការទទួលបាននូវការអប់រំជាសកល នឹងមានឥទ្ធិពលអវិជ្ជមានមកលើមូលដ្ឋានជាច្រើននៃការអភិវឌ្ឍមនុស្សសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

### ការលើកកម្ពស់ការបញ្ចេញទស្សនៈ និងការចូលរួម

ដរាបណាទាល់តែប្រជាពលរដ្ឋ អាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងពិធី និងដំណើរការនានា ដែលមានឥទ្ធិពលមកលើជីវិតរបស់ពួកគេ មាគ៌ាការអភិវឌ្ឍមនុស្សរបស់ជាតិ នឹងមិនអាចសម្រេចបានគោលបំណងដូចប្រាថ្នា ឬមាននិរន្តរ-ភាពឡើយ។ ប្រជាជន គួរតែអាចមានឥទ្ធិពលទៅលើការកសាងគោលនយោបាយ និងលទ្ធផលនានា ជាពិសេស ពលរដ្ឋវ័យក្មេងគួរតែអាចមានការរំពឹងលើឱកាសខាងសេដ្ឋកិច្ច និងការចូលរួមក្នុងនយោបាយ និងគណនេយ្យភាពកាន់តែច្រើនជាងមុន។

នៅភូមិភាគខាងជើង និងខាងត្បូង ប្រជាជនកាន់តែមានសេចក្តីទាមទារខ្លាំងឡើងៗ នៅពេល

រូបទី ៩

### លទ្ធផលនៃការអភិវឌ្ឍមនុស្ស រហូតដល់ឆ្នាំ ២០៥០ អាចជួយកែលម្អបានកាន់តែច្រើននូវសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័ស




### កំណើន GDP ក្នុងម្នាក់ៗ រហូតដល់ឆ្នាំ ២០៥០ មានកម្រិតខ្ពស់នៅក្រោមសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័ស




ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍមនុស្ស ការបង់ខាតដោយសារកង្វះចំណាត់ការមានកម្រិតខ្ពស់សម្រាប់ប្រទេសនានា ដែលមាន HDI ទាប។ បើគិតអំពីការខាតបង់ GDP ក្នុងម្នាក់ៗ ការខាតបង់ដោយសារកង្វះចំណាត់ការមានសមាមាត្រដូចគ្នាសម្រាប់ប្រទេសនានា បើទោះប្រទេសទាំងនោះមាន HDI កម្រិតណាក៏ដោយ។

**ប្រភព ៖** ការគណនារបស់ HDRO ផ្អែកតាម Pardee Center for International Futures (2013).

ដែលពួកគេទាមទាររកឱកាសច្រើនជាងមុន ដើម្បីបង្ហាញកង្វល់របស់ពួកគេ និងការរកវិធីធ្វើឥទ្ធិពលទៅលើគោលនយោបាយ ជាពិសេស ផ្នែកកិច្ចគាំពារសំខាន់ៗខាងសង្គម។ ក្នុងចំណោមអ្នកតវ៉ាដែលសកម្មជាងគេ គឺយុវជន មួយផ្នែកជាប្រតិកម្មតបទៅនឹងកង្វះការងារ និងឱកាសស្តួចស្តើងសម្រាប់យុវជន ដែលបញ្ចប់ការសិក្សាទទួលបានការងារធ្វើ។ ប្រវត្តិសាស្ត្រកន្លងមកពោរពេញដោយការបះបោរប្រឆាំងនឹងរដ្ឋាភិបាល ដែលមិនបានធ្វើការឆ្លើយតបទៅនឹង ការទាមទាររបស់ពួកគេ។ ប្រការនេះអាចធ្វើឲ្យការអភិវឌ្ឍមនុស្សវេខុសគន្លងផ្លូវរបស់វា ដោយសារថា ភាពវឹកវរំរំជើបរំជួលជាឧបសគ្គដល់ការវិនិយោគ និងកំណើន ហើយក្នុងសភាពបែបនោះ រដ្ឋាភិបាលអត្តាធិបតេយ្យនាំគ្នាបង្វែរធនធាន ទៅប្រើក្នុងការពង្រឹងការអនុវត្តច្បាប់ និងការរក្សាសណ្តាប់ធ្នាប់ទៅវិញ។

គេពិបាកនឹងទស្សន៍ទាយណាស់ថាតើពេលណាទើបសង្គម ឈានដល់ចំណុចដាំទីងក្រឡាប់ចាក់។ ការបះបោររបស់មហាជន ជាពិសេសដោយពលរដ្ឋដែលមានការអប់រំ ទំនងជាផ្ទុះឡើងនៅពេលអនាគត សម្រាប់ឱកាសខាងសេដ្ឋកិច្ចមានភាពអាប់អួរកាត់បន្ថយថ្លៃ ឱកាសនៃការចូលរួមនៅក្នុងសកម្មភាពនយោបាយ។ បន្ទាប់មកទៀត "ទម្រង់កិច្ចប្រឹងប្រែងប្រកបដោយអានុភាពនៃការប្រឡូកក្នុងនយោបាយ" ទាំងនេះ អាចទទួលបានការសម្របសម្រួល ផ្សព្វផ្សាយ បានកាន់តែងាយថែមទៀត តាមរយៈទម្រង់ថ្មីៗនៃមធ្យោបាយសារគមនាគមន៍មហាជន (mass communications)។

របាយការណ៍នេះ សបញ្ជាក់ឲ្យឃើញនូវភាពចាំបាច់ត្រូវមានគោលនយោបាយប្រកបដោយមហិច្ឆតា

## តស៊ូចំពោះការប្រឈមខាងបរិស្ថាន

ទោះបីការគំរាមកំហែងខាងបរិស្ថាន ដូចជាការប្រែប្រួលអាកាសធាតុ ការបាត់បង់ព្រៃឈើ ការបំពុលខ្យល់ និងទឹក និងគ្រោះមហន្តរាយធម្មជាតិ មានឥទ្ធិពលមកលើមនុស្សគ្រប់រូបក៏ដោយ កត្តាទាំងនេះបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុតមកលើប្រទេស និងសហគមន៍ក្រីក្រ។ ការប្រែប្រួលអាកាសធាតុកំពុងតែបង្កើនការគំរាមកំហែង ដែលមានជាប្រចាំមកលើបរិស្ថាន ហើយការបាត់បង់ប្រព័ន្ធអេកូឡូស៊ី កំពុងតែបង្កជាឧបសគ្គមកលើឱកាសនៃការចិញ្ចឹមជីវិត ជាពិសេស សម្រាប់ពលរដ្ឋក្រីក្រ។

ទោះបីប្រទេសដែលមាន HDI កម្រិតទាប រួមចំណែកតិចតួច ក្នុងការធ្វើឲ្យប្រែប្រួលអាកាសធាតុសកលក៏ដោយ ប្រទេសទាំងនេះទំនងជាជួបប្រទះនឹងការបាត់បង់ច្រើនបំផុត នៃទឹកភ្លៀងប្រចាំឆ្នាំ និងកំណើនយ៉ាងគំហុកនៃវិសមរូបធាតុអាកាសដោយមានឥទ្ធិពល អវិជ្ជមានមកលើផលិតផលកសិកម្ម និងការចិញ្ចឹមជីវិត។ ទំហំនៃការបាត់បង់ទាំងនេះ គូសបញ្ជាក់អំពីភាពបន្ទាន់នៃការប្រកាន់យកវិធានការទប់ទល់ ដើម្បីបង្កើនភាពធន់របស់ប្រជាជននៅចំពោះមុខការប្រែប្រួលអាកាសធាតុ។

តម្លៃដែលត្រូវបង់ដោយសារកង្វះចំណាត់ការទំនងជានឹងមានកម្រិតខ្ពស់។ បើគេពន្យារចំណាត់ការកាន់តែយូរកាលណា ការបង់ខាតក៏នឹងមានទំហំកាន់តែធំដែរ។ ដើម្បីធានាឲ្យសេដ្ឋកិច្ច និងសង្គមមាននិរន្តរភាព គេត្រូវការឲ្យមានគោលនយោបាយថ្មីៗ និងការកែប្រែរចនាសម្ព័ន្ធដែលបន្សុីគ្នារវាងការអភិវឌ្ឍមនុស្ស និងគោលដៅនៃការប្រែប្រួលអាកាសធាតុជាមួយយុទ្ធសាស្ត្រ នៃការបំភាយកម្រិតទាប, ភាពធន់ចំពោះអាកាសធាតុ និងយន្តការហិរញ្ញប្បទានបែបច្នៃប្រឌិតនៃភាពជាដៃគូរវាងវិស័យសាធារណ និងឯកជន។

## គ្រប់គ្រងការប្រែប្រួលប្រជាសាស្ត្រ

រវាងឆ្នាំ ១៩៧០ និង ២០១១ ប្រជាជនក្នុងពិភពលោកបានកើនឡើងពី ៣,៦ ពាន់លានដល់ ៧ ពាន់លាននាក់។ នៅពេលប្រជាជនក្នុងពិភពលោកមានការអប់រំកាន់តែច្រើនឡើង អត្រាកំណើនប្រជាជននឹងថយចុះ។ ការរំពឹងលើការអភិវឌ្ឍស្ថិតក្រោមឥទ្ធិពល នៃរចនាសម្ព័ន្ធអាយុរបស់ពលរដ្ឋ ក៏ដូចជាចំនួនប្រជាជនផងដែរ។ កង្វល់ដែលកាន់តែធ្ងន់ធ្ងរ គឺអត្រានៃមនុស្សក្នុងបន្ទុក ពោលគឺ ចំនួនពលរដ្ឋវ័យក្មេង និងមនុស្សចាស់ ដែលចែកដាច់ចេញពីគ្នាដោយក្រុមមនុស្សក្នុងវ័យធ្វើការដែលមានអាយុ ១៥-៦៤ ឆ្នាំ។

ប្រទេសក្រីក្រខ្លះ នឹងទទួលផលពី "ភាគលាភប្រជាសាស្ត្រ" ដោយសារសមាមាត្រនៃចំនួនប្រជាជនក្នុងវ័យធ្វើការកំពុងកើនឡើង ប៉ុន្តែអាចទទួលផលបាន តែក្នុងករណីដែលមានចំណាត់ការខាងគោលនយោបាយតែប៉ុណ្ណោះ។ ជាក់ស្តែង ការអប់រំកុមារី គឺជាមធ្យោបាយយ៉ាងសំខាន់ក្នុងការទាញយកផលពីភាគចំណែកនៃប្រជាសាស្ត្រ។ ស្ត្រីដែលមានការសិក្សាខ្ពស់ ទំនងជាមានកូនតិចដែលមានសុខភាពល្អ និងមានការអប់រំខ្ពស់។ នៅក្នុងប្រទេសជាច្រើន ស្ត្រីដែលមានការសិក្សាខ្ពស់ក៏បានទទួលប្រាក់បៀវត្សរ៍ខ្ពស់ជាងកម្មករ ដែលគ្មានការសិក្សាផងដែរ។

ផ្ទុយទៅវិញ តំបន់ដែលជាអ្នកមានជាងនៅក្នុងភូមិភាគខាងត្បូង នឹងប្រឈមជាមួយបញ្ហាបែបផ្សេងទៅវិញ ដោយសារប្រជាជនក្នុងប្រទេសទាំងនោះមានវ័យកាន់តែជ្រេ ហើយដូច្នេះ វាក៏បន្ថយសមាមាត្រ នៃចំនួនប្រជាជនក្នុងវ័យធ្វើការផងដែរ។ អត្រានៃចំនួនប្រជាជនមានវ័យជ្រេ ពិតជារឿងមួយមានសារៈសំខាន់ ព្រោះថាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បើសិនជាស្ថិតក្នុងភាពក្រីក្រនៅឡើយ នឹងត្រូវជួបការលំបាកក្នុងការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងវ័យចំណាស់។ បច្ចុប្បន្នបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅមានឱកាសតិចតួចប៉ុណ្ណោះក្នុងការទាញយកផលពេញលេញពីភាគលាភប្រជាសាស្ត្រនេះ។

ទោះជាយ៉ាងណាក៏ដោយ និន្នាការប្រជាសាស្ត្រមិនមែនជាកត្តាកំណត់នោះទេ។ គេអាចកែប្រែនិន្នាការនេះ យ៉ាងហោចណាស់ ដោយប្រយោលតាមរយៈគោលនយោបាយអប់រំ។ របាយការណ៍នេះបង្ហាញពីសេណារីយ៉ូចំនួនពីរសម្រាប់ឆ្នាំ ២០១០-២០៥០ ៖ សេណារីយ៉ូគោល ដែលក្នុងនោះ អត្រានៃការចុះឈ្មោះចូលរៀននៅថេរ ក្នុងគ្រប់កម្រិតសិក្សា និងសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័ស ដែលក្នុងនោះប្រទេសនានា ដែលកាលពីដំបូង

## ប្រអប់ ៤

### ហេតុអ្វីទស្សនៈរបស់ប្រជាជនទំនងជាមានភាពខុសគ្នា នៅក្នុងសាធារណរដ្ឋកូរ៉េ និងឥណ្ឌា

កម្រិតនៃការសិក្សាបានកើនឡើងយ៉ាងឆាប់រហ័ស នៅក្នុងសាធារណរដ្ឋកូរ៉េ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ សមាមាត្រយ៉ាងច្រើននៃកុមារនៅអាយុចូលរៀនមិនបានទទួលការអប់រំជាផ្លូវការឡើយ។ បច្ចុប្បន្ននេះ យុវតីកូរ៉េស្ថិតក្នុងចំណោមស្ត្រី ដែលបានទទួលការអប់រំល្អជាងគេក្នុងពិភពលោក ៖ ច្រើនជាងពាក់កណ្តាល បានបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យ។ ជាលទ្ធផល ទៅអនាគតជនជាតិកូរ៉េក្នុងវ័យចំណាស់ នឹងបានទទួលការអប់រំកាន់តែប្រសើរឡើងជាងមនុស្សចំណាស់នៅកូរ៉េ ក្នុងពេលបច្ចុប្បន្ននេះ (សូមអានរូប) និងដោយសារទំនាក់ទំនងវិជ្ជមានរវាងការអប់រំ និងសុខភាព ពួកគេទំនងជាមានសុខភាពល្អជាងផងដែរ។

ឧបមាថា អត្រាសិស្សចុះឈ្មោះចូលរៀន (ដែលមានកម្រិតខ្ពស់) នៅថេរ សមាមាត្រនៃពលរដ្ឋដែលមានអាយុតិចជាង ១៤ ឆ្នាំ នឹងថយចុះពី ១៦% ក្នុងឆ្នាំ ២០១០ មកត្រឹម ១៣% នៅឆ្នាំ ២០៥០។ គេនឹងឃើញមានការប្រែប្រួលគួរឲ្យកត់សំគាល់នៃមាសភាពការអប់រំ ក្នុងចំណោមប្រជាជនដែលអ្នកបានទទួលសិក្សាថ្នាក់ឧត្តម នឹងមានសមាមាត្រកើនឡើងពី ២៦% ដល់ ៤៧%។

សម្រាប់ប្រទេសឥណ្ឌា រូបភាពនេះមានលក្ខណៈខុសគ្នា។ មុនឆ្នាំ ២០០០ ច្រើនជាងពាក់កណ្តាលនៃមនុស្សពេញវ័យ ពុំបានទទួលការអប់រំជាផ្លូវការទេ។ បើទោះជាមានការពង្រីកការអប់រំជាមូលដ្ឋាននៅក្នុងពេលថ្មីៗនេះ និងកំណើនគួរឲ្យកត់សំគាល់ នៃចំនួនពលរដ្ឋឥណ្ឌាដែលបានទទួលការអប់រំខ្ពង់ខ្ពស់ក៏ដោយ (ដែលជាកត្តាគន្លឹះនៅក្នុងកំណើនសេដ្ឋកិច្ចឥណ្ឌាក្នុងពេលថ្មីៗនេះ) សមាមាត្រនៃមនុស្សពេញវ័យដែលពុំបានទទួលការសិក្សា នឹងថយចុះយឺតៗតែប៉ុណ្ណោះ។ ស្ថានភាពនេះមួយផ្នែក គឺដោយសារកម្រិតទាបជាងនៃការអប់រំ ជាពិសេស ក្នុងចំណោមស្ត្រី។ ចំនួនប្រជាពលរដ្ឋឥណ្ឌាត្រូវបានព្យាករណ៍ថានឹងកើនឡើងយ៉ាងឆាប់រហ័ស ដែលអាចឈានហួសប្រទេសចិនដែលមានប្រជាជនច្រើនជាងគេ។ សូម្បីនៅក្នុងសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័សប្រកបដោយមោទនភាពក៏ដោយ ដែលសន្មតថាមានការពង្រីកការសិក្សាដូចនៅកូរ៉េ របាយនៃការអប់រំនៅឥណ្ឌាក្នុងឆ្នាំ ២០៥០ នឹងនៅតែមានវិសមភាពកម្រិតខ្ពស់នៅឡើយ ដោយមនុស្សពេញវ័យក្នុងចំនួនច្រើន (ពិសេសមនុស្សចាស់) ជាអ្នកមិនបានទទួលការសិក្សា។ ទោះជាយ៉ាងណាក៏ដោយ ការពង្រីកយ៉ាងឆាប់រហ័សនៃការសិក្សាថ្នាក់ឧត្តមក្នុងសេណារីយ៉ូនេះ នឹងបង្កើតឲ្យមានកម្លាំងមនុស្សពេញវ័យដែលមានការសិក្សាកម្រិតខ្ពស់។

#### ការប្រៀបធៀបអនាគតនៃចំនួនប្រជាជន និងការអប់រំ នៅសាធារណរដ្ឋកូរ៉េ និងឥណ្ឌា




**ប្រភព ៖** Lutz and KC 2013

មានកម្រិតសិក្សាទាប ប្រកាន់យកចំណុចដៅប្រកបដោយមហិច្ឆតាខាងការអប់រំ។ ការថយចុះនៃអត្រាមនុស្ស ក្នុងបន្ទុកសម្រាប់ប្រទេសដែលមានតួលេខ HDI ទាប នៅក្រោមសេណារីយ៉ូនៃវឌ្ឍនភាពឆាប់រហ័ស មានច្រើនជាងពីរដងនៃអត្រានៅក្រោមសេណារីយ៉ូគោល។ គោលនយោបាយប្រកបដោយមហិច្ឆតាលើការអប់រំអាចជួយប្រទេសដែលមានតួលេខ HDI មធ្យម និងខ្ពស់ក្នុងការដោះស្រាយកំណើន នៃអត្រាមនុស្សក្នុងបន្ទុក ដែលបានព្យាករណ៍សម្រាប់ប្រទេសទាំងនោះ ដើម្បីធ្វើឲ្យអន្តរកាលនៃប្រជាសាស្រ្តក្នុងប្រទេសទាំងនោះ មិនសូវជួបការលំបាកនៅក្នុងពេលឈានទៅក្នុងវ័យចាស់។

ការដោះស្រាយភាពប្រឈម នៃរចនាសម្ព័ន្ធប្រជាជន នឹងទាមទារឲ្យមានការបង្កើនកម្រិតនៃការសិក្សា ទន្ទឹមនឹងការពង្រីកឱកាសសម្រាប់ការងារដែលផ្តល់ផល ដោយកាត់បន្ថយភាពគ្មានការងារធ្វើ លើកកម្ពស់ផលិតភាពការងារ និងបង្កើនការចូលរួមរបស់កម្លាំងពលករ ជាពិសេសក្នុងចំណោមស្ត្រី និងកម្មករវ័យចំណាស់។

ដំណើរការខ្លះក្នុងក្របខ័ណ្ឌអន្តររដ្ឋាភិបាលអាចសកម្មឡើងវិញតាមរយៈការចូលរួមកាន់តែច្រើនជាងមុនពីភូមិភាគខាងត្បូង

## អភិបាលកិច្ច និងភាពជាដៃគូសម្រាប់សម័យកាលថ្មី

របៀបរបបថ្មីៗ ដែលភូមិភាគខាងត្បូងបានជំរុញកន្លងមក និងពហុទស្សនៈ ដែលវាបាននាំមកជាមួយ កំពុងតែក្លាយជាភាពប្រឈមចំពោះស្ថាប័ន និងដំណើរការនានាដែលមានស្រាប់នៅក្នុងក្របខ័ណ្ឌពហុភាគីជាប្រពៃណី ពោលគឺហិរញ្ញវត្ថុ ពាណិជ្ជកម្ម ការវិនិយោគ និងសុខភាពដែលជូនកាលដោយផ្ទាល់ និងជួនកាលដោយប្រយោលតាមរយៈប្រព័ន្ធផ្សេងៗនៅថ្នាក់តំបន់ និងថ្នាក់អនុតំបន់។ អភិបាលកិច្ចនៅកម្រិតពិភពលោក និងតំបន់ កំពុងតែក្លាយជាបណ្តុំនៃរបៀបរបបថ្មីៗ និងរចនាសម្ព័ន្ធចាស់ៗ ដែលទាមទារឲ្យមានការគាំទ្ររួមគ្នាតាមវិធីផ្សេងៗ។ កំណែទម្រង់នៃស្ថាប័នពិភពលោកត្រូវតែមានការបំពេញបន្ថែមដោយកិច្ចសហប្រតិបត្តិការរឹងមាំជាងមុន ជាមួយស្ថាប័ននានានៅថ្នាក់តំបន់ និងនៅក្នុងករណីខ្លះជាមួយអាណត្តិទូលំទូលាយ សម្រាប់ស្ថាប័នថ្នាក់តំបន់ទាំងនោះ។ តណានេយ្យភាពនៃអង្គការនានាក៏ត្រូវតែពង្រីកទៅក្នុងក្រុមប្រទេសនានា ក៏ដូចជាក្រុមអ្នកពាក់ព័ន្ធជាច្រើនផងដែរ។

ស្ថាប័ន និងគោលការណ៍នានាដែលមានស្រាប់សម្រាប់អភិបាលកិច្ចអន្តរជាតិ ត្រូវបានបង្កើតឡើង សម្រាប់របៀបរបបពិភពលោកនៅក្នុងពេលមុនដែលមិនស៊ីគ្នាជាមួយស្ថានភាពបច្ចុប្បន្នឡើយ។ ផលវិបាកមួយ គឺថាស្ថាប័នទាំងនេះពុំមានតំណាងក្នុងចំនួនសមស្រប មកពីភូមិភាគខាងត្បូងឡើយ។ ប្រសិនបើត្រូវរក្សាទុកស្ថាប័នទាំងនេះ ត្រូវធ្វើយ៉ាងណាឲ្យស្ថាប័នទាំងនេះមានលក្ខណៈជាតំណាងបានសមស្របជាងមុនប្រកបដោយតម្លាភាព និងមានគណនេយ្យភាព។ ជាក់ស្តែង ដំណើរការអន្តររដ្ឋាភិបាលខ្លះអាចពង្រឹងបានតាមរយៈការចូលរួមនៃតំណាងមកពីភូមិភាគខាងត្បូង ដែលអាចនាំមកជាមួយនូវធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងធនធានមនុស្សជាច្រើន។

នៅក្នុងស្ថានភាពទាំងនេះ រដ្ឋាភិបាលមានការព្រួយបារម្ភ អំពីការរក្សាអធិបតេយ្យភាពជាតិ។ ការផ្សារភ្ជាប់យ៉ាងតឹងរឹងទៅនឹងគោលការណ៍ នៃអធិបតេយ្យភាពជាតិ អាចលើកទឹកចិត្តឲ្យមានការគិតគូរអំពីផលចំណេញ និងការបង់ខាត។ យុទ្ធសាស្រ្តល្អជាងមុនមួយ ត្រូវគិតគូរអំពីអធិបតេយ្យភាព ដែលប្រទេសនានាចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការដោយត្រឹមត្រូវ ផ្អែកលើបទប្បញ្ញត្តិ និងគណនេយ្យភាពអន្តរជាតិ ដោយចូលរួមនៅក្នុងកិច្ចប្រឹងប្រែងរួម ដែលពង្រឹងសុខុមាលភាពពិភពលោក។ អធិបតេយ្យភាពប្រកបដោយការទទួលខុសត្រូវ ក៏ទាមទារផងដែរឲ្យរដ្ឋធានាអំពីសន្តិសុខមនុស្ស និងសុវត្ថិភាពនៃពលរដ្ឋរបស់ខ្លួន។ យោងតាមទស្សនៈនេះ អធិបតេយ្យត្រូវគេមើលឃើញថា មិនត្រឹមតែជាសិទ្ធិមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការទទួលខុសត្រូវផងដែរ។

ពិភពលោកដែលមានការប្រែប្រួលនេះ មានការពាក់ព័ន្ធស៊ីជម្រៅ សម្រាប់ការផ្តល់ផលិតផលសាធារណៈ។ វិស័យដែលជាកង្វល់ជាអន្តរជាតិលើពិភពលោក ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់និងកិច្ចសហប្រតិបត្តិការរួមមានពាណិជ្ជកម្ម ចំណាកស្រុក និងការប្រែប្រួលអាកាសធាតុ។ នៅក្នុងករណីខ្លះ ផលិតផល

សាធារណៈ អាចបង្កើតបានតាមរយៈស្ថាប័ននៅថ្នាក់តំបន់ ដែលអាចជៀសវាងការងាកចេញពីគ្នាដែលពន្យឺតវឌ្ឍនភាព នៅក្នុងវេទិកាពហុភាគីធំៗ។ ទោះជាយ៉ាងណាក៏ដោយ កំណើនកិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាចផ្តល់ផលអវិជ្ជមានផងដែរ ដោយបន្ថែមភាពស្មុគស្មាញនៅច្រើនលំដាប់ថ្នាក់ និងភាពនៅដាច់ពីគ្នានៃស្ថាប័ននានា។ ដូច្នេះ ការប្រឈម គឺត្រូវធានា "ពហុភាពដែលស៊ីសង្វាក់គ្នា" ដើម្បីឲ្យស្ថាប័ននានានៅគ្រប់លំដាប់ថ្នាក់ធ្វើការប្រកបដោយការសម្របសម្រួលរវាងគ្នាបានទូលំទូលាយ។

ស្ថាប័នអភិបាលកិច្ចអន្តរជាតិ ត្រូវតែមានគណនេយ្យភាព មិនត្រឹមតែនៅចំពោះមុខរដ្ឋជាសមាជិកប៉ុណ្ណោះទេ ប៉ុន្តែនៅចំពោះមុខសង្គមស៊ីវិលពិភពលោកផងដែរ។ អង្គការសង្គមស៊ីវិលមានឥទ្ធិពលរួចមកហើយ ទៅលើតម្លាភាពនៅកម្រិតពិភពលោក និងក្នុងការកំណត់បទបញ្ញាអំពីជំនួយ កម្ចី សិទ្ធិមនុស្ស សុខភាព និងការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ បណ្តាញសង្គមស៊ីវិល អាចទាញយកប្រយោជន៍ពីប្រព័ន្ធព័ត៌មានថ្មីៗ និងបច្ចេកវិទ្យាប្រាស្រ័យទាក់ទងថ្មីៗផងដែរ។ ប៉ុន្តែ អង្គការសង្គមស៊ីវិលក៏ប្រឈមនឹងចំណោទអំពីភាពត្រឹមត្រូវ និងគណនេយ្យភាព និងអាចបង្កើតឡើង តាមទម្រង់មិនជាទីចង់បានផងដែរ។ទោះជាយ៉ាងណាក៏ដោយភាពសមស្របទៅអនាគតនៃអភិបាលកិច្ចអន្តរជាតិ អាស្រ័យទៅលើសមត្ថភាពរបស់ស្ថាប័ននានា ក្នុងការចូលរួមជាមួយបណ្តាញពលរដ្ឋ និងសហគមន៍។

## សេចក្តីសន្និដ្ឋាន ៖ ដៃគូក្នុងសម័យកាលថ្មី

ប្រទេសជាច្រើន នៅក្នុងភូមិភាគខាងត្បូង បានបង្ហាញឲ្យឃើញរួចមកហើយ អំពីអ្វីដែលអាចធ្វើបាន ដើម្បីធានាថា ការអភិវឌ្ឍមនុស្សឈានទៅមុខតាមវិធីនានា ដែលនាំមកនូវទាំងផលិតភាព និងនិរន្តរភាព ប៉ុន្តែប្រទេសទាំងនោះទើបសម្រេចបានមួយកម្រិតតែប៉ុណ្ណោះ។ សម្រាប់ច្រើនឆ្នាំទៅមុខទៀត របាយការណ៍នេះលើកស្នើសេចក្តីសន្និដ្ឋានធំៗចំនួនប្រាំ គឺ ៖

### កំណើនកម្លាំងសេដ្ឋកិច្ចនៅភូមិភាគខាងត្បូង ត្រូវតែស៊ីគ្នាជាមួយការប្តេជ្ញាពេញលេញលើការអភិវឌ្ឍមនុស្ស

ការវិនិយោគលើការអភិវឌ្ឍមនុស្ស មានហេតុផលសមស្រប មិនត្រឹមតែលើមូលដ្ឋាននៃក្រមសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែដោយហេតុថា ការវិនិយោគលើការអប់រំ សុខភាព និងសុខុមាលភាពសង្គម ក៏ជាគន្លឹះក្នុងការធ្វើឲ្យមានជោគជ័យនៃសេដ្ឋកិច្ចពិភពលោក ដែលកាន់តែមានភាពប្រកួតប្រជែង និងឌីណាមិកផងដែរ។ ជាក់ស្តែង ការវិនិយោគទាំងនេះ គួរតែផ្តោតលើអ្នកក្រ ដោយផ្សារភ្ជាប់អ្នកទាំងនោះទៅនឹងទីផ្សារ និងបង្កើនឱកាសក្នុងរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ភាពក្រីក្រគឺជាអយុត្តិធម៌ដែលអាច និងគួរតែដោះស្រាយបានតាមរយៈចំណាត់ការប្រកបដោយការប្តេជ្ញា។

ការកសាងគោលនយោបាយល្អ ក៏ទាមទារឲ្យផ្តោតការយកចិត្តទុកដាក់ លើការពង្រឹងសមត្ថភាពសង្គមផងដែរ មិនត្រឹមតែសមត្ថភាពបុគ្គលប៉ុណ្ណោះទេ។ បុគ្គលនានាធ្វើការនៅក្នុងស្ថាប័នសង្គមដែលអាចកំហិត ឬពង្រឹងសក្តានុពលអភិវឌ្ឍរបស់ពួកគេ។ គោលនយោបាយដែលកែប្រែនិយាមសង្គម ដែលរារាំងសក្តានុពលមនុស្ស ដូចជា ការកំហិតប្រឆាំងអាពាហ៍ពិពាហ៍វ័យក្មេង ឬតម្រូវការឲ្យមានចំណង ដៃអាពាហ៍ពិពាហ៍ទាំងអស់នេះ អាចផ្តល់ឱកាសបន្ថែមទៀត សម្រាប់បុគ្គលនានាឈានទៅបញ្ចេញសក្តានុពលរបស់ខ្លួន ឲ្យបានពេញទំហឹង។

### ប្រទេសអភិវឌ្ឍន៍តិចតួច អាចរៀនសូត្រ និងទទួលផលពីជោគជ័យនៃសេដ្ឋកិច្ចលេចធ្លោនៅក្នុងភូមិភាគខាងត្បូង

ការប្រមូលផ្តុំ មិនធ្លាប់មានពីមុនមកនៃធនធានហិរញ្ញវត្ថុ និងមូលនិធិនៅក្នុងដែនអធិបតេយ្យក្នុងភូមិភាគខាងត្បូង ក៏ដូចជាភូមិភាគខាងជើង ផ្តល់ឱកាសសម្រាប់បង្កើនវឌ្ឍនភាពដែលមានមូលដ្ឋានទូលំទូលាយជាងមុន។ សូម្បីការប្រើប្រាស់មូលនិធិនេះតែមួយផ្នែកតូច សម្រាប់ការអភិវឌ្ឍមនុស្ស និងការលុបបំបាត់ភាពក្រីក្រ ក៏វាអាចជះឥទ្ធិពលធំធេងផងដែរ។ ទន្ទឹមនឹងនេះ

ពាណិជ្ជកម្មត្បូង-ត្បូង និងលំហូរនៃការវិនិយោគ អាចបង្កើនទីផ្សារបរទេសតាមវិធីថ្មីៗ ដែលពង្រឹងឱកាសអភិវឌ្ឍន៍ ដូចជាតាមរយៈការចូលរួមនៅក្នុងខ្សែចង្វាក់តម្លៃនៅថ្នាក់តំបន់ និងពិភពលោកផងដែរ។

ពាណិជ្ជកម្មត្បូង-ត្បូង និងជាពិសេសការវិនិយោគ ដែលកំពុងបែកចេញជាខ្នែងច្រើននេះ អាចធ្វើជាមូលដ្ឋាន សម្រាប់ផ្ទេរសមត្ថភាពផលិតទៅតំបន់នានា និងប្រទេសនានាដែលមិនសូវមានការអភិវឌ្ឍ។ ការចូលហ៊ុនជាមួយគ្នារវាងចិន និងឥណ្ឌានៅក្នុងពេលថ្មីៗនេះ និងការចាប់ផ្តើមវិនិយោគលើកម្មន្តសាលនៅអាហ្វ្រិក ផ្តល់ជាលំនាំដើមទៅក្នុងការពង្រីកកម្លាំងច្រើនថែមទៀត។ បណ្តាញផលិតកម្មអន្តរជាតិ ផ្តល់ឱកាសសម្រាប់បង្កើនល្បឿននៃដំណើរការអភិវឌ្ឍន៍ ដោយអនុញ្ញាតឲ្យប្រទេសនានា លោតផ្លោះទៅរកចង្វាក់ផលិតកម្មទំនើបតែម្តង។

ការពូនគរទុនបម្រុងយ៉ាងច្រើនពុំធ្លាប់មានពីមុនមក ផ្តល់កាលានុវត្តភាពសម្រាប់ជំរុញឲ្យមានវឌ្ឍនភាពកាន់តែទូលំទូលាយថែមទៀត

## ស្ថាប័នថ្មី និងភាពជាដៃគូថ្មីៗ អាចសម្រួលដល់សមាហរណកម្មថ្នាក់តំបន់ និងទំនាក់ទំនង ត្បូង-ត្បូង

ស្ថាប័ន និងភាពជាដៃគូថ្មីៗ អាចជួយប្រទេសនានាចែករំលែកចំណេះដឹង បទពិសោធន៍ និងបច្ចេកវិទ្យា។ កិច្ចការនេះអាចធ្វើឡើងតាមរយៈស្ថាប័នថ្មី ដែលរឹងមាំជាងមុន ដើម្បីជំរុញពាណិជ្ជកម្ម និងការវិនិយោគ និងបង្កើនល្បឿននៃការចែករំលែកបទពិសោធន៍ នៅទូទាំងភូមិភាគខាងត្បូង។ ជំហានមួយ គឺត្រូវបង្កើតគណៈកម្មាធិការភូមិភាគខាងត្បូង ដើម្បីនាំមកនូវគំរូចម្រុះថ្មីមួយនៃភូមិភាគត្បូង ដែលអាចជាកម្លាំងមួយដើម្បីសាមគ្គីភាព។

## តំណាងកាន់តែច្រើនសម្រាប់ភូមិភាគខាងត្បូង និងសង្គមស៊ីវិល អាចបង្កើនល្បឿនវឌ្ឍនភាពលើការប្រឈមចម្បងៗរបស់ពិភពលោក

ការឈានឡើងនៃភូមិភាគខាងត្បូង កំពុងនាំទៅរកភាពចម្រុះច្រើនជាងមុន នៃទស្សនៈលើវេទិកាពិភពលោក។ ចំណុចនេះតំណាងឲ្យឱកាសមួយដើម្បីបង្កើតស្ថាប័នអភិបាលកិច្ចដែលតំណាងឲ្យបានពេញលេញនូវមណ្ឌលទាំងអស់ ដែលទាញយកផលពីភាពចម្រុះនេះ នៅក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាពិភពលោក។

គេត្រូវការ ឲ្យមានគោលការណ៍នាំមុខថ្មីៗ សម្រាប់អង្គការអន្តរជាតិ ដែលរួមបញ្ចូលបទពិសោធន៍នានាពីភូមិភាគខាងត្បូង។ ការលេចឡើងនៃក្រុមប្រទេស ២០ គឺជាជំហានសំខាន់មួយនៅក្នុងទិសដៅនេះ ប៉ុន្តែប្រទេសនានាក្នុងភូមិភាគខាងត្បូង ក៏ត្រូវតែមានអ្នកតំណាងដោយសមធម៌ផងដែរនៅក្នុងស្ថាប័ន Bretton Woods, អង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិដទៃទៀត។

សង្គមស៊ីវិលដែលសកម្ម និងចលនាសង្គមទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ កំពុងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្កើនការអំពាវនាវរបស់ពួកគេ ទាមទារឲ្យមានអភិបាលកិច្ចត្រឹមត្រូវ និងយុត្តិធម៌។ ការសាយភាយនៃចលនា និងកំណើននៃវេទិកានានា សម្រាប់ផ្សព្វផ្សាយសារគន្លឹះ និងតម្រូវការចាំបាច់នានា ទាមទារឲ្យស្ថាប័នអភិបាលកិច្ចធ្វើការបន្សុាំទៅនឹងគោលការណ៍ ដែលមានលក្ខណៈប្រជាធិបតេយ្យ និងការរួបរួមគ្នាជាងមុន។ ជាទូទៅ ដើម្បីឲ្យពិភពលោកមួយកាន់តែមានយុត្តិធម៌ជាងមុន និងមិនសូវមានវិសមភាព ទាមទារឲ្យមានលំហសម្រាប់ពហុសម្លេង និងប្រព័ន្ធមួយ សម្រាប់ការសន្ទនាបញ្ចេញយោបល់ជាសាធារណៈ។

## ការឈានឡើងនៃភូមិភាគខាងត្បូង នាំមកនូវឱកាសថ្មីៗសម្រាប់បង្កើតឲ្យមានការផ្គត់ផ្គង់ផលិតផលសាធារណៈច្រើនជាងមុន

ពិភពលោកដែលមាននិរន្តរភាព ទាមទារឲ្យមានការផ្តល់ផលិតផលសេវាសាធារណៈ ពិភព-លោកច្រើនជាងមុន។ បញ្ហាពិភពលោកបច្ចុប្បន្ននេះកំពុងកើនទាំងចំនួន និងភាពបន្ទាន់ ដែលរាប់ចាប់តាំងពីការកាត់បន្ថយ ការប្រែប្រួលអាកាស-ធាតុ និងអស្ថេរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិ រហូតដល់ការប្រយុទ្ធប្រឆាំងភេរវកម្ម និងការសាយភាយអាវុធនុយក្លេអ៊ែរ។ បញ្ហាទាំងនេះ ទាមទារឲ្យមានការឆ្លើយតបជាសកល។ ប៉ុន្តែនៅក្នុងតំបន់ជាច្រើន កិច្ចសហប្រតិបត្តិការអន្តរជាតិនៅតែមានភាពយឺតយ៉ាវ និងច្រើនមានភាពរារែកប្រកបដោយគ្រោះថ្នាក់។ ការឈានឡើងនៃភូមិភាគខាងត្បូង នាំមកនូវឱកាសថ្មីៗក្នុងការផ្តល់នូវផលិតផលសាធារណៈពិភពលោក កាន់តែមានប្រសិទ្ធភាពជាងមុន និងសម្រាប់ដោះស្រាយបញ្ហាពិភពលោកជាច្រើន ដែលកំពុងជាប់គាំងក្នុងពេលបច្ចុប្បន្ននេះ។

ក្នុងករណីច្រើនបំផុត "ភាពជាសាធារណៈ" (Publicness) និង "ភាពជាឯកជន" (Privateness) វាមិនមែនជាកម្មសិទ្ធិពីធម្មជាតិ នៃផលិតផលសាធារណៈឡើយ ប៉ុន្តែជាលទ្ធផលនៃដំណើរវិវត្តន៍សង្គម។ ក្នុងន័យនេះ វាតំណាងឲ្យជម្រើសគោលនយោបាយ។ រដ្ឋាភិបាលថ្នាក់ជាតិអាចចាត់វិធានការ នៅក្នុងករណីពុំមានការផ្តល់បានគ្រប់គ្រាន់នៅថ្នាក់ជាតិ ប៉ុន្តែ នៅពេលការប្រឈមជាសកលលេចឡើង កិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាការចាំបាច់ និងអាចធ្វើទៅបាន តែតាមរយៈសកម្មភាពស្ម័គ្រចិត្តរបស់ បណ្តារដ្ឋាភិបាលតែប៉ុណ្ណោះ។ ដោយសារតែមានភាពប្រឈមបន្ទាន់ច្រើន វឌ្ឍនភាពក្នុងការកំណត់អំពីអ្វីជារបស់សាធារណៈ និងអ្វីជារបស់ឯកជន ទាមទារឲ្យមានភាពដឹកនាំរឹងមាំ និងដោយការប្តេជ្ញាជាបុគ្គលិក និងជាស្ថាប័ន។

*　*　*

*របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣* តំណាងឲ្យបរិបទពិភពលោកសម័យថ្មីនេះ និងត្រួសត្រាយមាគ៌ាមួយ សម្រាប់អ្នកកសាងគោល-នយោបាយ និងពលរដ្ឋ ក្នុងដំណើរឆ្លងកាត់ពិភពលោកមួយ ដែលកាន់តែប្រទាក់ក្រឡាគ្នាខ្លាំងឡើងៗ និងដើម្បីតទល់ជាមួយភាពប្រឈមកាន់តែច្រើនឡើងរបស់ពិភពលោក។ របាយការណ៍នេះអធិប្បាយអំពី ថាតើឌីណាមិកនៃអំណាច ទស្សនៈ និងសម្បត្តិនៅក្នុងពិភពលោក កំពុងប្រែប្រួលបែបណា និងកំណត់អត្តសញ្ញាណគោលនយោបាយ និងស្ថាប័នថ្មីៗ ដែលចាំបាច់សម្រាប់ដោះស្រាយតថភាពនៃសតវត្សរ៍ទី២១ និងជំរុញការអភិវឌ្ឍមនុស្សជាមួយសមធម៌ និរន្តរភាព និងសមាហរណកម្ម សង្គមធំធេងជាងមុន។ វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្ស ទាមទារឲ្យមានចំណាត់ការ និងស្ថាប័នទាំងនៅកម្រិតពិភពលោក និងថ្នាក់ជាតិ។ នៅកម្រិតពិភពលោកកំណែទម្រង់ស្ថាប័ន និងនិម្មិតកម្មថ្មី គឺជាតម្រូវការចាំបាច់ដើម្បីការពារ និងផ្តល់ផលិតផលសេវាសាធារណៈពិភពលោក។ នៅថ្នាក់ជាតិ ការប្តេជ្ញារបស់រដ្ឋដើម្បីឲ្យមានយុត្តិធម៌សង្គម មានសារៈសំខាន់ណាស់ គឺសំខាន់ដូចគ្នានឹងតថភាព ដែលថាដោយសារតែភាពចម្រុះនៃបរិបទជាតិ វប្បធម៌ និងលក្ខខណ្ឌស្ថាប័ន គោលនយោបាយបែបបច្ចេកទេសធិបតេយ្យធ្វើ "គំរូមួយត្រូវគ្រប់កន្លែង" ជារបស់លែងមានភាពប្រាកដនិយម ឬប្រសិទ្ធភាពទៀតហើយ។ ប៉ុន្តែ គោលការណ៍រួម ដូចជាភាពចុះសម្រុងគ្នាក្នុងសង្គម ការប្តេជ្ញារបស់រដ្ឋលើការអប់រំ សុខភាព និងកិច្ចគាំពារសង្គម និងការបើកចំហចំពោះសមាហរណកម្មពាណិជ្ជកម្ម រួមបញ្ចូលគ្នាស្តែងចេញជាមធ្យោបាយមួយ សម្រាប់ដំណើរឆ្ពោះទៅរកការអភិវឌ្ឍមនុស្ស ដោយនិរន្តរភាព និងសមធម៌។

ការឈានឡើងនៃភូមិភាគខាងត្បូង នាំមកនូវឱកាសថ្មីៗក្នុងការផ្តល់ផលិតផលសាធារណៈសកលលោកប្រកបដោយប្រសិទ្ធភាពជាងមុន និងសម្រាប់ដោះស្រាយបញ្ហាពិភពលោកជាច្រើន ដែលកំពុងជាប់គាំងក្នុងពេលបច្ចុប្បន្ននេះ

## លំដាប់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ឆ្នាំ ២០១២ និងការប្រែប្រួលលំដាប់ពីឆ្នាំ ២០១១ ដល់ ២០១២

| | | | |
|---|---|---|---|
| អាហ្វកានីស្ថង់ | ១៧៥ | -១ | |
| អាល់បានី | ៧០ | -១ | ↓ |
| អាល់ហ្សេរី | ៩៣ | -១ | ↓ |
| អង់ដូរ៉ា | ៣៣ | | ↓ |
| អង់ហ្គោឡា | ១៤៨ | -១ | |
| អង់ទីហ្គា និងបារខ្ញូបា | ៦៧ | -១ | ↓ |
| អាហ្សង់ទីន | ៤៥ | -១ | ↓ |
| អាកមេនី | ៨៧ | | ↓ |
| អូស្ត្រាលី | ២ | | |
| អូទ្រីស | ១៨ | -១ | |
| អាហ្សេរបៃហ្សង់ | ៨២ | | ↓ |
| បាហាម៉ាស់ | ៤៩ | | |
| បារេន | ៤៨ | ១ | |
| បង់ក្លាដែស | ១៤៦ | | ↑ |
| បាបាដូស | ៣៨ | ១ | |
| បេឡារូស | ៥០ | | ↑ |
| បែលហ្ស៊ិក | ១៧ | | |
| បេលីហ្ស | ៩៦ | | |
| បេនីន | ១៦៦ | ១ | |
| ប៊ុយតង់ | ១៤០ | | ↑ |
| បូលីវី (សាធារណរដ្ឋពហុជាតិ) | ១០៨ | -១ | |
| បូស្នី និងហេហ្សីហ្គោវីណា | ៨១ | -១ | ↓ |
| បូស្វាណា | ១១៩ | | ↓ |
| ប្រេស៊ីល | ៨៥ | | |
| ប្រ៊ុយណេ ដារូសាឡាំ | ៣០ | | |
| ប៊ុលការី | ៥៧ | | |
| បួគីណា ហ្វាសូ | ១៨៣ | -១ | |
| ប៊ូរុនឌី | ១៧៨ | | ↓ |
| កម្ពុជា | ១៣៨ | | |
| កាមេរូន | ១៥០ | -១ | |
| កាណាដា | ១១ | -១ | ↓ |
| ខេប វែរដ៍ | ១៣២ | -១ | ↓ |
| សាធារណរដ្ឋអាហ្វ្រិកកណ្តាល | ១៨០ | | ↓ |
| ឆាត | ១៨៤ | | |
| ស៊ីលី | ៤០ | | |
| ចិន | ១០១ | | |
| កូឡុំប៊ី | ៩១ | -១ | |
| កូម៉ូរ៉ូស | ១៦៩ | | ↓ |
| កុងហ្គោ | ១៤២ | | |
| កុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យ) | ១៨៦ | | |
| កូស្តារីកា | ៦២ | ១ | |
| កូតឌីវ័រ | ១៦ | -១ | ↑ |
| ក្រូអាទី | ៤៧ | | ↓ |
| គុយបា | ៥៩ | | |
| សាយប្រ៊ីស | ៣១ | | |
| សាធារណរដ្ឋឆែក | ២៨ | | |
| ដាណឺម៉ាក់ | ១៥ | | |
| ជីប៊ូទី | ១៦៤ | | |
| ដូមីនីកា | ៧២ | ២ | |
| សាធារណរដ្ឋដូមីនីកែន | ៩៦ | | ↑ |
| អេក្វាឌ័រ | ៨៩ | | |
| អេហ្ស៊ីប | ១១២ | -១ | |
| អែលសាល់វ៉ាឌ័រ | ១០៧ | | ↓ |
| ហ្គីនេអេក្វាទ័រ | ១៣៦ | ១ | |
| អេរីទ្រា | ១៨១ | ១ | ↑ |
| អេស្តូនី | ៣៣ | -១ | ↑ |
| អេត្យូពី | ១៧៣ | ២ | ↓ |
| ហ្វីជី | ៩៦ | | ↑ |
| ហ្វាំងឡង់ | ២១ | | |
| បារាំង | ២០ | | |
| ហ្គាបុង | ១០៦ | | |
| ហ្គាំប៊ី | ១៦៥ | | |

| | | | |
|---|---|---|---|
| ហ្សកហ្ស៊ី | ៧២ | ៣ | ↑ |
| អាល្លឺម៉ង់ | ៥ | | |
| ហ្គាណា | ១៣៥ | | |
| ក្រិច | ២៩ | | |
| ក្រេណាដា | ៦៣ | -១ | ↓ |
| ហ្គាតេម៉ាឡា | ១៣៣ | | |
| ហ្គីនេ | ១៧៨ | -១ | ↓ |
| ហ្គីនេ-ប៊ីស្សូ | ១៧៦ | | |
| ហ្គូយយ៉ាណា | ១១៨ | ១ | ↑ |
| ហៃទី | ១៦១ | ១ | ↑ |
| ហុងឌុយរ៉ាស | ១២០ | | |
| ហុងកុង (សាធារណរដ្ឋប្រជាមានិតចិន) (SaR) | ១៣ | ១ | ↑ |
| ហុងគ្រី | ៣៧ | | |
| អាយស្លែន | ១៣ | | |
| ឥណ្ឌា | ១៣៦ | | |
| ឥណ្ឌូនេស៊ី | ១២១ | ៣ | ↑ |
| អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម) | ៧៦ | -២ | ↓ |
| អ៊ីរ៉ាក់ | ១៣១ | ១ | ↑ |
| អៀរឡង់ | ៧ | | |
| អ៊ីស្រាអែល | ១៦ | | |
| អ៊ីតាលី | ២៥ | | |
| ចាម៉ៃកា | ៨៥ | -២ | ↓ |
| ជប៉ុន | ១០ | | |
| ហ្សកដង់ | ១០០ | | |
| កាហ្សាក់ស្ថង់ | ៦៩ | -១ | ↓ |
| កេនយ៉ា | ១៤៥ | | |
| គីរីបាទី | ១២១ | | |
| សាធារណរដ្ឋកូរ៉េ | ១២ | | |
| គុយវ៉ែត | ៥៤ | -១ | ↓ |
| គៀរហ្គីស្តង់ | ១២៥ | | |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ១៣៨ | | |
| ឡាតវី | ៤៤ | ១ | ↑ |
| លីបង់ | ៧២ | | |
| ឡេសូថូ | ១៥៨៨ | ១ | ↑ |
| លីបេរី | ១៧៤ | | |
| លីប៊ី | ៦៤ | 23 | ↑ |
| លិចតិនស្តែន | ២៤ | | |
| លីទុយអានី | ៤១ | ២ | ↑ |
| លុចសំបួរ | ២៦ | | |
| ម៉ាដាហ្គាស្កា | ១៥១ | | |
| ម៉ាឡាវី | ១៧០ | ១ | ↑ |
| ម៉ាឡេស៊ី | ៦៣ | ១ | ↑ |
| ម៉ាល់ឌីវ | ១០៤ | -១ | ↓ |
| ម៉ាលី | ១៨២ | -១ | ↓ |
| ម៉ាល់តា | ៣២ | ១ | ↑ |
| ម៉ូរីតានី | ១៥៥ | | |
| ម៉ូរីទុស | ៨០ | -១ | ↓ |
| ម៉ិចស៊ិក | ៦១ | | |
| រដ្ឋសហព័ន្ធមីក្រូនេស៊ី | ១១៧ | | |
| សាធារណរដ្ឋម៉ុលដូវ៉ា | ១១៣ | | |
| ម៉ុងហ្គោលី | ១០៨ | ២ | ↑ |
| ម៉ុងតេនេក្រូ | ៥២ | -២ | ↓ |
| ម៉ារ៉ុក | ១៣០ | | |
| ម៉ូហ្សំប៊ិក | ១៨៥ | | |
| មីយ៉ាន់ម៉ា | ១៤៩ | | |
| ណាមីប៊ី | ១២៨ | | |
| នេប៉ាល់ | ១៥៧ | | |
| ហូឡង់ | ៤ | | |
| នូវែលហ្សេឡង់ | ៦ | | |
| នីការ៉ាហ្គ័រ | ១២៩ | | |
| នីហ្សេរ | ១៨៦ | ១ | ↑ |
| នីហ្សេរីយ៉ា | ១៥៣ | ១ | ↑ |

| | | | |
|---|---|---|---|
| ន័រវេស | ១ | | |
| អូម៉ង់ | ៨៤ | -១ | ↓ |
| ប៉ាគីស្ថង់ | ១៤៦ | | |
| ប៉ាឡៅ | ៥២ | ២ | ↑ |
| រដ្ឋប៉ាឡេស្ទីន | ១១០ | ១ | ↑ |
| ប៉ាណាម៉ា | ៥៩ | ១ | ↑ |
| ប៉ាពូញូហ្គីនេ | ១៥៦ | | |
| ប៉ារ៉ាហ្គាយ | ១១១ | -២ | ↓ |
| ប៉េរូ | ៧៧ | -១ | ↓ |
| ហ្វីលីពីន | ១១៤ | | |
| ប៉ូឡូញ | ៣៩ | | |
| ព័រទុយហ្គាល់ | ៤៣ | -៣ | ↓ |
| កាតា | ៣៦ | | |
| រ៉ូម៉ានី | ៥៦ | -១ | ↓ |
| សហព័ន្ធរុស្ស៊ី | ៥៥ | | |
| រ៉្វាន់ដា | ១៦៧ | | |
| សាំងគីត និងនេវីស | ៧២ | -១ | ↓ |
| សាំងលូសៀរ | ៨៨ | | |
| សាំងវីនសេន និងក្រេណាឌីន | ៨៣ | -២ | ↓ |
| សាម៉ៅ | ៩៦ | | |
| សៅតូម៉េ និងព្រីនស៊ីពេ | ១៤៤ | | |
| អារ៉ាប៊ីសាអ៊ូឌីត | ៥៧ | | |
| សេនេហ្គាល់ | ១៥៤ | -២ | ↓ |
| ស៊ែកប៊ី | ៦៤ | | |
| សីសែល | ៤៦ | | |
| សេរ៉ាលេអូន | ១៧៧ | ២ | ↑ |
| សិង្ហបុរី | ១៨ | | |
| ស្លូវ៉ាគី | ៣៥ | | |
| ស្លូវេនៀ | ២១ | | |
| កោះសូឡូម៉ុង | ១៤៣ | | |
| អាហ្វ្រិកខាងត្បូង | ១២១ | ១ | ↑ |
| អេស្ប៉ាញ | ២៣ | | |
| ស្រីឡង្កា | ៩២ | | |
| ស៊ូដង់ | ១៧១ | -១ | ↓ |
| ស៊ូរីនេម | ១០៥ | | |
| ស្វាស៊ីលែន | ១៤១ | -១ | ↓ |
| ស៊ុយអែដ | ៧ | | |
| ស្វីស | ៩ | | |
| សាធារណរដ្ឋអារ៉ាប់ស៊ីរី | ១១៦ | | |
| តាក់ស៊ីគីស្ថង់ | ១២៥ | ១ | ↑ |
| សហសាធារណរដ្ឋតង់ហ្សានី | ១៥២ | ១ | ↑ |
| ថៃ | ១០៣ | ១ | ↑ |
| អតីតសាធារណរដ្ឋយូហ្គោស្លាវនៃម៉ាសេដូនី | ៧៨ | -២ | ↓ |
| ទីម័រខាងកើត | ១៣៤ | | |
| តូហ្គោ | ១៥៩ | ១ | ↑ |
| តុងហ្គា | ៩៥ | | |
| ទ្រីនីដាត និងតូបាហ្គោ | ៦៧ | -១ | ↓ |
| ទុយនីហ្ស៊ី | ៩៤ | | |
| ទួរគី | ៩០ | | |
| ទួមេនីស្ថង់ | ១០២ | | |
| អ៊ូហ្គាន់ដា | ១៦១ | | |
| អ៊ុយក្រែន | ៧៨ | | |
| សហភាពអារ៉ាប់អេមីរ៉ែត | ៤១ | -១ | ↓ |
| ចក្រភពអង់គ្លេស | ២៦ | | |
| ស.រ.អា | ៣ | -១ | ↓ |
| អ៊ូរូហ្គាយ | ៥១ | | |
| អ៊ូសបេគីស្ថង់ | ១១១៤ | ១ | ↑ |
| វ៉ាណាទូ | ១២៤ | -២ | ↓ |
| វេនេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ារីនៃ) | ៧១ | -១ | ↓ |
| វៀតណាម | ១២៧ | | |
| យេម៉ែន | ១៦០ | -២ | ↓ |
| ហ្សំបៀរ | ១៦៣ | | |
| ហ្ស៊ីមបាវេ | ១៧២ | ១ | ↑ |

សំគាល់ ៖ តួលេខវិជ្ជមាន ឬអវិជ្ជមាន និងសញ្ញាព្រួញ "ឡើង" និង "ចុះ" បង្ហាញពីការប្រែប្រួលកើន ឬថយ នៃលំដាប់ប្រទេសពីឆ្នាំ ២០១១ ដល់ ២០១២ ដោយប្រើប្រាស់ទិន្នន័យ និងវិធីសាស្ត្រមានសង្គតិភាព, គ្មានលេខ គឺមិនប្រែប្រួល។

# សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស

| លំដាប់ HDI | | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | សន្ទស្សន៍ HDI គិតបញ្ចូលវិសមភាព | | សន្ទស្សន៍វិសមភាព យេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រសរុប | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ចំនួន | លំដាប់ | ចំនួន | លំដាប់ | ចំនួន | លំដាប់ |
| **អភិវឌ្ឍន៍មនុស្សខ្ពស់បំផុត** | | | | | | | | |
| ១ | ន័រវ៉េស | ០.៩៥៥ | ០.៨៩៤ | ១ | ០.០៦៥ | ៥ | .. | |
| ២ | អូស្ត្រាលី | ០.៩៣៨ | ០.៨៦៤ | ២ | ០.១១៥ | ១៧ | .. | |
| ៣ | ស.រ.អា | ០.៩៣៧ | ០.៨២១ | ១៦ | ០.២៥៦ | ៤២ | .. | |
| ៤ | ហូឡង់ | ០.៩២១ | ០.៨៥៧ | ៤ | ០.០៤៥ | ១ | .. | |
| ៥ | អាល្លឺម៉ង់ | ០.៩២០ | ០.៨៥៦ | ៥ | ០.០៧៥ | ៦ | .. | |
| ៦ | នូវែលហ្សេឡង់ | ០.៩១៩ | .. | .. | ០.១៦៤ | ៣១ | .. | |
| ៧ | អៀរឡង់ | ០.៩១៦ | ០.៨៥០ | ៦ | ០.១២១ | ១៩ | .. | |
| ៧ | ស៊ុយអែដ | ០.៩១៦ | ០.៨៥៩ | ៣ | ០.០៥៥ | ២ | .. | |
| ៩ | ស្វ៊ីស | ០.៩១៣ | ០.៨៤៩ | ៧ | ០.០៥៧ | ៣ | .. | |
| ១០ | ជប៉ុន | ០.៩១២ | .. | .. | ០.១៣១ | ២១ | .. | |
| ១១ | កាណាដា | ០.៩១១ | ០.៨៣២ | ១៣ | ០.១១៩ | ១៨ | .. | |
| ១២ | សាធារណរដ្ឋកូរ៉េ | ០.៩០៩ | ០.៧៥៨ | ២៨ | ០.១៥៣ | ២៧ | .. | |
| ១៣ | ហុងកុង (សាធារណរដ្ឋប្រជាមានិតចិន) | ០.៩០៦ | .. | .. | .. | .. | .. | |
| ១៤ | អាយស្លែន | ០.៩០៦ | ០.៨៤៨ | ៨ | ០.០៨៩ | ១០ | .. | |
| ១៥ | ដាណឺម៉ាក់ | ០.៩០១ | ០.៨៤៥ | ៩ | ០.០៥៧ | ៣ | .. | |
| ១៦ | អ៊ីស្រាអែល | ០.៩០០ | ០.៧៩០ | ២១ | ០.១៤៤ | ២៥ | .. | |
| ១៧ | បែលហ្ស៊ិក | ០.៨៩៧ | ០.៨២៥ | ១៥ | ០.០៩៨ | ១២ | .. | |
| ១៨ | អូទ្រីស | ០.៨៩៥ | ០.៨៣៧ | ១២ | ០.១០២ | ១៤ | .. | |
| ១៨ | សិង្ហបុរី | ០.៨៩៥ | .. | .. | ០.១០១ | ១៣ | .. | |
| ២០ | បារាំង | ០.៨៩៣ | ០.៨១២ | ១៨ | ០.០៨៣ | ៩ | .. | |
| ២១ | ហ្វាំងឡង់ | ០.៨៩២ | ០.៨៣៩ | ១១ | ០.០៧៥ | ៦ | .. | |
| ២១ | ស្លូវេនៀ | ០.៨៩២ | ០.៨៤០ | ១០ | ០.០៨០ | ៨ | 0.000 | ២០០៣ |
| ២៣ | អេស្ប៉ាញ | ០.៨៨៥ | ០.៧៩៦ | ២០ | ០.១០៣ | ១៥ | .. | |
| ២៤ | លិចធេនស្តេន | ០.៨៨៣ | .. | .. | .. | .. | .. | |
| ២៥ | អ៊ីតាលី | ០.៨៨១ | ០.៧៧៦ | ២៤ | ០.០៩៤ | ១១ | .. | |
| ២៦ | លុចហ្សំបួរ | ០.៨៧៥ | ០.៨១៣ | ១៧ | ០.១៤៩ | ៦ | .. | |
| ២៦ | ចក្រភពអង់គ្លេស | ០.៨៧៥ | ០.៨០២ | ១៩ | ០.២០៥ | ៣៤ | .. | |
| ២៨ | សាធារណរដ្ឋឆែក | ០.៨៧៣ | ០.៨២៦ | ១៤ | ០.១២២ | ២០ | 0.00១ | ២០០២/២០០៣ |
| ២៩ | ក្រិក | ០.៨៦០ | ០.៧៦០ | ២៧ | ០.១៣៦ | ២៣ | .. | |
| ៣០ | ប្រ៊ុយនេ ដារូសាឡាំ | ០.៨៥៥ | .. | .. | .. | .. | .. | |
| ៣១ | សាយប្រឹស | ០.៨៤៨ | ០.៧៥១ | ២៩ | ០.១៣៤ | ២២ | .. | |
| ៣២ | ម៉ាល់តា | ០.៨៤៧ | ០.៧៧៨ | ២៣ | ០.២៣៦ | ៣៩ | .. | |
| ៣៣ | អង់ដូរ៉ា | ០.៨៤៦ | .. | .. | .. | .. | .. | |
| ៣៣ | អេសស្តូនី | ០.៨៤៦ | ០.៧៧០ | ២៥ | ០.១៥៨ | ២៩ | 0.0២៦ | ២០០៣ |
| ៣៥ | ស្លូវ៉ាគី | ០.៨៤០ | ០.៧៨៨ | ២២ | ០.១៧១ | ៣២ | 0.000 | ២០០៣ |
| ៣៦ | កាតា | ០.៨៣៤ | .. | .. | ០.៥៤៦ | ១១៧ | .. | |
| ៣៧ | ហុងគ្រី | ០.៨៣១ | ០.៧៦៩ | ២៦ | ០.២៥៦ | ៤២ | 0.0១៦ | ២០០៣ |
| ៣៨ | បារបាដូស | ០.៨២៥ | .. | .. | ០.៣៤៣ | ៦១ | .. | |
| ៣៩ | ប៉ូឡូញ | ០.៨២១ | ០.៧៤០ | ៣០ | ០.១៤០ | ២៤ | .. | |
| ៤០ | ស៊ីលី | ០.៨១៩ | ០.៦៦៤ | ៤១ | ០.៣៦០ | ៦៦ | .. | |
| ៤១ | លីទុយអានី | ០.៨១៨ | ០.៧២៧ | ៣៣ | ០.១៥៧ | ២៨ | .. | |
| ៤១ | សហភាពអារ៉ាប់អេមីរ៉ែត | ០.៨១៨ | .. | .. | ០.២៤១ | ៤០ | 0.00២ | ២០០៣ |
| ៤៣ | ព័រទុយហ្កាល់ | ០.៨១៦ | ០.៧២៩ | ៣២ | ០.១១៤ | ១៦ | .. | |
| ៤៤ | ឡាទ្វី | ០.៨១៤ | ០.៧២៦ | ៣៥ | ០.២១៦ | ៣៦ | 0.00៦ | ២០០៣ |
| ៤៥ | អាហ្សង់ទីន | ០.៨១១ | ០.៦៥៣ | ៤៣ | ០.៣៨០ | ៧១ | 0.0១១ | ២០០៥ |
| ៤៦ | សីសីល | ០.៨០៦ | .. | .. | .. | .. | .. | |
| ៤៧ | ក្រូអាទី | ០.៨០៥ | ០.៦៨៣ | ៣៩ | ០.១៧៩ | ៣៣ | 0.0១៦ | ២០០៣ |

| ចំណាត់ថ្នាក់ HDI | | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | សន្ទស្សន៍ HDI កែតម្រូវវិសមភាព | | សន្ទស្សន៍វិសមភាព យេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រពហុវិមាត្រ | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ចំនួន | ចំណាត់ថ្នាក់ | ចំនួន | ចំណាត់ថ្នាក់ | ចំនួន | ចំណាត់ថ្នាក់ |
| **ការអភិវឌ្ឍមនុស្សខ្ពស់** | | | | | | | | |
| ៤៨ | បារ៉ែន | ០.៧៩៦ | .. | .. | ០.២៥៨ | ៤៥ | .. | |
| ៤៩ | ហាមាស | ០.៧៩៤ | .. | .. | ០.៣១៦ | ៥៣ | .. | |
| ៥០ | បេឡារុស | ០.៧៩៣ | ០.៧២៧ | ៣៣ | .. | .. | ០.០០០ | ២០០៥ |
| ៥១ | អ៊ុយរ៉ាហ្គាយ | ០.៧៩២ | ០.៦៦២ | ៤២ | ០.៣៦៧ | ៦៩ | ០.០០៦ | ២០០២/២០០៣ |
| ៥២ | ម៉ុងតេនេហ្គ្រូ | ០.៧៩១ | ០.៧៣៣ | ៣១ | .. | .. | ០.០០៦ | ២០០៥/២០០៦ |
| ៥២ | ប៉ាឡៅ | ០.៧៩១ | .. | .. | .. | .. | .. | |
| ៥៤ | គុយវ៉ែត | ០.៧៩០ | .. | .. | ០.២៧៤ | ៤៧ | .. | |
| ៥៥ | សហព័ន្ធរុស្ស៊ី | ០.៧៨៨ | .. | .. | ០.៣១២ | ៥១ | ០.០០៥ | ២០០៣ |
| ៥៦ | រ៉ូម៉ានី | ០.៧៨៦ | ០.៦៨៧ | ៣៨ | ០.៣២៧ | ៥៥ | .. | |
| ៥៧ | ប៊ុលការី | ០.៧៨២ | ០.៧០៤ | ៣៦ | ០.២១៩ | ៣៨ | .. | |
| ៥៧ | អារ៉ាប៊ីសាអូឌីត | ០.៧៨២ | .. | .. | ០.៦៨២ | ១៤៥ | .. | |
| ៥៩ | គុយបា | ០.៧៨០ | .. | .. | ០.៣៥៦ | ៦៣ | .. | |
| ៥៩ | ប៉ាណាម៉ា | ០.៧៨០ | ០.៥៨៨ | ៥៧ | ០.៣០៥ | ១០៨ | .. | |
| ៦១ | ម៉ិចស៊ិក | ០.៧៧៥ | ០.៥៩៣ | ៥៥ | ០.៣៨២ | ៧២ | ០.០១៥ | ២០០៦ |
| ៦២ | កូស្តារីកា | ០.៧៧៣ | ០.៦០៦ | ៥៤ | ០.៣៤៦ | ៦២ | .. | |
| ៦៣ | ក្រើណាដា | ០.៧៧០ | .. | .. | .. | .. | .. | |
| ៦៤ | លីប៊ី | ០.៧៦៩ | .. | .. | ០.២១៦ | ៣៦ | .. | |
| ៦៤ | ម៉ាឡេស៊ី | ០.៧៦៩ | .. | .. | ០.២៥៦ | ៤២ | .. | |
| ៦៤ | ស៊ែកប៊ី | ០.៧៦៩ | ០.៦៩៦ | ៣៧ | .. | .. | ០.០០៣ | ២០០៥/២០០៦ |
| ៦៧ | អង់ទីហ្គា និងបាប៊ុយដា | ០.៧៦០ | .. | .. | .. | .. | .. | |
| ៦៧ | ទ្រីនីដាត និងតូបាហ្គោ | ០.៧៦០ | ០.៦៤៤ | ៤៩ | ០.៣១១ | ៥០ | ០.០២០ | ២០០៦ |
| ៦៩ | កាហ្សាក់ស្តង់ | ០.៧៥៤ | ០.៦៥២ | ៤៤ | ០.៣១២ | ៥១ | ០.០០២ | ២០០៦ |
| ៧០ | អាល់បានី | ០.៧៤៩ | ០.៦៤៥ | ៤៨ | ០.២៥១ | ៤១ | ០.០០៥ | ២០០៨/២០០៩ |
| ៧១ | សាធារណរដ្ឋបូលីវ៉ា និងវេនេហ្ស៊ុអេឡា | ០.៧៤៨ | ០.៦៤៩ | ៦៦ | ០.៤៦៦ | ៩៣ | .. | |
| ៧២ | ដូមីនីកា | ០.៧៤៥ | .. | .. | .. | .. | .. | |
| ៧២ | ហ្សកហ្ស៊ី | ០.៧៤៥ | ០.៦៣១ | ៥១ | ០.៤៣៨ | ៨១ | ០.០០៣ | ២០០៥ |
| ៧២ | លីបង់ | ០.៧៤៥ | ០.៥៧៥ | ៥៩ | ០.៤៣៣ | ៧៨ | .. | |
| ៧២ | សាំងគីត និងណេវីស | ០.៧៤៥ | .. | .. | .. | .. | .. | |
| ៧៦ | សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ | ០.៧៤២ | .. | .. | ០.៤៩៦ | ១០៧ | .. | |
| ៧៧ | ប៉េរូ | ០.៧៤១ | ០.៥៦១ | ៦២ | ០.៣៨៧ | ៧៣ | ០.០៦៦ | ២០០៨ |
| ៧៨ | អតីតសាធារណរដ្ឋយូហ្គោស្លាវនៃម៉ាសេដូនី | ០.៧៤០ | ០.៦៣១ | ៥១ | ០.១៦២ | ៣០ | ០.០០៨ | ២០០៥ |
| ៧៨ | អ៊ុយក្រែន | ០.៧៤០ | ០.៦៧២ | ៤០ | ០.៣៣៨ | ៥៧ | ០.០០៨ | ២០០៧ |
| ៨០ | ម៉ូរីទុស | ០.៧៣៧ | ០.៦៣៩ | ៥០ | ០.៣៧៧ | ៧០ | .. | |
| ៨១ | បូស្នៀ និងហឺស៊ីហ្គោវីណា | ០.៧៣៥ | ០.៦៥០ | ៤៥ | .. | .. | ០.០០៣ | ២០០៦ |
| ៨២ | អាហ្សែបៃហ្សង់ | ០.៧៣៤ | ០.៦៥០ | ៤៥ | ០.៣២៣ | ៥៤ | ០.០២១ | ២០០៦ |
| ៨៣ | សាំងវីនសេន និងក្រើណាឌីន | ០.៧៣៣ | .. | .. | .. | .. | .. | |
| ៨៤ | អូម៉ង់ | ០.៧៣១ | .. | .. | ០.៣៤០ | ៥៩ | .. | |
| ៨៥ | ប្រេស៊ីល | ០.៧៣០ | ០.៥៣១ | ៧០ | ០.៤៤៧ | ៨៥ | ០.០១១ | ២០០៦ |
| ៨៥ | ចាម៉ៃកា | ០.៧៣០ | ០.៥៩១ | ៥៦ | ០.៤៥៨ | ៨៧ | .. | |
| ៨៧ | អាកមេនី | ០.៧២៩ | ០.៦៤៩ | ៤៧ | ០.៣៤០ | ៥៩ | ០.០០១ | ២០១០ |
| ៨៨ | សាំងលូស៊ី | ០.៧២៥ | .. | .. | .. | .. | .. | |
| ៨៩ | អេក្វាឌ័រ | ០.៧២៤ | ០.៥៣៧ | ៦៩ | ០.៤៤២ | ៨៣ | ០.០០៩ | ២០០៣ |
| ៩០ | ទួរគី | ០.៧២២ | ០.៥៦០ | ៦៣ | ០.៣៦៦ | ៦៨ | ០.០២៨ | ២០០៣ |
| ៩១ | កូឡុំប៊ី | ០.៧១៩ | ០.៥១៩ | ៧៤ | ០.៤៥៩ | ៨៨ | ០.០២២ | ២០១០ |
| ៩២ | ស្រីលង្កា | ០.៧១៥ | ០.៦០៧ | ៥៣ | ០.៤០២ | ៧៥ | ០.០២១ | ២០០៣ |
| ៩៣ | អាល់ហ្សេរី | ០.៧១៣ | .. | .. | ០.៣៩១ | ៧៤ | .. | |
| ៩៤ | ទុយនីហ្ស៊ី | ០.៧១២ | .. | .. | ០.២៦១ | ៦ | ០.០១០ | ២០០៣ |

| លំដាប់ HDI | | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | សន្ទស្សន៍ HDI គិតបញ្ចូលវិសមភាព | | សន្ទស្សន៍វិសមភាព យេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រសរុប | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ចំនួន | លំដាប់ | ចំនួន | លំដាប់ | ចំនួន | លំដាប់ |
| **អភិវឌ្ឍមនុស្សមធ្យម** | | | | | | | | |
| ៩៥ | តុងហ្គា | ០.៧១០ | .. | .. | ០.៤៦២ | ៩០ | .. | |
| ៩៦ | បេលីស | ០.៧០២ | .. | .. | ០.៤៣៥ | ៧៩ | ០.០២៤ | ២០០៦ |
| ៩៦ | សាធារណរដ្ឋដូមីនីកែន | ០.៧០២ | ០.៥១០ | ៨០ | ០.៥០៨ | ១០៩ | ០.០១៨ | ២០០៧ |
| ៩៦ | ហ្វីជី | ០.៧០២ | .. | .. | .. | .. | .. | |
| ៩៦ | សាម៉ៅ | ០.៧០២ | .. | .. | .. | .. | .. | |
| ១០០ | ហ្ស៊កដង់ | ០.៧០០ | ០.៥៦៨ | ៦០ | ០.៤៨២ | ៩៩ | ០.០០៨ | ២០០៩ |
| ១០១ | ចិន | ០.៦៩៩ | ០.៥៤៣ | ៦៧ | ០.២១៣ | ៣៥ | ០.០៥៦ | ២០០២ |
| ១០២ | ទួមេនីគីស្តង់ | ០.៦៩៨ | .. | .. | .. | .. | .. | |
| ១០៣ | ថៃ | ០.៦៩០ | ០.៥៤៣ | ៦៧ | ០.៣៦០ | ៦៦ | ០.០០៦ | ២០០៥/២០០៦ |
| ១០៤ | ម៉ាល់ឌីវ | ០.៦៨៨ | ០.៥១៥ | ៧៦ | ០.៣៥៧ | ៦៤ | ០.០១៨ | ២០០៩ |
| ១០៥ | ស៊ូរីនេម | ០.៦៨៤ | ០.៥២៦ | ៧២ | ០.៤៦៧ | ៩៤ | ០.០៣៩ | ២០០៦ |
| ១០៦ | ហ្គាបុង | ០.៦៨៣ | ០.៥៥០ | ៦៥ | ០.៤៩២ | ១០៥ | .. | |
| ១០៧ | អែលសាល់វ៉ាឌ័រ | ០.៦៨០ | ០.៤៩៩ | ៨៣ | ០.៤៤១ | ៨២ | .. | |
| ១០៨ | រដ្ឋពហុជាតិនៃបូលីវី | ០.៦៧៥ | ០.៤៤៤ | ៨៥ | ០.៤៧៤ | ៩៧ | ០.០៨៩ | ២០០៨ |
| ១០៨ | ម៉ុងហ្គោលី | ០.៦៧៥ | ០.៥៦៨ | ៦០ | ០.៣២៨ | ៥៦ | ០.០៦៥ | ២០០៥ |
| ១១០ | រដ្ឋប៉ាលេស្ទីន | ០.៦៧០ | .. | .. | .. | .. | ០.០០៥ | ២០០៦/២០០៧ |
| ១១១ | ប៉ារ៉ាហ្គាយ | ០.៦៦៩ | .. | .. | ០.៤៧២ | ៩៥ | ០.០៦៤ | ២០០២/២០០៣ |
| ១១២ | អេហ្ស៊ីប | ០.៦៦២ | ០.៥០៣ | ៨២ | ០.៥៩០ | ១២៦ | ០.០២៤ | ២០០៨ |
| ១១៣ | សាធារណរដ្ឋម៉ុលដូវ៉ា | ០.៦៦០ | ០.៥៨៤ | ៥៨ | ០.៣០៣ | ៤៩ | ០.០០៧ | ២០០៥ |
| ១១៤ | ហ្វីលីពីន | ០.៦៥៤ | ០.៥២៤ | ៧៣ | ០.៤១៨ | ៧៧ | ០.០៦៤ | ២០០៨ |
| ១១៤ | អ៊ូស្បេគីស្តង់ | ០.៦៥៤ | ០.៥៥១ | ៦៤ | .. | .. | ០.០០៨ | ២០០៦ |
| ១១៦ | សាធារណរដ្ឋអារ៉ាប់ស៊ីរី | ០.៦៤៨ | ០.៥១៥ | ៧៦ | ០.៥៥១ | ១១៨ | ០.០២១ | ២០០៦ |
| ១១៧ | រដ្ឋសហព័ន្ធមីក្រូនេស៊ី | ០.៦៤៥ | .. | .. | .. | .. | .. | |
| ១១៨ | ហ្គុយយ៉ាណា | ០.៦៣៦ | ០.៥១៤ | ៧៨ | ០.៤៥០ | ១០៤ | ០.០៣០ | ២០០៩ |
| ១១៩ | បូស្វាណា | ០.៦៣៤ | .. | .. | ០.៤៨៥ | ១០២ | .. | |
| ១២០ | ហុងឌុយរ៉ាស | ០.៦៣២ | ០.៤៥៨ | ៨៤ | ០.៤៨៣ | ១០០ | ០.១៥៩ | ២០០៥/២០០៦ |
| ១២១ | ឥណ្ឌូនេស៊ី | ០.៦២៩ | ០.៥១៤ | ៧៨ | ០.៤៩៤ | ១០៦ | ០.០៩៥ | ២០០៧ |
| ១២១ | គីរីបាទី | ០.៦២៩ | .. | .. | .. | .. | .. | |
| ១២១ | អាហ្វ្រិកខាងត្បូង | ០.៦២៩ | .. | .. | ០.៤៦២ | ៩០ | ០.០៥៧ | ២០០៨ |
| ១២៤ | វ៉ាណាទូ | ០.៦២៦ | .. | .. | .. | .. | ០.១២៩ | ២០០៧ |
| ១២៥ | គៀហ្ស៊ីស្តង់ | ០.៦២២ | ០.៥១៦ | ៧៥ | ០.៣៥៧ | ៦៤ | ០.០១៩ | ២០០៥/២០០៦ |
| ១២៥ | តាជីគីស្តង់ | ០.៦២២ | ០.៥០៧ | ៨១ | ០.៣៣៨ | ៥៧ | ០.០៦៨ | ២០០៥ |
| ១២៧ | វៀតណាម | ០.៦១៧ | ០.៥៣១ | ៧០ | ០.២៩៩ | ៤៨ | ០.០១៧ | ២០១០/២០១១ |
| ១២៨ | ណាមីប៊ី | ០.៦០៨ | ០.៣៤៤ | ១០១ | ០.៤៥៥ | ៨៦ | ០.១៨៧ | ២០០៦/២០០៧ |
| ១២៩ | នីការ៉ាហ្គ័រ | ០.៥៩៩ | ០.៤៣៤ | ៨៦ | ០.៤៦១ | ៨៩ | ០.១២៨ | ២០០៦/២០០៧ |
| ១៣០ | ម៉ារ៉ុក | ០.៥៩១ | ០.៤១៥ | ៨៨ | ០.៤៤៤ | ៨៤ | ០.០៤៨ | ២០០៧ |
| ១៣១ | អ៊ីរ៉ាក់ | ០.៥៩០ | .. | .. | ០.៥៥៧ | ១២០ | ០.០៥៩ | ២០០៦ |
| ១៣២ | ខេប វែរដ៍ | ០.៥៨៦ | .. | .. | .. | .. | .. | |
| ១៣៣ | ហ្គាតេម៉ាឡា | ០.៥៨១ | ០.៣៨៩ | ៩២ | ០.៥៣៩ | ១១៤ | ០.១២៧ | ២០០៣ |
| ១៣៤ | ទីម័រខាងកើត | ០.៥៧៦ | ០.៣៨៦ | ៩៣ | .. | .. | ០.៣៦០ | ២០០៩/២០១០ |
| ១៣៥ | ហ្គាណា | ០.៥៥៨ | ០.៣៧៩ | ៩៤ | ០.៥៦៥ | ១២១ | ០.១៤៤ | ២០០៨ |
| ១៣៦ | ហ្គីនេអេក្វាទ័រ | ០.៥៥៤ | .. | .. | .. | .. | .. | |
| ១៣៦ | ឥណ្ឌា | ០.៥៥៤ | ០.៣៩២ | ៩១ | ០.៦១០ | ១៣២ | ០.២៨៣ | ២០០៥/២០០៦ |
| ១៣៨ | កម្ពុជា | ០.៥៤៣ | ០.៤០២ | ៩០ | ០.៤៧៣ | ៩៦ | ០.២១២ | ២០១០ |
| ១៣៨ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ០.៥៤៣ | ០.៤០៩ | ៨៩ | ០.៤៨៣ | ១០០ | ០.២៦៧ | ២០០៦ |
| ១៤០ | ប៊ូតង់ | ០.៥៣៨ | ០.៤៣០ | ៨៧ | ០.៤៦៤ | ៩២ | ០.១១៩ | ២០១០ |
| ១៤១ | ស្វាស៊ីឡែន | ០.៥៣៦ | ០.៣៤៦ | ៩៩ | ០.៥២៥ | ១១២ | ០.០៨៦ | ២០១០ |

| លំដាប់ HDI | | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | សន្ទស្សន៍ HDI គិតបញ្ចូលវិសមភាព | | សន្ទស្សន៍វិសមភាព យេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រសរុប | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ចំនួន | លំដាប់ | ចំនួន | លំដាប់ | ចំនួន | លំដាប់ |
| **ការអភិវឌ្ឍមនុស្សទាប** | | | | | | | | |
| ១៤២ | កុងហ្គោ | ០.៥៣៤ | ០.៣៦៨ | ៩៦ | ០.៦១០ | ១៣២ | ០.២០៨ | ២០០៩ |
| ១៤៣ | កោះសូឡូម៉ុង | ០.៥៣០ | .. | .. | .. | .. | .. | |
| ១៤៤ | សាវតូមេ និងព្រីនស៊ីពេ | ០.៥២៥ | ០.៣៥៨ | ៩៧ | .. | .. | ០.១៥៤ | ២០០៨/២០០៩ |
| ១៤៥ | កេនយ៉ា | ០.៥១៩ | ០.៣៤៤ | ១០១ | ០.៦០៨ | ១៣០ | ០.២២៩ | ២០០៨/២០០៩ |
| ១៤៦ | បង់ក្លាដែស | ០.៥១៥ | ០.៣៧៤ | ៩៥ | ០.៥១៨ | ១១១ | ០.២៩២ | ២០០៧ |
| ១៤៦ | ប៉ាគីស្ថង់ | ០.៥១៥ | ០.៣៥៦ | ៩៨ | ០.៥៦៧ | ២៣ | ០.២៦៤ | ២០០៦/២០០៧ |
| ១៤៨ | អង់ហ្គោឡា | ០.៥០៨ | ០.២៨៥ | ១១៤ | .. | .. | .. | |
| ១៤៩ | មីយ៉ាន់ម៉ា | ០.៤៩៨ | .. | .. | ០.៤៣៧ | ៨០ | .. | |
| ១៥០ | កាមេរូន | ០.៤៩៥ | ០.៣៣០ | ១០៤ | ០.៦២៨ | ១៣៧ | ០.២៨៧ | ២០០៤ |
| ១៥១ | ម៉ាដាហ្គាស្កា | ០.៤៨៣ | ០.៣៣៥ | ១០៣ | .. | .. | ០.៣៥៧ | ២០០៨/២០០៩ |
| ១៥២ | សហភាពសាធារណរដ្ឋតង់ហ្សានៀរ | ០.៤៧៦ | ០.៣៤៦ | ៩៩ | ០.៥៥៦ | ១១៩ | ០.៣៣២ | ២០១០ |
| ១៥៣ | នីហ្សេរីយ៉ា | ០.៤៧១ | ០.២៧៦ | ១១៩ | .. | .. | ០.៣១០ | ២០០៨ |
| ១៥៤ | សេនេហ្គាល់ | ០.៤៧០ | ០.៣១៥ | ១០៥ | ០.៥៤០ | ១១៥ | ០.៤៣៩ | ២០១០/២០១១ |
| ១៥៥ | ម៉ូរីតានីញ៉ា | ០.៤៦៧ | ០.៣០៦ | ១០៧ | ០.៦៤៣ | ១៣៩ | ០.៣៥២ | ២០០៧ |
| ១៥៦ | ប៉ាពួញូហ្គីនេ | ០.៤៦៦ | .. | .. | ០.៦១៧ | ១៣៤ | .. | |
| ១៥៧ | នេប៉ាល់ | ០.៤៦៣ | ០.៣០៤ | ១០៩ | ០.៤៨៥ | ១០២ | ០.២១៧ | ២០១១ |
| ១៥៨ | ឡេសូថូ | ០.៤៦១ | ០.២៩៦ | ១១ | ០.៥៣៤ | ១១៣ | ០.១៥៦ | ២០០៩ |
| ១៥៩ | តូហ្គោ | ០.៤៥៩ | ០.៣០៥ | ១០៨ | ០.៥៦៦ | ១២២ | ០.២៨៤ | ២០០៦ |
| ១៦០ | យេម៉ែន | ០.៤៥៨ | ០.៣១០ | ១០៦ | ០.៧៤៧ | ១៤៨ | ០.២៨៣ | ២០០៦ |
| ១៦១ | ហៃទី | ០.៤៥៦ | ០.២៧៣ | ១២០ | ០.៥៩២ | ១២៧ | ០.២៩៩ | ២០០៥/២០០៦ |
| ១៦១ | យូហ្គង់ដា | ០.៤៥៦ | ០.៣០៣ | ១១០ | ០.៥១៧ | ១១០ | ០.៣៦៧ | ២០១១ |
| ១៦៣ | ហ្សំប៊ី | ០.៤៤៨ | ០.២៨៣ | ១១៧ | ០.៦២៣ | ១៣៦ | ០.៣២៨ | ២០០៧ |
| ១៦៤ | ជីប៊ូទី | ០.៤៤៥ | ០.២៨៥ | ១១៤ | .. | .. | ០.១៣៩ | ២០០៦ |
| ១៦៥ | ហ្កាំប៊ី | ០.៤៣៩ | .. | .. | ០.៥៩៤ | ១២៨ | ០.៣២៤ | ២០០៥/២០០៦ |
| ១៦៦ | បេនីន | ០.៤៣៦ | ០.២៨០ | ១១៨ | ០.៦១៨ | ១៣៥ | ០.៤១២ | ២០០៦ |
| ១៦៧ | រ៉្វាន់ដា | ០.៤៣៤ | ០.២៨៧ | ១១២ | ០.៤១៤ | ៧៦ | ០.៣៥០ | ២០១០ |
| ១៦៨ | កូដឌីវ័រ | ០.៤៣២ | ០.២៦៥ | ១២២ | ០.៦៣២ | ១៣៨ | ០.៣៥៣ | ២០០៥ |
| ១៦៩ | កូម៉ូរ៉ូស | ០.៤២៩ | .. | .. | .. | .. | .. | |
| ១៧០ | ម៉ាឡាវី | ០.៤១៨ | ០.២៨៧ | ១១២ | ០.៥៧៣ | ១២៤ | ០.៣៣៤ | ២០១០ |
| ១៧១ | ស៊ូដង់ | ០.៤១៤ | .. | .. | ០.៦០៤ | ១២៩ | .. | |
| ១៧២ | ហ្ស៊ីមបាវ៉េ | ០.៣៩៧ | ០.២៨៤ | ១១៦ | ០.៥៤៤ | ១១៦ | ០.១៧២ | ២០០១០/២០១១ |
| ១៧៣ | អេត្យូពី | ០.៣៩៦ | ០.២៦៩ | ១២១ | .. | .. | ០.៥៦៤ | ២០១១ |
| ១៧៤ | លីបេរីយ៉ា | ០.៣៨៨ | ០.២៥១ | ១២៣ | ០.៦៥៨ | ១៤៣ | ០.៤៨៥ | ២០០៧ |
| ១៧៥ | អាហ្វកានីស្ថង់ | ០.៣៧៤ | .. | .. | ០.៧១២ | ១៤៧ | .. | |
| ១៧៦ | ហ្គីនេប៊ីសូ | ០.៣៦៤ | ០.២១៣ | ១២៧ | .. | .. | .. | |
| ១៧៧ | សេរ៉ាឡេអូន | ០.២៥៩ | ០.២១០ | ១២៨ | ០.៦៤៣ | ១៣៩ | ០.៤៣៩ | ២០០៨ |
| ១៧៨ | ប៊ូរុនឌី | ០.៣៥៥ | .. | .. | ០.៤៧៦ | ៩៨ | ០.៥៣០ | ២០០៥ |
| ១៧៨ | ហ្គីនេ | ០.៣៥៥ | ០.២១៧ | ១២៦ | .. | .. | ០.៥០៦ | ២០០៥ |
| ១៨០ | សាធារណរដ្ឋអាហ្វ្រិកកណ្ដាល | ០.៣៥២ | ០.២០៩ | ១២៩ | ០.៦៥៤ | ១៤២ | .. | |
| ១៨១ | អេរីទ្រា | ០.៣៥១ | .. | .. | .. | .. | .. | |
| ១៨២ | ម៉ាលី | ០.៣៤៤ | .. | .. | ០.៦៤៩ | ១៤១ | ០.៥៥៨ | ២០០៦ |
| ១៨៣ | ប៊ួគីណាហ្វាសូ | ០.៣៤៣ | ០.២២៦ | ១២៤ | ០.៦០៩ | ១៣១ | ០.៥៣៥ | ២០១០ |
| ១៨៤ | ឆាត | ០.៣៤០ | ០.២០៣ | ១៣០ | .. | .. | ០.៣៤៤ | ២០០៣ |
| ១៨៥ | ម៉ូហ្សំប៊ិក | ០.៣២៧ | ០.២២០ | ១២៥ | ០.៥៨២ | ១២៥ | ០.៥១២ | ២០០៩ |
| ១៨៦ | សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ | ០.៣០៤ | ០.១៨៣ | ១៣២ | ០.៦៨១ | ១៤៤ | ០.៣៩២ | ២០១០ |
| ១៨៦ | នីហ្សេរ | ០.៣០៤ | ០.២០០ | ១៣១ | ០.៧០៧ | ១៤៦ | ០.៦៤២ | ២០០៦ |

| | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | សន្ទស្សន៍ HDI គិតបញ្ចូលវិសមភាព | | សន្ទស្សន៍វិសមភាព យេនឌ័រ | | សន្ទស្សន៍ភាពក្រីក្រសរុប | |
|---|---|---|---|---|---|---|---|
| លំដាប់ HDI | ចំនួន | ចំនួន | លំដាប់ | ចំនួន | លំដាប់ | ចំនួន | លំដាប់ |
| **ប្រទេស ឬដែនដីដទៃទៀត** | | | | | | | |
| សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ | .. | .. | .. | .. | .. | .. | |
| កោះម៉ាសាល់ | .. | .. | .. | .. | .. | .. | |
| ម៉ូណាកូ | .. | .. | .. | .. | .. | .. | |
| ណៅរូ | .. | .. | .. | .. | .. | .. | |
| សានម៉ារីណូ | .. | .. | .. | .. | .. | .. | |
| សូម៉ាលី | .. | .. | .. | .. | .. | 0.៥១៤ | ២០០៦ |
| ស៊ូដង់ខាងត្បូង | .. | .. | .. | .. | .. | .. | |
| ទូវ៉ាលូ | .. | .. | .. | .. | .. | .. | |
| **ក្រុមសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស** | | | | | | | |
| អភិវឌ្ឍន៍មនុស្សខ្ពស់បំផុត | 0.៩០៥ | 0.៨០៧ | — | 0.១៩៣ | — | — | |
| អភិវឌ្ឍន៍មនុស្សខ្ពស់ | 0.៧៥៨ | 0.៦០២ | — | 0.៣៧៦ | — | — | |
| អភិវឌ្ឍន៍មនុស្សមធ្យម | 0.៦៤០ | 0.៤៨៥ | — | 0.៤៥៧ | — | — | |
| អភិវឌ្ឍន៍មនុស្សទាប | 0.៤៦៦ | 0.៣១០ | — | 0.៥៧៨ | — | — | |
| **តំបន់** | | | | | | | |
| រដ្ឋអារ៉ាប់ | 0.៦៥២ | 0.៤៨៦ | — | 0.៥៥៥ | — | — | |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក | 0.៦៨៣ | 0.៥៣៧ | — | 0.៣៣៣ | — | — | |
| អឺរ៉ុប និងអាស៊ីកណ្តាល | 0.៧៧១ | 0.៦៧២ | — | 0.២៨០ | — | — | |
| អាមេរិកឡាទីននិងការ៉ាអ៊ីប | | | | | | | |
| 0.៧៤១ | 0.៥៥០ | — | 0.៤១៩ | — | — | | |
| អាស៊ីខាងត្បូង | 0.៥៥៨ | 0.៣៩៥ | — | 0.៥៦៨ | — | — | |
| សាហារ៉ាក្បែរអាហ្វ្រិក | 0.៤៧៥ | 0.៣០៩ | — | 0.៥៧៧ | — | — | |
| **ប្រទេសអភិវឌ្ឍន៍តិចតួច** | 0.៤៤៩ | 0.៣០៣ | — | 0.៥៦៦ | — | | |
| **រដ្ឋកំពុងអភិវឌ្ឍន៍លើកោះតូចៗ** | 0.៦៤៨ | 0.៤៥៩ | — | 0.៤៨១ | — | | |
| **ពិភពលោក** | **0.៦៩៤** | **0៥៣២** | — | **0.៤៦៣** | — | | |

### សំគាល់៖

សន្ទស្សន៍ទាំងនេះ ប្រើប្រាស់ទិន្នន័យឆ្នាំខុសៗគ្នា — សូមអានឧបសម្ព័ន្ធស្ថិតិ នៅក្នុងរបាយការណ៍ពិស្តារ (ដែលមាននៅក្នុង http://hdr.undp.org) ដែលមានព័ត៌មានពិស្តារ និងកំណត់សំគាល់ពេញលេញ និងប្រភពទិន្នន័យទាំងនេះ។ ចំណាត់ក្រុមប្រទេសបានផ្អែកលើកម្រិត ២៥% ៖ ប្រទេសណាមួយអាចស្ថិតនៅក្នុងក្រុមដែលមានការអភិវឌ្ឍមនុស្សខ្ពស់បំផុត ប្រសិនបើមាន HDI នៅក្នុង ២៥% ខ្ពស់ជាងគេ, នៅក្នុងក្រុមខ្ពស់ ប្រសិនបើមាន HDI ក្នុងចន្លោះ ៥១-៧៥%, កម្រិតមធ្យម ប្រសិនបើមាន HDI ក្នុងចន្លោះ ២៦-៥០% និង ក្នុងក្រុមទាប ប្រសិនបើតួលេខ HDI នៅក្នុងក្រុម ២៥% ទាបជាងគេ។ របាយការណ៍មុនៗបានប្រើប្រាស់តួលេខដាច់ខាត តែមិនមែនតួលេខគោលធៀបឡើយ។

**របាយការណ៍អភិវឌ្ឍន៍មនុស្សកម្រិតពិភពលោក ៖** របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣ គឺជារបាយការណ៍ចុងក្រោយនៅក្នុងចំណោមរបាយការណ៍អភិវឌ្ឍន៍មនុស្សកម្រិតពិភពលោក ដែលបានចេញផ្សាយជាបន្តបន្ទាប់ដោយយូអិនឌីភី ចាប់តាំងពីឆ្នាំ ១៩៩០ មក ដែលជាការវិភាគឯករាជ្យ ដោយសំអាងលើបទពិសោធន៍អំពីបញ្ហា និន្នាការ និងគោលនយោបាយអភិវឌ្ឍន៍ចម្បងៗ។

ប្រភពដទៃទៀត ដែលទាក់ទងនឹងរបាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣ អាចមាននៅក្នុងវិបសាយ hdr.undp.org ដែលរួមទាំងរបាយការណ៍ពិស្តារ ឬរបាយការណ៍សង្ខេបក្នុងជាង ២០ ភាសាខុសៗគ្នា ឯកសារស្រាវជ្រាវនានា អំពីការអភិវឌ្ឍមនុស្ស ដែលបានធ្វើឡើងសម្រាប់ការរៀបរៀងរបាយការណ៍ឆ្នាំ ២០១៣ ផែនទី និងកម្រងទិន្នន័យអំពីសូចនាករអភិវឌ្ឍន៍មនុស្សថ្នាក់ជាតិ សេចក្ដីពន្យល់ពេញលេញអំពីប្រភព និងវិធីសាស្ត្រ ដែលប្រើប្រាស់សម្រាប់សន្ទស្សន៍អភិវឌ្ឍន៍មនុស្សក្នុងរបាយការណ៍នេះ សេចក្ដីអធិប្បាយអំពីស្ថានភាពរបស់ប្រទេសនានា និងឯកសារសាវតារដទៃទៀត។ របាយការណ៍អភិវឌ្ឍន៍មនុស្សកម្រិតពិភពលោក តំបន់ និងជាតិ ដែលបានចេញផ្សាយកន្លងមកមាននៅក្នុងវិបសាយ hdr.undp.org ។

**របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់តំបន់ ៖** នៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ របាយការណ៍អភិវឌ្ឍន៍មនុស្សត្រូវបានរៀបរៀងឡើងដោយពីដំបូងបានផ្ដោតលើវិស័យចម្បងៗចំនួនបួននៃប្រទេសកំពុងអភិវឌ្ឍន៍ និងមានការគាំទ្រពីការិយាល័យយូអិនឌីភីថ្នាក់តំបន់។ តាមរយៈការវិភាគគួរឲ្យចាប់អារម្មណ៍ និងអនុសាសន៍ គោលនយោបាយច្បាស់លាស់ របាយការណ៍ទាំងនោះបានពិនិត្យមើលបញ្ហាសំខាន់ៗ ដូចជាការពង្រឹងសិទ្ធិអំណាចខាងនយោបាយនៅបណ្ដារដ្ឋអារ៉ាប់ សន្តិសុខស្បៀងនៅអាហ្វ្រិក ការប្រែប្រួលអាកាសធាតុនៅអាស៊ី ការប្រព្រឹត្តមកលើជនជាតិដើមភាគតិចនៅអឺរ៉ុបកណ្ដាល និងការប្រឈមនានានៃវិសមភាព និងសន្តិសុខពលរដ្ឋនៅអាមេរិកឡាទីន និងនៅតំបន់ឈូងសមុទ្រការ៉ាអ៊ីប។

**របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិ ៖** ចាប់តាំងពីមានការចេញផ្សាយជាលើកដំបូងនៅឆ្នាំ ១៩៩២ របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិត្រូវបានរៀបរៀង និងផលិតដោយក្រុមអ្នកនិពន្ធនៅក្នុងមូលដ្ឋាននៃប្រទេសចំនួន ១៤០ ក្រោមការគាំទ្រពីយូអិនឌីភី។ របាយការណ៍ទាំងនេះ ដែលមកទល់បច្ចុប្បន្ននេះ មានចំនួនប្រមាណ ៧០០ មកហើយ បានផ្ដល់ទស្សនទានអំពីការអភិវឌ្ឍមនុស្សសម្រាប់ការគិតគូរនៅក្នុងគោលនយោបាយជាតិ តាមរយៈការពិគ្រោះយោបល់ និងការស្រាវជ្រាវនៅមូលដ្ឋាន។ របាយការណ៍អភិវឌ្ឍន៍មនុស្សថ្នាក់ជាតិចែងអំពីបញ្ហាអភិវឌ្ឍន៍សំខាន់ៗជាច្រើន ដែលរាប់ចាប់ពីការប្រែប្រួលអាកាសធាតុ រហូតដល់ការងាររបស់យុវជន និងវិសមភាព ដែលជំរុញដោយយេនឌ័រ និងជាតិពន្ធុ។

## របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ១៩៩០ - ២០១៣

| | |
|---|---|
| ១៩៩០ | គោលការណ៍គ្រឹះ និងរង្វាស់អភិវឌ្ឍន៍មនុស្ស |
| ១៩៩១ | ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍមនុស្ស |
| ១៩៩២ | កត្តានានានៃការអភិវឌ្ឍមនុស្សនៅកម្រិតពិភពលោក |
| ១៩៩៣ | ការចូលរួមរបស់ប្រជាជន |
| ១៩៩៤ | កត្តាថ្មីៗនៃសន្តិសុខមនុស្ស |
| ១៩៩៥ | យេនឌ័រ និងការអភិវឌ្ឍមនុស្ស |
| ១៩៩៦ | កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍមនុស្ស |
| ១៩៩៧ | ការអភិវឌ្ឍមនុស្សដើម្បីលុបបំបាត់ភាពក្រីក្រ |
| ១៩៩៨ | ការប្រើប្រាស់ដើម្បីអភិវឌ្ឍមនុស្ស |
| ១៩៩៩ | សកលភាវូបនីយកម្មដោយផ្ដោតលើមនុស្សជាតិ |
| ២០០០ | សិទ្ធិមនុស្ស និងការអភិវឌ្ឍមនុស្ស |
| ២០០១ | ការធ្វើឲ្យបច្ចេកវិទ្យាថ្មីបម្រើប្រយោជន៍ការអភិវឌ្ឍមនុស្ស |
| ២០០២ | ការធ្វើឲ្យដំណើរការប្រជាធិបតេយ្យកាន់តែស៊ីជម្រៅនៅក្នុងពិភពលោកមួយដែលមានការបែងចែក |
| ២០០៣ | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ៖ ភាពរឹងមាំក្នុងចំណោមប្រជាជាតិនានានៅក្នុងការបញ្ចប់ភាពក្រីក្រ |
| ២០០៤ | សេរីភាពខាងវប្បធម៌នៅក្នុងពិភពលោកចម្រុះសព្វថ្ងៃនេះ |
| ២០០៥ | កិច្ចសហប្រតិបត្តិការអន្តរជាតិត្រង់ផ្លូវបំបែក ៖ ជំនួយពាណិជ្ជកម្ម និងសន្តិសុខនៅក្នុងពិភពលោកដែលមិនស្មើភាព |
| ២០០៦ | ទៅហួសពីភាពខ្វះខាត ៖ ថាមពល ភាពក្រីក្រ និងវិបត្តិទឹកលើពិភពលោក |
| ២០០៧/២០០៨ | ប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ ៖ សាមគ្គីភាពមនុស្សជាតិក្នុងពិភពលោកមួយខ្វះការចុះសម្រុងគ្នា |
| ២០០៩ | ជំនះរបាំងឧបសគ្គ ៖ ភាពចល័ត និងការអភិវឌ្ឍមនុស្ស |
| ២០១០ | ទ្រព្យសម្បត្តិពិតប្រាកដរបស់ប្រជាជាតិ ៖ មាគ៌ាទៅរកការអភិវឌ្ឍមនុស្ស |
| ២០១១ | និរន្តរភាព និងសមធម៌ ៖ អនាគតកាន់តែប្រសើរមួយសម្រាប់ទាំងអស់គ្នា |
| ២០១៣ | ការឈានឡើងនៃភូមិភាគខាងត្បូង ៖ វឌ្ឍនភាពមនុស្សក្នុងពិភពលោកចម្រុះ |

United Nations Development Programme
One United Nations Plaza
New York, NY 10017

www.undp.org

សតវត្សរ៍ទី ២១ នេះកំពុងឃើញនូវការផ្លាស់ប្តូរស៊ីជម្រៅនៃចរន្តឌីណាមិកលើសកលលោកដែលបណ្តាលមកពីដំណើរឈានទ្បើងយ៉ាងឆាប់រហ័សនៃប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការក្លាយទៅជាអំណាចថ្មីលើឆាកអន្តរជាតិ។ ចិនបានជែងហួសជប៉ុន ក្នុងនាមជាសេដ្ឋកិច្ចធំជាងគេ ទីពីរលើសកលលោកដោយតាមរយៈនេះ បានជួយស្តូចប្រជាជនជាច្រើនរយលាននាក់ឲ្យចាកផុតពីភាពក្រីក្រ។ ឥណ្ឌាកំពុងធ្វើការតម្រែតម្រង់អនាគតរបស់ខ្លួនតាមរយៈភាពច្នៃប្រឌិតថ្មីៗខាងសហគ្រាស និងនិម្មិតកម្មខាងគោលនយោបាយសង្គម។ ប្រេស៊ីល កំពុងលើកស្ទួយស្តង់ដារនៃការរស់នៅរបស់ខ្លួន តាមរយៈការពង្រីកទំនាក់ទំនងអន្តរជាតិ និងកម្មវិធីប្រឆាំងភាពក្រីក្រ ដែលបានផ្តល់ជាគំរូអនុវត្តនៅទូទាំងពិភពលោក។

ប៉ុន្តែ "ការឈានទ្បើងនៃភូមិភាគខាងត្បូង" គឺជាបាតុភូតមួយធំជាងនេះឆ្ងាយណាស់។ ទួរគី ម៉ិចស៊ិក ថៃ អាហ្វ្រិកខាងត្បូង ឥណ្ឌូនេស៊ី និងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតជាច្រើន កំពុងក្លាយជាអ្នកដើរតួនាំមុខនៅលើឆាកពិភពលោក។ របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៣ បានរកឃើញថា ប្រទេសកំពុងអភិវឌ្ឍន៍ច្រើនជាង ៤០ នៅទូទាំងពិភពលោក បានសម្រេចសមិទ្ធផលប្រសើរជាងការរំពឹងទុកលើការអភិវឌ្ឍមនុស្ស នៅក្នុងបណ្តាទសវត្សរ៍កន្លងទៅនេះ ដោយមានកំណើននៃការរីកចម្រើនគួរឲ្យកត់សំគាល់ នៅក្នុងរយៈពេលដប់ឆ្នាំកន្លងទៅនេះ។

ប្រទេសទាំងនេះនីមួយៗមានប្រវត្តិដោយឡែកៗ និងបានជ្រើសយកមាគ៌ានៃការអភិវឌ្ឍ តាមតម្រូវការជាក់ស្តែងរៀងៗខ្លួនដែរ។ ប៉ុន្តែ ប្រទេសទាំងនេះមានសំណុំលក្ខណៈរួមសំខាន់ៗ និងប្រឈមការលំបាកដូចៗគ្នាជាច្រើន។ ប្រទេសទាំងនេះក៏កាន់តែផ្សារភ្ជាប់ជាមួយគ្នា និងពឹងផ្អែកលើគ្នាកាន់តែជិតស្និទ្ធផងដែរ។ ប្រជាពលរដ្ឋក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅទូទាំងពិភពលោក ក៏ទាមទារសិទ្ធិបញ្ចេញទស្សនៈកាន់តែច្រើនក្នុងពេលដែលពួកគេចែករំលែកគំនិត តាមរយៈប្រព័ន្ធប្រាស្រ័យទាក់ទងថ្មីៗ និងទាមទារឲ្យរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិមានគណនេយ្យភាពកាន់តែច្រើនជាងមុនផងដែរ។

របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០១៣ វិភាគអំពីមូលហេតុ និងផលវិបាកនៃការបន្ត "ឈានទ្បើងនៃភូមិភាគខាងត្បូង" និងកំណត់អត្តសញ្ញាណគោលនយោបាយនានាដែលកើតចេញពីតថភាពនេះ ដែលអាចជំរុញវឌ្ឍនភាពនេះកាន់តែខ្លាំងទ្បើងនៅទូទាំងពិភពលោក សម្រាប់ច្រើនទសវត្សរ៍ទៅមុខទៀត។ របាយការណ៍នេះអំពាវនាវឲ្យមានតំណាងនៃបណ្តាប្រទេសនៅភូមិភាគខាងត្បូង កាន់តែច្រើនថែមទៀតនៅក្នុងប្រព័ន្ធអភិបាលកិច្ចពិភពលោក និងចង្អុលបង្ហាញប្រភពថ្មីៗ នៃហិរញ្ញប្បទាននៅក្នុងភូមិភាគខាងត្បូង សម្រាប់ជាប្រយោជន៍សាធារណៈសំខាន់ៗ។ តាមរយៈទស្សនៈទានថ្មីៗដែលបានពីការវិភាគ និងសំណើច្បាស់លាស់ឲ្យមានកំណែទម្រង់គោលនយោបាយ របាយការណ៍នេះ ជួយបង្ហាញមាគ៌ាសម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ទាំងអស់ ឲ្យសហការគ្នាតទល់នឹងការលំបាករួមនៃការអភិវឌ្ឍមនុស្ស ដោយត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

*"របាយការណ៍នេះរម្លឹកទ្បើងវិញនូវការយល់ដឹងរបស់យើង អំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍពិភពលោក និងបង្ហាញថាតើយើងអាចរៀនសូត្របែបណាពីបទពិសោធន៍នានានៃវឌ្ឍនភាពយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍនៅក្នុងប្រទេសជាច្រើននៅភូមិភាគខាងត្បូង។"*

—ដកស្រង់ពីអារម្ភកថាដោយ លោកស្រី Helen Clark, អភិបាលយូអិនឌីភី

*"វិធានអភិវឌ្ឍន៍មនុស្ស គឺជាការរីកចម្រើនចម្បងមួយនៅក្នុងលំហាត់ដ៏លំបាកនៃការស្វែងយល់អំពីជោគជ័យ និងការខ្វះខាតនៅក្នុងជីវិតរបស់មនុស្ស និងក្នុងការទទួលស្គាល់អំពីសារៈសំខាននៃការឆ្លុះបញ្ចាំង និងការពិភាក្សា និងដើម្បីឈានទៅរកភាពត្រឹមត្រូវ និងយុត្តិធម៌ក្នុងពិភពលោក។"*

—ដកស្រង់ពីជំពូក១ ដោយជ័យលាភីរង្វាន់ណូបែល Amartya Sen

*"គ្មានអ្នកណាម្នាក់មានភាពផ្តាច់មុខខាងគំនិតល្អៗនោះទេហេតុនេះហើយទើបក្រុងញូវយ៉កត្រូវតែបន្តរៀនសូត្រពីទម្លាប់ល្អៗរបស់ទីក្រុងនិងប្រទេសដទៃទៀត។"*

—ដកស្រង់ពីជំពូក ៣ ដោយ Michael Bloomberg អភិបាលក្រុងញូវយ៉ក

*"ការសង្កេតឲ្យបានច្បាស់លាស់នូវមាគ៌ាខុសៗគ្នានៃការអភិវឌ្ឍ ដែលប្រទេសកំពុងអភិវឌ្ឍន៍មានជោគជ័យបានប្រកាន់យក បានជួយបង្កើនជម្រើសគោលនយោបាយសម្រាប់ប្រទេស និងតំបន់ទាំងអស់" ។*

—ដកស្រង់ពីសេចក្តីផ្តើម ដោយ Khalid Malik ប្រធានក្រុមអ្នកនិពន្ធ